ធនាគារជាតិនៃកម្ពុជា

ប្រាក់រៀល ស្ថិរភាព អភិវឌ្ឍន៍

# ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍ បច្ចេកវិទ្យាហិរញ្ញវត្ថុ ២០២០-២០២៥



# អារម្ភកថា

បច្ចេកវិទ្យាហិរញ្ញវត្ថុ ជាវិស័យមួយដែលលេចធ្លោក្នុងចំណោមឧស្សាហកម្មនានាក្នុងប្រទេសកម្ពុជា។ គិតចាប់តាំងពីឆ្នាំ២០១០ វត្តមានរបស់បច្ចេកវិទ្យាហិរញ្ញវត្ថុ បានចូលរួមលើកស្ទួយកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព តាមរយៈការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុគ្រប់ផ្នែកទូទាំងប្រទេស តាំងពីទីប្រជុំជនរហូតដល់ជនបទ។

ការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ បានជំរុញឱ្យប្រទេសកម្ពុជាឈានមុខក្នុងការបង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ និងការកាត់បន្ថយភាពក្រីក្រដែលគាំទ្រដោយការអភិវឌ្ឍតាមសេដ្ឋកិច្ចយ៉ាងឆាប់រហ័សជាមួយការរីកចម្រើនក្នុងវិស័យកសិកម្ម វាយនភណ្ឌ និងទេសចរណ៍។ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អត្រាភាពក្រីក្រនៅកម្ពុជាបានថយចុះពី ៤៧,៨% ក្នុងឆ្នាំ២០០៧ មកត្រឹម ១៧,៨% នៅឆ្នាំ២០២០ ហើយប្រទេសកម្ពុជាបានសម្រេចគោលដៅអភិវឌ្ឍសហស្សវត្សរ៍ ដោយបានកាត់បន្ថយអត្រាភាពក្រីក្រត្រឹមពាក់កណ្តាលក្នុងឆ្នាំ២០០៩។ នៅឆ្នាំ២០១៥ កម្ពុជាបានប្រែក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងឆ្ពោះទៅរកគោលដៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ជាមួយនឹងអត្រាកំណើនសេដ្ឋកិច្ចចំនួន ៧,១% ក្នុងឆ្នាំ២០១៩ កម្ពុជានៅតែជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចឈានមុខគេនៅតំបន់អាស៊ីអាគ្នេយ៍។

ក្រៅពីវឌ្ឍនភាពដ៏ឆាប់រហ័សនេះ ក្នុងបរិបទនៃការរីករាលដាលនៃជម្ងឺកូវីដ-១៩ នាពេលបច្ចុប្បន្ន បានជំរុញឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុទ្វេដង ដោយសារសេវាធនាគារឌីជីថលមានតម្លៃសមរម្យ ងាយស្រួលប្រើ ជាពិសេសសម្រាប់សាធារណជនដែលនៅក្រៅប្រព័ន្ធហិរញ្ញវត្ថុ ហើយពុំមានលទ្ធភាពប្រើប្រាស់សេវាហិរញ្ញវត្ថុ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាបានជំរុញឱ្យមានបរិស្ថានសមស្របសម្រាប់បច្ចេកវិទ្យាហិរញ្ញវត្ថុរីកលូតលាស់ថែមទៀត។ ក្នុងនោះ ធនាគារជាតិនៃកម្ពុជាបានអនុវត្តវិធីសាស្ត្រ សង្កេត សិក្សា និងអនុវត្ត ដើម្បីជំរុញការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុនៅប្រទេសកម្ពុជាទាំងទំហំ និងវិសាលភាព។ អនុលោមតាមឧត្តមានុវត្តន៍អន្តរជាតិដូចបណ្តាធនាគារកណ្តាលអាជ្ញាធររូបិយវត្ថុ និងនិយ័តករចម្បងៗដែរ ធនាគារជាតិនៃកម្ពុជាបានដើរតួជាអាជ្ញាធរសម្របសម្រួលក្នុងប្រព័ន្ធអេកូឡូស៊ីវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីសម្រេចបាននវានុវត្តន៍ថ្មីៗ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការថ្នាក់ជាតិនិងក្នុងតំបន់។ ស្ថិតនៅក្នុងបរិបទនេះ ដោយមានជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំដាក់ឱ្យប្រើផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុឆ្នាំ២០២០-២០២៥។

ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុឆ្នាំ២០២០-២០២៥ ត្រូវបានបង្កើតឡើងដើម្បីតម្រង់ទិសសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា ដោយផ្តោតលើសសរស្តម្ភចំនួន៣ រួមមាន (១)សេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ (២)បច្ចេកវិទ្យាគាំទ្រ និង (៣)គោលនយោបាយជំរុញ។

ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលធនាគារជាតិនៃកម្ពុជាបានរៀបចំនេះ អនុលោមតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលមានទិសដៅលើកកម្ពស់នវានុវត្តន៍នៃប្រព័ន្ធអេកូឡូស៊ីឌីជីថលទាំងមូល និងការទទួលយកបច្ចេកវិទ្យាថ្មីៗក្នុងវិស័យហិរញ្ញវត្ថុ។ ការងារទាំងនេះពាក់ព័ន្ធនឹងការអភិវឌ្ឍ ការគាំទ្រនិងការអនុវត្តគោលនយោបាយឌីជីថលសំខាន់ៗដូចជា អត្តសញ្ញាណឌីជីថល ដំណើរការហិរញ្ញវត្ថុដោយស្វ័យប្រវត្តិ បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត ឃ្លាំងផ្ទុកទិន្នន័យនិងការចែករំលែកទិន្នន័យ បច្ចេកវិទ្យាក្លោដ បច្ចេកវិទ្យាឌីអិលធី ក្របខណ្ឌធនាគារបើកចំហ ការកំណត់អត្តសញ្ញាណអតិថិជនជាអេឡិចត្រូនិក ព្រមទាំងគំនិតផ្តួចផ្តើមផ្សេងទៀត។

ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ជាគោលការណ៍ណែនាំដើម្បីសម្របសម្រួលដំណើរការ និងផ្លាស់ប្តូរដោយរលូនឆ្ពោះទៅរកបច្ចេកវិទ្យាហិរញ្ញវត្ថុជឿនលឿនសម្រាប់សាធារណជនដែលពុំមានលទ្ធភាពប្រើប្រាស់សេវាធនាគារ និងជាស្ពានចម្លងប្រសើរថែមទៀតសម្រាប់សាធារណជននិងធុរកិច្ចដែលមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការនៅក្នុងប្រទេសកម្ពុជា។ ហេតុនេះការផ្តល់សេវាកម្មហិរញ្ញវត្ថុតាមបែបឌីជីថល តាមរយៈការពង្រឹងប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងប្រទេស និងគាំទ្រដល់ការអនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ជាគោលបំណង និងការងារអាទិភាពដែលធនាគារជាតិនៃកម្ពុជាផ្តោតការយកចិត្តទុកដាក់ដូចបានលើកឡើងក្នុងយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ។ ក្នុងន័យនេះ បរិយាបន្នហិរញ្ញវត្ថុរំពឹងទុកថានឹងត្រូវបានពង្រឹងបន្ថែមទៀត តាមរយៈការផ្សារភ្ជាប់នៃបច្ចេកវិទ្យាឌីជីថលដែលនាំមកនូវប្រសិទ្ធភាព និងសុវត្ថិភាពសម្រាប់ប្រតិបត្តិការឌីជីថល និងការប្រើប្រាស់កាន់តែទូលំទូលាយ។

ផែនទីមគ្គុទ្ទេសក៍នេះ នឹងផ្តល់ឱកាសដល់បច្ចេកវិទ្យាហិរញ្ញវត្ថុអាចតភ្ជាប់ទំនាក់ទំនងគ្នាតាមរយៈការចូលរួមក្នុងប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់កន្លោងសម្រេចបាននូវការទូទាត់ឆ្លងអន្តរគ្រឹះស្ថាន ដែលនឹងជំរុញនវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុនាពេលខាងមុខបន្ថែមទៀត។ ស្របជាមួយនឹងយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុឆ្នាំ២០២០-២០២៥ នេះ នឹងនាំមកនូវសេវា និងផលិតផលហិរញ្ញវត្ថុឌីជីថលសំបូរបែបប្រកបដោយភាពងាយស្រួល មានប្រសិទ្ធភាព លទ្ធភាពទទួលយកនិងប្រើប្រាស់បានប្រសើរជាងមុន។

ធនាគារជាតិនៃកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះធនាគារអភិវឌ្ឍន៍អាស៊ីដែលបានផ្តល់ជំនួយបច្ចេកទេសក្នុងការរៀបចំផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ និងសូមថ្លែងអំណរគុណដល់ភាគីពាក់ព័ន្ធទាំងអស់ដូចជា សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូ-ហិរញ្ញវត្ថុកម្ពុជា និងសមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការពិភាក្សា និងផ្តល់អនុសាសន៍សម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងក្របខណ្ឌប្រព័ន្ធអេកូឡូស៊ីជាតិ។ ធនាគារជាតិនៃកម្ពុជាសង្ឃឹមយ៉ាងមុតមាំថា ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុឆ្នាំ២០២០-២០២៥ នឹងគាំទ្រដល់គោលដៅថ្នាក់ជាតិ ក្នុងការពន្លឿនបរិយាបន្នហិរញ្ញវត្ថុតាមរយៈការផ្តល់សេវាកម្ម និងផលិតផលបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា។

ទេសាភិបាល

ជា.ចាន់តូ

# មាតិកា


អារម្ភកថា i

អក្សរកាត់ v

ខ្លឹមសារសង្ខេប ១

ជំពូក ១ សេចក្តីផ្តើម ៣

I. និដ្ឋភាពទូទៅ ៣

II. ទស្សនៈវិស័យ ៤

III. និសដៅ ៤

IV. វិសាលភាព ៤

ជំពូក ២ សសរស្តម្ភបច្ចេកវិទ្យាហិរញ្ញវត្ថុ ៥

ជំពូក ៣ ស្ថានភាពបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា ១១

I. និដ្ឋភាពទូទៅនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ១១

II. ក្របខណ្ឌគតិយុត្តពាក់ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ ១២

១. បទប្បញ្ញត្តិសម្រាប់រូបិយវត្ថុអេឡិចត្រូនិក និងសេវាទូទាត់សងប្រាក់ឌីជីថល ១៣

២. បទប្បញ្ញត្តិសម្រាប់មូលធនក្រោដហ្វាន់ឌីង ១៣

៣. បទប្បញ្ញត្តិសម្រាប់បច្ចេកវិទ្យាធានារ៉ាប់រង ១៤

៤. ច្បាប់ស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ១៤

៥. ច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់ ១៤

III. ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ដែលគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ១៥

១. ប្រព័ន្ធទូទាត់តម្លៃធំ ១៥

២. ប្រព័ន្ធទូទាត់រាយ ១៦

៣. ការទូទាត់សងប្រាក់ និងផ្ទេរប្រាក់ឆ្លងដែន ១៨

៤. ការលើកកម្ពស់ការទូទាត់ឆ្លងគ្រឹះស្ថាន និងស្តង់ដារក្នុងការទូទាត់សងប្រាក់ ១៨

IV. បញ្ហាប្រឈម និងកាលានុវត្តភាព ១៨

១. បញ្ហាប្រឈម ១៩

២. កាលានុវត្តភាព ២០

ជំពូក ៤ និដ្ឋភាពគោលនយោបាយបច្ចេកវិទ្យាហិរញ្ញវត្ថុ ២២

I. សេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ ២២

១. សេវាធនាគារឌីជីថល ២២

២. ថ្នាលហិរញ្ញប្បទានបច្ចេកវិទ្យាហិរញ្ញវត្ថុ ២៤

៣. មូលធនក្រោដហ្វាន់ឌីង ២៥

៤. សេវាបម្រើអតិថិជនស្វ័យប្រវត្តិ ២៦

៥. រូបិយវត្ថុអេឡិចត្រូនិក និងសេវាទូទាត់សងប្រាក់ឌីជីថល ២៧

៦. បច្ចេកវិទ្យាធានារ៉ាប់រង ២៨

៧. ទ្រព្យសកម្មគ្រីបតូ និងសកម្មភាពពាក់ព័ន្ធ ២៩

II. បច្ចេកវិទ្យាគាំទ្រ ២៩

១. សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ ២៩

២. បញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សា ៣១

៣. បច្ចេកវិទ្យាជីវមាត្រសម្រាប់ការកំណត់ និងផ្ទៀងផ្ទាត់អត្តសញ្ញាណ ៣២

៤ .បច្ចេកវិទ្យាក្លោដ ៣៣

៥. បច្ចេកវិទ្យាឌីអិលធី ៣៤

III. គោលនយោបាយជំរុញ ៣៧

១. អត្តសញ្ញាណឌីជីថល ៣៧

២. ក្របខណ្ឌធនាគារបើកចំហ ៣៩

៣. ក្របខណ្ឌការពារទិន្នន័យ ៤១

៤. ក្របខណ្ឌសន្តិសុខសាយប័រ ៤២

៥. ចំណេះដឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ និងឌីជីថល ៤៣

៦. គំនិតផ្តួចផ្តើមជំរុញនវានុវត្តន៍ ៤៥

៦.១. បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ ៤៥

៦.២. មជ្ឈមណ្ឌលនវានុវត្តន៍ ៤៧

ជំពូក ៥ យុទ្ធសាស្ត្រឆ្លើយតប ៤៩

ជំពូក ៦ ផែនការសកម្មភាពអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ ៥៥

ឯកសារយោង ៦៤

# អក្សរកាត់

| | | |
|---|---|---|
| ABC | សមាគមធនាគារនៅកម្ពុជា | Association of Banks in Cambodia |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី | Asian Development Bank |
| AI | បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត | Artificial Intelligence |
| AML/CFT | ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | Anti-Money Laundering / Combating the Financing of Terrorism |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ | Association of Southeast Asian Nations |
| CAFT | សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា | Cambodian Association of Finance and Technology |
| CMA | សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា | Cambodia Microfinance Association |
| CSS | ប្រព័ន្ធខេមបូឌានស៊ែស្វីច | Cambodian Shared Switch |
| DLT | បច្ចេកវិទ្យាឌីអិលធី | Distributed Ledger Technology |
| e-KYC | នីតិវិធីស្គាល់អតិថិជនជាអេឡិចត្រូនិក | Electronic Know Your Customer |
| EMV | យូរ៉ូផេ ម៉ាស្ទ័រកាត និង វីសា | Europay, Mastercard, and VISA |
| FDR | ផែនទីមគ្គុទេសន៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ | FinTech Development Roadmap |
| FSDS | យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ | Financial Sector Development Strategy |
| ICT | បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន | Information Communication Technology |
| KHQR | ខ្មែរឃ្វីករ៉េសស្ប៉ុន | Khmer Quick Response |
| KYC | នីតិវិធីស្គាល់អតិថិជន | Know Your Customer |
| MEF | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | Ministry of Economy and Finance |
| MFI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | Microfinance Institution |
| ML | បច្ចេកវិទ្យាម៉ាស៊ីនស្វ័យសិក្សា | Machine Learning |
| MOI | ក្រសួងមហាផ្ទៃ | Ministry of Interior |
| MSME | សហគ្រាសមីក្រូ ធនតូច និងមធ្យម | Micro Small and Medium enterprises |
| NACC | គណកម្មការជាតិប្រឆាំងបទល្មើសតាមប្រព័ន្ធសាយប័រ | National Anti-Cybercrime Committee |
| NBC | ធនាគារជាតិនៃកម្ពុជា | National Bank of Cambodia |
| NCS | ប្រព័ន្ធផាត់ទាត់ជាតិ | National Clearing System |
| NFIS | យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ | National Financial Inclusion Strategy |
| RTGS | ប្រព័ន្ធទូទាត់ដុលភ្លាមៗ | Real Time Gross Settlement |
| SECC | និយ័តករមូលបត្រកម្ពុជា | Securities and Exchange Commission of Cambodia |

# ខ្លឹមសារសង្ខេប

កំណើនអត្រាប្រជាជនវ័យក្មេង ការប្រើប្រាស់ទូរស័ព្ទចល័ត ការប្រើប្រាស់រូបិយវត្ថុអេឡិចត្រូនិក ការទិញទំនិញអនឡាញ និងការទូទាត់ឌីជីថល និងការផ្លាស់ប្តូរឥរិយាបថទៅកាន់ការទូទាត់សងប្រាក់ឌីជីថល បានបង្ហាញពីសក្តានុពលសមស្របមួយសម្រាប់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងប្រតិបត្តិការឌីជីថលក្នុងប្រទេសកម្ពុជា។ ដោយមើលឃើញពីអត្ថប្រយោជន៍របស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានចាត់ទុកការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុជាមធ្យោបាយមួយក្នុងការចូលរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារ ក៏ដូចជារួមចំណែកនៅក្នុងដំណើរឆ្ពោះទៅរកសេដ្ឋកិច្ចនិងសង្គមឌីជីថលនៅកម្ពុជា។

ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុឆ្នាំ២០២០-២០២៥ ត្រូវបានរៀបចំឡើងស្របតាមគោលដៅយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ និងយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ និងអនុលោមតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ដែលរៀបចំដោយរាជរដ្ឋាភិបាលកម្ពុជា។ ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុត្រូវបានរំពឹងថា នឹងចូលរួមបង្កើនការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ លើកកម្ពស់ការប្រើប្រាស់សេវាបច្ចេកវិទ្យាហិរញ្ញវត្ថុ និងប្រតិបត្តិការឌីជីថលនៅប្រទេសកម្ពុជា។

ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ផ្តោតលើសសរស្តម្ភសំខាន់ៗចំនួន ៣ ដែលជាឧត្តមានុវត្តន៍អន្តរជាតិ ប៉ុន្តែត្រូវបានរៀបចំនិងកែសម្រួលឱ្យស្របតាមបរិបទរបស់ប្រទេសកម្ពុជាដូចជា (១)សេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ (២)បច្ចេកវិទ្យាគាំទ្រ និង (៣)គោលនយោបាយជំរុញ។ លើសពីនេះ ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក៏បានកំណត់វិស័យអាទិភាពសំខាន់ៗ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា រួមមាន៖

| សសរស្តម្ភ | ផ្នែក | យុទ្ធសាស្ត្រ |
|---|---|---|
| **សសរស្តម្ភទី១៖** **សេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ** | **១. ប្រាក់បញ្ញើនិងឥណទាន** | |
| | ក. សេវាធនាគារឌីជីថល | លើកកម្ពស់ផលិតផល និងសេវាធនាគារឌីជីថលប្រកបដោយនវានុវត្តន៍ |
| | ខ.ផ្តាលហិរញ្ញប្បទានបច្ចេកវិទ្យាហិរញ្ញវត្ថុ | រៀបចំក្របខណ្ឌបទប្បញ្ញត្តិដែលទាក់ទងទៅនឹងផ្តាលហិរញ្ញប្បទានបច្ចេកវិទ្យាហិរញ្ញវត្ថុឱ្យស្របទៅតាមបរិបទ និងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជា |
| | **២. សេវាផាត់ទាត់ និងទូទាត់សងប្រាក់** | |
| | រូបិយវត្ថុអេឡិចត្រូនិក និងសេវាទូទាត់សងប្រាក់ឌីជីថល | ពិនិត្យក្របខណ្ឌបទប្បញ្ញត្តិ ដើម្បីគាំទ្រដល់នវានុវត្តន៍ និងគ្រប់គ្រងហានិភ័យដែលអាចកើតមាននៅក្នុងសេវាទូទាត់សងប្រាក់ឌីជីថល |

| សសរស្តម្ភ | ផ្នែក | យុទ្ធសាស្ត្រ |
|---|---|---|
| **សសរស្តម្ភទី២៖ បច្ចេកវិទ្យាគាំទ្រ** | ក. សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ | ដាក់ចេញគោលការណ៍ណែនាំ ដើម្បីជំរុញការដាក់ឱ្យប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រនៅក្នុងគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ |
| | ខ. បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សា | ពិចារណាដាក់ចេញគោលការណ៍ណែនាំស្តីពី ការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សាក្នុងវិស័យធនាគារ |
| | គ. បច្ចេកវិទ្យាជីវមាត្រ | ជំរុញការប្រើប្រាស់បច្ចេកវិទ្យាជីវមាត្រនៅក្នុងគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ |
| | ឃ. បច្ចេកវិទ្យាក្លោដ | លើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពលើការប្រើប្រាស់បច្ចេកវិទ្យាក្លោដ ក្នុងគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ |
| | ង. បច្ចេកវិទ្យាឌីអិលធី | ពិនិត្យលទ្ធភាពក្នុងការដាក់ចេញផលិតផល និងសេវាកម្មថ្មីៗទៀត ដែលប្រើប្រាស់បច្ចេកវិទ្យាឌីអិលធី នៅក្នុងវិស័យធនាគារ |
| **សសរស្តម្ភទី៣៖ គោលនយោបាយជំរុញ** | ក. អត្តសញ្ញាណឌីជីថល | ចូលរួមនៅក្នុងគំនិតផ្តួចផ្តើមថ្នាក់ជាតិ ក្នុងការអភិវឌ្ឍ និងប្រើប្រាស់ថ្នាលអត្តសញ្ញាណកម្មឌីជីថលរួម |
| | ខ. ក្របខណ្ឌធនាគារបើកចំហ | ពិនិត្យលទ្ធភាពក្នុងការអភិវឌ្ឍក្របខណ្ឌធនាគារបើកចំហនៅក្នុងវិស័យធនាគារ |
| | គ. ក្របខណ្ឌការពារទិន្នន័យ | ពិនិត្យលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តក្របខណ្ឌបទប្បញ្ញត្តិសម្រាប់ការការពារទិន្នន័យនៅក្នុងវិស័យធនាគារ |
| | ឃ. ក្របខណ្ឌសន្តិសុខសាយប័រ | ពិនិត្យឡើងវិញលើក្របខណ្ឌហានិភ័យសន្តិសុខសាយប័រនៅក្នុងវិស័យធនាគារ រួមទាំងបច្ចេកវិទ្យាហិរញ្ញវត្ថុ ឱ្យស្របតាមក្របខណ្ឌថ្នាក់ជាតិ សម្រាប់ក្របខណ្ឌសន្តិសុខសាយប័រ |
| | ង. ចំណេះដឹងផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ និងឌីជីថល | ដាក់ចេញកម្មវិធីស្តីពី ចំណេះដឹងហិរញ្ញវត្ថុដោយសហការជាមួយគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ |
| | ច. គំនិតផ្តួចផ្តើមជំរុញនវានុវត្តន៍ | ពិនិត្យលទ្ធភាពក្នុងការរៀបចំ និងដាក់ឱ្យប្រើប្រាស់បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ |
| | | ពិនិត្យលទ្ធភាពក្នុងការរៀបចំ និងដាក់ឱ្យប្រើប្រាស់មុខងារមជ្ឈមណ្ឌលនវានុវត្តន៍សម្រាប់វិស័យធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ |

# ជំពូក ១ សេចក្ដីផ្ដើម

## I. ទិដ្ឋភាពទូទៅ

ក្នុងនាមជាធនាគារកណ្តាល ធនាគារជាតិនៃកម្ពុជាបានដើរតួជានិយ័តករយ៉ាងសំខាន់ក្នុងការរក្សាតុល្យភាពរវាងគុណសម្បត្តិនៃបច្ចេកវិទ្យាហិរញ្ញវត្ថុសម្រាប់បរិយាបន្នហិរញ្ញវត្ថុ និងផលប៉ះពាល់សេដ្ឋកិច្ច ដែលបច្ចេកវិទ្យាហិរញ្ញវត្ថុអាចបង្កឡើង ជាពិសេសក្នុងវិស័យហិរញ្ញវត្ថុ។ នារយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ បច្ចេកវិទ្យាហិរញ្ញវត្ថុបានចាប់ផ្តើមរីកចម្រើនខ្លាំងនៅប្រទេសកម្ពុជា។ ល្បឿននៃនវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងការអភិវឌ្ឍផលិតផលនិងទីផ្សារ បានធ្វើឱ្យគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការដូចជា គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុមានសក្តានុពលបោះជំហានទៅមុខយ៉ាងឆាប់រហ័ស។

បច្ចេកវិទ្យាហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងប្រតិបត្តិការឌីជីថលនៅក្នុងប្រទេសកម្ពុជា។ ដោយមើលឃើញពីសក្តានុពលរបស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់ក្នុងការរៀបចំក្របខណ្ឌគតិយុត្តដែលគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ជាពិសេសផ្តល់លទ្ធភាពឱ្យសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងអ្នកប្រើប្រាស់អាចទទួលបានសេវាទូទាត់សងប្រាក់ដែលគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ទោះបីជាមានការរំពឹងទុកពីលទ្ធផលវិជ្ជមានដែលនឹងទទួលបានពីការអភិវឌ្ឍក្នុងដំណាក់កាលដំបូងក៏ដោយ ក៏ការវិវត្តន៍ឥតឈប់ឈរនៃបច្ចេកវិទ្យាហិរញ្ញវត្ថុបានជំរុញឱ្យធនាគារជាតិនៃកម្ពុជាពង្រឹងក្របខណ្ឌគតិយុត្ត ដើម្បីធានាបច្ចេក-វិទ្យាហិរញ្ញវត្ថុមានសុវត្ថិភាព និងស្ថិរភាព ព្រមទាំងគាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធចម្បងៗ ដើម្បីធ្វើឱ្យប្រតិបត្តិការទូទាត់ឆ្លងអន្តរគ្រឹះស្ថានកាន់តែប្រសើរ និងមានប្រសិទ្ធភាពផងដែរ។

ម្យ៉ាងវិញទៀត បច្ចេកវិទ្យាហិរញ្ញវត្ថុមានសក្តានុពលខ្ពស់ក្នុងការកាត់បន្ថយចំណាយថ្លៃដើមលើសេវាហិរញ្ញវត្ថុ និងលើកកម្ពស់ការទទួលបានសេវាហិរញ្ញវត្ថុសម្រាប់ប្រជាជនមានប្រាក់ចំណូលទាបដែលមិនមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុទូទៅ។ ប៉ុន្តែបច្ចេកវិទ្យាហិរញ្ញវត្ថុក៏អាចបង្កឱ្យមានហានិភ័យផ្សេងៗ ពាក់ព័ន្ធនឹងការលួចបន្លំ ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម សន្តិសុខសាយប័រ និងការបំពានលើឯកជនភាពរបស់បុគ្គល។ ដូច្នេះ ធនាគារជាតិនៃកម្ពុជាបានព្យាយាមរក្សាតុល្យភាពរវាងគុណសម្បត្តិ និងហានិភ័យ ក្នុងការទទួលយកនិងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយមិនធ្វើឱ្យប៉ះពាល់វិស័យធនាគារនិងហិរញ្ញវត្ថុទូទៅនៅកម្ពុជា។

ដោយមានជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារជាតិនៃកម្ពុជាបានរៀបចំផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ សម្រាប់រយៈពេល ៥ឆ្នាំ។ ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុពន្យល់អំពីការអនុវត្តវិធានការពាក់ព័ន្ធនឹងសសរស្តម្ភ និងការអនុវត្តគោល-នយោបាយផ្អែកលើក្របខណ្ឌទស្សនទាននៃ "រចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ" រួមមាន សេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ បច្ចេកវិទ្យាគាំទ្រ និងគោលនយោបាយជំរុញ។

## II. ទស្សនៈវិស័យ

ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ មានទស្សនៈវិស័យក្នុងការបណ្តុះបរិវត្តកម្មឌីជីថលក្នុងវិស័យធនាគារ ស្របតាមរបៀបវារៈរបស់រាជរដ្ឋាភិបាលស្តីពី ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា។

## III. ទិសដៅ

ទិសដៅនៃផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុមានដូចខាងក្រោម៖

១. ដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងបទប្បញ្ញត្តិជាប្រព័ន្ធដែលផ្តល់នូវតុល្យភាពរវាងហានិភ័យ និងកាលានុវត្តភាព

២. សម្រួលដល់ការផ្តល់សេវា និងផលិតផលបច្ចេកវិទ្យាហិរញ្ញវត្ថុ និងគំរូធុរកិច្ចប្រកបដោយនវានុវត្តន៍ដែលមានប្រសិទ្ធភាពជាងមុន

៣. ជំរុញការប្រើប្រាស់សេវា និងផលិតផលបច្ចេកវិទ្យាហិរញ្ញវត្ថុឱ្យបានទូលំទូលាយដែលអាចប្រើប្រាស់បានក្នុងតម្លៃសមរម្យ ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។

## IV. វិសាលភាព

ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ មានវិសាលភាពគ្របដណ្តប់លើបច្ចេកវិទ្យាហិរញ្ញវត្ថុដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ធនាគារជាតិនៃកម្ពុជា។

# ជំពូក ២ សសរស្តម្ភបច្ចេកវិទ្យាហិរញ្ញវត្ថុ

ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុប្រើប្រាស់ក្របខណ្ឌទស្សនទាននៃ "រចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ" រៀបរៀងដោយធនាគារសម្រាប់ការទូទាត់អន្តរជាតិ (២០២០) ដើម្បីពិភាក្សាអំពីទិដ្ឋភាពបច្ចេកវិទ្យាហិរញ្ញវត្ថុនៅប្រទេសកម្ពុជា។ ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុផ្តោតសំខាន់លើសសរស្តម្ភសំខាន់ៗចំនួន ៣ រួមមាន៖ (១)សេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ (២)បច្ចេកវិទ្យាគាំទ្រ និង (៣)គោលនយោបាយជំរុញ។




## I. សសរស្តម្ភទី១៖ សេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ

សេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុជាច្រើន ត្រូវបានប្រើប្រាស់នៅក្នុងវិស័យហិរញ្ញវត្ថុ។ ដើម្បីឱ្យមានសង្គតភាព ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនេះប្រើប្រាស់បច្ចេកសព្ទរបស់ធនាគារសម្រាប់ការទូទាត់អន្តរជាតិ ដែលបានបែងចែកសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុជាក្រុមដូចខាងក្រោម៖ (១)ប្រាក់បញ្ញើនិងឥណទាន (២)ការគៀរគរដើមទុននិងប្រភពមូលនិធិផ្សេងៗទៀត (៣)ការគ្រប់គ្រងការជួញដូរទ្រព្យសកម្មនិងសេវាពាក់ព័ន្ធ (៤)សេវាផាត់ទាត់និងទូទាត់សងប្រាក់ (៥)ធានារ៉ាប់រង និង (៦)ទ្រព្យសកម្មគ្រីបតូ។ បច្ចេកសព្ទនៅក្នុងសសរស្តម្ភទី១ ត្រូវបានបង្ហាញដូចខាងក្រោម៖

### ១. ប្រាក់បញ្ញើ និងឥណទាន

ក. **សេវាធនាគារឌីជីថល៖** សំដៅលើគ្រឹះស្ថានទទួលប្រាក់បញ្ញើដែលជាសមាជិកនៃគម្រោងធានារ៉ាប់រងប្រាក់បញ្ញើ និងផ្តល់សេវាធនាគារជាចម្បងតាមរយៈបណ្តាញអេឡិចត្រូនិកជំនួសឱ្យសាខាជារូបវន្ត។

ខ. **ថ្នាលផ្តល់ឥណទានផ្អែកលើតារាងតុល្យការ៖** សំដៅលើសកម្មភាពផ្តល់ឥណទានធ្វើឡើងតាមរយៈថ្នាលបច្ចេកវិទ្យា (មិនធ្វើប្រតិបត្តិការដោយគ្រឹះស្ថានធនាគារ) ដែលប្រើប្រាស់តារាងតុល្យការផ្ទាល់ខ្លួនក្នុងដំណើរការធុរកិច្ចធម្មតា ដើម្បីធ្វើអន្តរការីយកម្មរវាងអ្នកខ្ចី និងអ្នកឱ្យខ្ចី។

គ. **ឥណទានក្រោដហ្វាន់ឌីង៖** សំដៅលើសកម្មភាពផ្តល់ឥណទាន ធ្វើឡើងតាមរយៈថ្នាលបច្ចេកវិទ្យា (មិនធ្វើប្រតិបត្តិការដោយគ្រឹះស្ថានធនាគារ) ដែលផ្គូផ្គងរវាងអ្នកខ្ចី និងអ្នកឱ្យខ្ចី។ កិច្ចសន្យាកម្ចីនីមួយៗត្រូវបានបង្កើតឡើងរវាងអ្នកខ្ចី និងអ្នកឱ្យខ្ចី ដោយថ្នាលបច្ចេកវិទ្យាមិនមានកាតព្វកិច្ចក្នុងការវាយតម្លៃ ឬបំប្លែងហានិភ័យនោះឡើយ។

## ២. ការកៀរគរដើមទុន និងប្រភពមូលនិធិផ្សេងៗទៀត

**មូលធនក្រោដហ្វាន់ឌីង៖** សំដៅលើសកម្មភាពដែលវិនិយោគិនផ្តល់មូលនិធិដល់ក្រុមហ៊ុនឯកជនក្នុងទម្រង់ជាមូលធន។ ថ្នាលបច្ចេកវិទ្យាហិរញ្ញវត្ថុនឹងផ្គូផ្គងវិនិយោគិនជាមួយក្រុមហ៊ុនដែលពួកគេចង់វិនិយោគ ដែលអនុញ្ញាតឱ្យពួកគេអាចចូលរួមក្នុងសកម្មភាពកៀរគរដើមទុនក្នុងដំណាក់កាលដំបូងសម្រាប់ការបង្កើតក្រុមហ៊ុនថ្មី និងក្រុមហ៊ុនផ្សេងទៀត។

## ៣. ការគ្រប់គ្រងការជួញទ្រព្យសកម្មនិងសេវាពាក់ព័ន្ធ

**ការផ្តល់ប្រឹក្សាដោយស្វ័យប្រវត្តិ៖** សំដៅលើការផ្តល់ប្រឹក្សាហិរញ្ញវត្ថុស្តីពីផលិតផលវិនិយោគដោយពុំមានអន្តរាគមន៍របស់មនុស្ស ឬមានតិចតួច និងពឹងផ្អែកលើបច្ចេកវិទ្យាដើម្បីធ្វើការចុះឈ្មោះអ្នកប្រើប្រាស់ និងការផ្តល់ប្រឹក្សាដោយស្វ័យប្រវត្តិ។

## ៤. សេវាផាត់ទាត់ និងទូទាត់សងប្រាក់

ក. **រូបិយវត្ថុអេឡិចត្រូនិក៖** សំដៅលើការចេញផ្សាយឧបករណ៍ទូទាត់ (រូបិយវត្ថុអេឡិចត្រូនិក) ក្នុងគោលបំណងសម្រួលដល់ប្រតិបត្តិការទូទាត់សងប្រាក់។

ខ. **សេវាទូទាត់សងប្រាក់ឌីជីថល៖** សំដៅលើអ្នកផ្តល់សេវាទូទាត់សងប្រាក់ឌីជីថលដែលប្រើប្រាស់បច្ចេកវិទ្យា ដើម្បីសម្រួលដល់ប្រតិបត្តិការទូទាត់សងប្រាក់ដូចជា ការផ្ទេរប្រាក់ផាត់ទាត់ ឬទូទាត់សមតុល្យតាមបែបឌីជីថលដោយមិនចាំបាច់ប្រើរូបិយវត្ថុរូបវន្ត។

## ៥. ធានារ៉ាប់រង

**បច្ចេកវិទ្យាធានារ៉ាប់រង៖** សំដៅលើគំរូធុរកិច្ចប្រកបដោយនវានុវត្តន៍ ដែលកំពុងលេចឡើងក្នុងផ្នែកសំខាន់ពីររបស់វិស័យធានារ៉ាប់រង (១)បណ្តាញចែកចាយព័ត៌មានធានារ៉ាប់រងដូចជាការប្រៀបធៀបផតថល និងជើងសារធានារ៉ាប់រងឌីជីថល និង (២)ការលក់ធានារ៉ាប់រង ដូចជាការលក់ធានារ៉ាប់រងតាមទូរស័ព្ទចល័ត តាមតម្រូវការ តាមការប្រើប្រាស់ឬពីបុគ្គលទៅបុគ្គល និងតាមប៉ារ៉ាម៉ែតធានារ៉ាប់រង។

## ៦. ទ្រព្យសកម្មគ្រីបតូ

**ទ្រព្យសកម្មគ្រីបតូ៖** សំដៅលើប្រភេទទ្រព្យសកម្មឯកជនដែលពឹងផ្អែកលើបច្ចេកវិទ្យាគ្រីបតូ និងបច្ចេកវិទ្យាឌីអិលធី ឬបច្ចេកវិទ្យាស្រដៀងគ្នាក្នុងការកំណត់តម្លៃទ្រព្យសកម្មនោះ។

## II. សសរស្តម្ភទី២៖ បច្ចេកវិទ្យាគាំទ្រ

បច្ចេកវិទ្យាគាំទ្រមួយចំនួន ត្រូវបានប្រើសម្រាប់នវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងវិស័យហិរញ្ញវត្ថុ ដូចជា៖ (១)សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (២)បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (៣)បច្ចេកវិទ្យាម៉ាស៊ីនស្វ័យសិក្សា (៤)ការកំណត់អត្តសញ្ញាណនិងការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវផ្អែកលើជីវមាត្រ (៥) បច្ចេកវិទ្យាក្លោដ និង (៦)បច្ចេកវិទ្យាឌីអិលធី។ ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាគាំទ្រ បាននាំឱ្យមានភាពរីកចម្រើនផ្នែកកម្មវិធីសម្រាប់គោលបំណងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុនីមួយៗ ដូចជា (១)សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ ដើម្បីឱ្យគ្រឹះស្ថានមិនមែនធនាគារអាចចូលប្រើប្រាស់ទិន្នន័យអ្នកប្រើប្រាស់របស់ធនាគារប្រកបដោយសុវត្ថិភាព (២)បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិតនិងម៉ាស៊ីនស្វ័យសិក្សាសម្រាប់ការផ្តល់ប្រឹក្សា ការផ្តល់និទ្ទេសឥណទាន និងការជួញដូរដោយស្វ័យប្រវត្តិ (៣)បច្ចេកវិទ្យាជីវមាត្រសម្រាប់ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវរបស់អ្នកប្រើប្រាស់ជាឌីជីថល (៤)បច្ចេកវិទ្យាក្លោដសម្រាប់ទទួលបានទិន្នន័យធំ ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ ការរក្សាទុក ការគាំពារ និងកិច្ចដំណើរការព័ត៌មានហិរញ្ញវត្ថុ និង (៥)បច្ចេកវិទ្យាឌីអិលធី ប្រើសម្រាប់មូលដ្ឋានទិន្នន័យសុវត្ថិភាពនៃព័ត៌មានហិរញ្ញវត្ថុដែលមានភាពរឹងមាំទប់ទល់នឹងការវាយប្រហារតាមបច្ចេកវិទ្យា បង្កើនប្រសិទ្ធភាព និងកាត់បន្ថយការចំណាយ។ បច្ចេកសព្ទនៅក្នុងសសរស្តម្ភទី២ មានដូចខាងក្រោម៖

១. **សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ៖** សំដៅលើសំណុំនៃវិធាន និងបរិច្ឆិន្នភាពដែលត្រូវអនុវត្តសម្រាប់កម្មវិធីកុំព្យូទ័រ ដើម្បីឱ្យកម្មវិធីកុំព្យូទ័រផ្សេងៗគ្នាអាចទំនាក់ទំនងគ្នាបានបង្កើតជាសន្ទានកម្មរវាងកម្មវិធីកំព្យូទ័រផ្សេងគ្នា និងសម្រួលដល់ដំណើរការអន្តរកម្មរវាងគ្នា។

២. **បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត៖** សំដៅលើប្រព័ន្ធព័ត៌មានវិទ្យា ដែលអាចអនុវត្តមុខងារបានដូចសមត្ថភាពមនុស្ស។ បញ្ញាសិប្បនិម្មិតអាចសួរសំណួរ ស្វែងរកនិងធ្វើតេស្តសាកល្បងសម្មតិកម្ម និងធ្វើការសម្រេចចិត្តដោយស្វ័យប្រវត្តិផ្អែកលើការវិភាគទិន្នន័យទូលំទូលាយ និងសម្បូរបែប។

៣. **បច្ចេកវិទ្យាម៉ាស៊ីនស្វ័យសិក្សា៖** សំដៅលើវិធីសាស្ត្រក្នុងការរៀបចំវិធានដោះស្រាយបញ្ហា និងធ្វើស្វ័យអភិវឌ្ឍតាមរយៈបទពិសោធន៍។ ក្បួនដោះស្រាយរបស់ម៉ាស៊ីនស្វ័យសិក្សា ផ្តល់សមត្ថភាពឱ្យកុំព្យូទ័រអាចស្វែងយល់ និងបំពេញការងារដែលបានកំណត់ឱ្យ។ បច្ចេកវិទ្យានេះក៏អនុញ្ញាតឱ្យកុំព្យូទ័រសិក្សា និងបង្កើតវិធានដោះស្រាយ និងព្យាករណ៍ដោយផ្អែកលើទិន្នន័យដែលមានស្រាប់ និងបទពិសោធន៍កន្លងមក។ ម៉ាស៊ីនស្វ័យសិក្សា ជាផ្នែកមួយនៃបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត។

៤. **បច្ចេកវិទ្យាជីវមាត្រសម្រាប់ការកំណត់ និងផ្ទៀងផ្ទាត់អត្តសញ្ញាណ៖** សំដៅលើបច្ចេកវិទ្យាក្នុងការបញ្ជាក់អត្តសញ្ញាណបុគ្គលដោយស្វ័យប្រវត្តិ ផ្អែកលើលក្ខណៈជីវសាស្ត្រ និងអាកប្បកិរិយារបស់ពួកគេ។ បច្ចេកវិទ្យានេះគ្របដណ្តប់វិធីសាស្ត្រច្រើនប្រភេទក្នុងការប្រើប្រាស់លក្ខណៈពិសេសផ្សេងៗគ្នារបស់បុគ្គលម្នាក់ៗ ដើម្បីកំណត់អត្តសញ្ញាណ និងការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវរបស់ពួកគេ។ លក្ខណៈពិសេសដែលអាចប្រើប្រាស់ ដើម្បីកំណត់សុពលភាព និងភាពត្រឹមត្រូវនៃអត្តសញ្ញាណរបស់បុគ្គលទាំងនេះមានដូចជា ស្នាមក្រយៅដៃ ប្រស្រីភ្នែក ដៃ មុខ សំលេង ឬហត្ថលេខា។

៥. **បច្ចេកវិទ្យាក្លោដ៖** សំដៅលើការប្រើប្រាស់បណ្ដាញអនឡាញ "ក្លោដ" របស់ប្រតិបត្តិករផ្តល់សេវា ដើម្បីបង្កើនវិសាលភាព និងភាពបត់បែននៃសមត្ថភាពកុំព្យូទ័ររបស់គ្រឹះស្ថាន។ បច្ចេកវិទ្យានេះអាចផ្តល់ភាពងាយស្រួលក្នុងការចូលប្រើប្រាស់ធនធានកុំព្យូទ័ររួមតាមតម្រូវការ (ដូចជា បណ្តាញ ម៉ាស៊ីនមេ បរិក្ខារផ្ទុកទិន្នន័យ កម្មវិធីកុំព្យូទ័រ និងសេវាកម្មផ្សេងៗ) យ៉ាងឆាប់រហ័ស ដោយត្រូវការការគាំទ្រតិចបំផុតពីប្រតិបត្តិករផ្តល់សេវា។

៦. **បច្ចេកវិទ្យាឌីអិលធី៖** សំដៅលើមធ្យោបាយនៃការកត់ត្រាព័ត៌មានតាមរយៈ Distributed Ledger ដែលជាការចម្លងទិន្នន័យឌីជីថលច្រើនដងទៅកាន់ទីតាំងជាច្រើនផ្សេងៗគ្នា។ បច្ចេកវិទ្យានេះអនុញ្ញាតឱ្យ Node ទាំងឡាយដែលនៅក្នុងបណ្តាញអាចដាក់ស្នើបញ្ជាក់សុពលភាព និងកត់ត្រាដោយសុវត្ថិភាពនូវរាល់ការផ្លាស់ប្តូរ (ឬធ្វើបច្ចុប្បន្នភាព) ទៅក្នុង Synchronized Ledger ដែលត្រូវបានចែកចាយនៅតាមបណ្តាញរបស់ Node ទាំងអស់។

## III. សសរស្តម្ភទី៣៖ គោលនយោបាយជំរុញ

មូលដ្ឋានគ្រឹះនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុពឹងផ្អែកលើស្ថិរភាពនៃកំណើន ដែលគាំទ្រដោយគោលនយោបាយជំរុញ។ ជាសកល រដ្ឋាភិបាលបានដាក់ចេញគោលនយោបាយ និងបទប្បញ្ញត្តិបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីជាមូលដ្ឋានសម្រាប់ហេដ្ឋារចនាសម្ព័ន្ធឌីជីថលចាំបាច់ ក្នុងការជំរុញការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដូចជា៖ (១)អត្តសញ្ញាណឌីជីថល (២)ក្របខណ្ឌធនាគារបើកចំហ (៣)ក្របខណ្ឌការពារទិន្នន័យ (៤)ក្របខណ្ឌសន្តិសុខសាយប័រ និង (៥)គំនិតផ្តួចផ្តើមជំរុញនវានុវត្តន៍។ គោលនយោបាយជំរុញ ត្រូវបានអនុម័តដាក់ឱ្យអនុវត្តទាំងកម្រិតថ្នាក់ជាតិ ឬកម្រិតវិស័យហិរញ្ញវត្ថុ អាស្រ័យលើគោលដៅគោលនយោបាយ។ បច្ចេកសព្ទនៅក្នុងសសរស្តម្ភទី៣ មានដូចខាងក្រោម៖

១. **ប្រព័ន្ធអត្តសញ្ញាណឌីជីថល៖** សំដៅលើប្រព័ន្ធដែលគ្របដណ្តប់ដំណើរការនៃការបញ្ជាក់អត្តសញ្ញាណ ឬការចុះឈ្មោះ និងការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ។ ការបញ្ជាក់អត្តសញ្ញាណ និងការចុះឈ្មោះអាចធ្វើឡើងជាលក្ខណៈឌីជីថល ឬរូបវន្ត (ដោយប្រើប្រាស់ឯកសារ) ឬការរួមបញ្ចូលគ្នា ប៉ុន្តែការភ្ជាប់រវាងព័ត៌មានបញ្ជាក់អត្តសញ្ញាណ ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ និងការរួមបញ្ចូលគ្នាត្រូវធ្វើឡើងជាឌីជីថល។

២. **ក្របខណ្ឌធនាគារបើកចំហ៖** សំដៅលើការចែករំលែក និងប្រើប្រាស់ទិន្នន័យដោយមានការអនុញ្ញាតពីអ្នកប្រើប្រាស់ ពីសំណាក់គ្រឹះស្ថានធនាគារជាមួយតតិយភាគី ដើម្បីអភិវឌ្ឍកម្មវិធី និងសេវាកម្មដែលផ្តល់នូវការទូទាត់សងប្រាក់ភ្លាមៗ និងផ្តល់ជម្រើសហិរញ្ញវត្ថុកាន់តែមានតម្លាភាពសម្រាប់ម្ចាស់គណនី និងទីផ្សារ។ល។

៣. **ក្របខណ្ឌការពារទិន្នន័យ៖** សំដៅលើប្រព័ន្ធច្បាប់ដែលតម្រូវឱ្យមានការព្រមព្រៀងពីអ្នកប្រើប្រាស់មុនពេលទិន្នន័យរបស់ពួកគេ (ដូចជា ទីតាំង ព័ត៌មានហិរញ្ញវត្ថុ ឬសុខភាព) អាចត្រូវបានប្រមូល ប្រើប្រាស់ ឬចែករំលែក។ នៅក្នុងប្រទេសដែលមានក្របខណ្ឌការពារទិន្នន័យ គោលបំណងនៃការប្រមូល និងប្រើប្រាស់ទិន្នន័យគួរតែត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ក្របខណ្ឌទូលំទូលាយបន្ថែមទៀត ក៏បង្កើតឱ្យមានសិទ្ធិថ្មីៗសម្រាប់ឯកត្តជនដូចជា ភាពងាយស្រួល

រក្សាទុកនិងបន្លាស់ទីនៃទិន្នន័យ សិទ្ធិមិនបង្ហាញទិន្នន័យ ឬសិទ្ធិលុបចោលទិន្នន័យ។

៤. **ក្របខណ្ឌសន្តិសុខសាយប័រៈ** សំដៅលើបទប្បញ្ញត្តិថ្នាក់ជាតិនិង/ឬតាមវិស័យ គោលការណ៍ណែនាំ និងការត្រួតពិនិត្យដែលមានគោលដៅរួម ក្នុងការបង្កើតក្របខណ្ឌសន្តិសុខសាយប័រសម្រាប់សម្រួលដល់ស្ថាប័ន និងគ្រឹះស្ថានក្នុងការកាត់បន្ថយហានិភ័យសាយប័រ និងការឆ្លើយតប និងការស្តារឡើងវិញពីការវាយប្រហារតាមសាយប័រប្រកបដោយប្រសិទ្ធភាព។ វិធានការបទប្បញ្ញត្តិទាំងនេះត្រូវបានដកស្រង់ចេញពីក្របខណ្ឌសន្តិសុខសាយប័រ និងការណែនាំផ្សេងៗជាច្រើនដែលរៀបចំដោយស្ថាប័នជាតិ អន្តរជាតិ ទាំងវិស័យសាធារណៈ និងឯកជន។ ការកសាងក្របខណ្ឌសន្តិសុខសាយប័រ ចាប់ផ្តើមពីការតម្រូវឱ្យគ្រឹះស្ថានហិរញ្ញវត្ថុរៀបចំចងក្រងកម្មវិធី ឬគោលនយោបាយស្តីពី សន្តិសុខសាយប័រ ព្រមទាំងកំណត់អត្តសញ្ញាណព័ត៌មានសំខាន់ៗដែលចាំបាច់ត្រូវការពារ។ ការធ្វើតេស្តសាកល្បងលើភាពងាយរងគ្រោះ និងភាពធន់របស់គ្រឹះស្ថានទប់ទល់នឹងហានិភ័យសាយប័រ ក៏ដូចជាការរាយការណ៍អំពីព្រឹត្តិការណ៍សាយប័រជាលក្ខខណ្ឌតម្រូវចាំបាច់។ ការបែងចែកតួនាទីនិងភារកិច្ចនៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុ និងការធានានូវគុណវុឌ្ឍន៍របស់តតិយភាគីក៏ជាសមាសធាតុសំខាន់នៅក្នុងលក្ខខណ្ឌតម្រូវនានានៃក្របខណ្ឌសន្តិសុខសាយប័រ។

៥. **ឧក្រិដ្ឋកម្មសាយប័រៈ** សំដៅលើករណីដែលប្រព័ន្ធកុំព្យូទ័រឬសមាសធាតុនៃប្រព័ន្ធកុំព្យូទ័រ ជាកម្មវត្ថុនៃបទឧក្រិដ្ឋ (ការលួចព័ត៌មាន ការលួចបន្លំតាមសារអេឡិចត្រូនិក ការផ្ញើសារអេឡិចត្រូនិកឥតបានការ) ឬជាប្រភពសម្របសម្រួលបទឧក្រិដ្ឋ (ដូចជាការលួចព័ត៌មាន ឬលួចប្រាក់ជាដើម)។

៦. **ភាពធន់សាយប័រៈ** សំដៅលើសមត្ថភាពនៃហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុក្នុងការគិតទុកជាមុន ទប់ទល់ ទប់ស្កាត់ ស្រោចស្រង់ឡើងវិញភ្លាមៗពីការវាយប្រហារតាមសាយប័រ។

៧. **ហានិភ័យសាយប័រៈ** សំដៅលើប្រូបាប៊ីលីតេរួមបញ្ចូលគ្នានៃព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងដែនព័ត៌មាន កុំព្យូទ័រ និងធនធានទំនាក់ទំនងរបស់ស្ថាប័ន និងផលវិបាកនៃព្រឹត្តិការណ៍នោះសម្រាប់ស្ថាប័ន។

៨. **គំនិតផ្តួចផ្តើមជំរុញនវានុវត្តន៍ៈ** គំនិតផ្តួចផ្តើមជំរុញនវានុវត្តន៍ បង្កើតឡើងដោយអាជ្ញាធរត្រួតពិនិត្យដែលផ្តល់ការគាំទ្រ ការប្រឹក្សា ឬការណែនាំដល់អង្គភាពដែលនៅក្រោមបទប្បញ្ញត្តិ ឬមិននៅក្រោមបទប្បញ្ញត្តិក្នុងការរៀបចំក្របខណ្ឌបទប្បញ្ញត្តិ ឬកំណត់គោលការណ៍ត្រួតពិនិត្យ ឬបញ្ហាច្បាប់និងការព្រួយបារម្ភផ្សេងៗ។ គំនិតផ្តួចផ្តើមជំរុញនវានុវត្តន៍មាន ៣ ប្រភេទសំខាន់ៗ ដូចជា មជ្ឈមណ្ឌលនវានុវត្តន៍ បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ និងអ្នកជំរុញនវានុវត្តន៍។

៩. **មជ្ឈមណ្ឌលនវានុវត្តន៍ៈ** សំដៅលើអ្នកសម្របសម្រួលនវានុវត្តន៍ បង្កើតឡើងដោយអាជ្ញាធរត្រួតពិនិត្យដែលផ្តល់ការគាំទ្រ ការប្រឹក្សា ឬការណែនាំដល់អង្គភាពដែលនៅក្រោមបទប្បញ្ញត្តិ ឬមិននៅក្រោមបទប្បញ្ញត្តិក្នុងការរៀបចំក្របខណ្ឌបទប្បញ្ញត្តិ ឬកំណត់គោលការណ៍ត្រួតពិនិត្យ ឬបញ្ហាច្បាប់ និងការព្រួយបារម្ភផ្សេងៗ។

**១០.បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ៖** សំដៅលើបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុដែលស្ថិតក្រោមការគ្រប់គ្រង ពេលខ្លះមានលក្ខណៈជាការលើកលែង និងការសម្រួលផ្នែកបទប្បញ្ញត្តិ តាមរយៈការប្រើឆន្ទានុសិទ្ធិរបស់អាជ្ញាធរត្រួតពិនិត្យដែលគាំទ្រដោយច្បាប់។ បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុនេះ អាចពាក់ព័ន្ធទៅនឹងការដាក់កំហិតផ្សេងៗលើប្រតិបត្តិការរបស់គ្រឹះស្ថាន (ដូចជា ការរឹតត្បិតលើពេលវេលាដែលគ្រឹះស្ថានអាចធ្វើប្រតិបត្តិការនៅក្នុងការសាកល្បង)។

**១១.អ្នកជំរុញនវានុវត្តន៍៖** សំដៅលើកិច្ចសម្របសម្រួលភាពជាដៃគូរវាងអ្នកផ្តល់បច្ចេកវិទ្យាហិរញ្ញវត្ថុ និងធនាគារកណ្តាល ឬអាជ្ញាធរត្រួតពិនិត្យ និងវិស័យឯកជន ដើម្បីអភិវឌ្ឍគំនិតផ្តួចផ្តើមសេវា ឬផលិតផលថ្មីៗ ដែលអាចពាក់ព័ន្ធនឹងការផ្តល់មូលនិធិ និង/ឬការយល់ព្រម ឬការឯកភាពពីអាជ្ញាធរពាក់ព័ន្ធ សម្រាប់ការអនុវត្តនាពេលអនាគត។

# ជំពូក ៣ ស្ថានភាពបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា

បច្ចុប្បន្ន វិស័យហិរញ្ញវត្ថុនៅប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ គិតត្រឹមដំណាច់ឆ្នាំ២០២០ ប្រព័ន្ធធនាគារមានធនាគារពាណិជ្ជចំនួន ៥២ ធនាគារឯកទេសចំនួន ១៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៨១ ដែលរួមបញ្ចូលទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៦ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន ១៥ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន ២៨ និងអ្នកដំណើរការតតិយភាគីចំនួន ៤។ តាមរយៈការអភិវឌ្ឍនេះ គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់បាននិងកំពុងដាក់ឱ្យប្រើប្រាស់សេវាធនាគារ ជាពិសេសសេវាទូទាត់សងប្រាក់តាមរយៈថ្នាលឌីជីថលដែលរួមមាន សេវាធនាគារអ៊ីនធឺណិត សេវាធនាគារចល័ត ការទូទាត់ចល័តតាមរយៈឃ្យូអរកូត។ ការរីកចម្រើននៃហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក៏ដូចជាការប្រើប្រាស់ទូរស័ព្ទចល័ត បានជំរុញឱ្យសេវាទូទាត់សងប្រាក់មានប្រជាប្រិយភាពខ្លាំង ដោយសារមានភាពងាយស្រួល តម្លៃសមរម្យ និងសុវត្ថិភាព។

## I. ទិដ្ឋភាពទូទៅនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ

ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលដំបូង ប៉ុន្តែមាននិន្នាការកើនឡើងជាបណ្តើរៗ ក្នុងនោះនវានុវត្តន៍ថ្មីៗត្រូវបានសង្កេតឃើញនៅក្នុងវិស័យធនាគារ។ បច្ចេកវិទ្យាហិរញ្ញវត្ថុមួយចំនួនធំធ្វើប្រតិបត្តិការពាក់ព័ន្ធសេវាទូទាត់សងប្រាក់ឌីជីថល និងការផ្ទេរប្រាក់ឆ្លងដែន។ ហិរញ្ញប្បទានបច្ចេកវិទ្យាហិរញ្ញវត្ថុ និងការផ្តល់និទ្ទេសឥណទានក៏ដើរតួយ៉ាងសំខាន់ក្នុងការវាយតម្លៃភាពត្រឹមត្រូវរបស់អ្នកប្រើប្រាស់ និងជួយសម្រួលដល់ការផ្តល់ឥណទានដោយរលូន។ បន្ថែមពីនេះ ប្រតិបត្តិករផ្តល់សេវាសូហ្វវែរក៏បានចូលរួមអភិវឌ្ឍបច្ចេកវិទ្យាសម្រាប់សហគ្រាសដូចជា ប្រព័ន្ធធនាគារស្នូល ការគ្រប់គ្រងកិច្ចបញ្ជិកាគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ វិក្កយបត្រ និងសារពើភ័ណ្ឌ។

ទិដ្ឋភាពរួមនៃធុរកិច្ចថ្មីនៅកម្ពុជា មានប្រតិបត្តិករផ្តល់បច្ចេកវិទ្យាប្រមាណជាង ៣០០ ដែលកំពុងដំណើរការក្នុងដំណាក់កាលផ្សេងៗគ្នា ក្នុងនោះបច្ចេកវិទ្យាហិរញ្ញវត្ថុ និងបច្ចេកវិទ្យាផ្នែកឌីជីថលមេឌៀ មានចំនួនប្រតិបត្តិករច្រើនជាងគេ។ ចំណែកប្រតិបត្តិករធុរកិច្ចថ្មីផ្នែកកសិកម្ម អប់រំ និងសុខាភិបាលមានចំនួនតិចតួចនៅឡើយ។ ធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ មានចំនួនច្រើនជាង ៥០ ប្រតិបត្តិករ ដែលភាគច្រើនជាគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។ សម្រាប់ពេលអនាគត ចំនួនប្រតិបត្តិករធុរកិច្ចថ្មីរំពឹងទុកថា នឹងមានការកើនឡើងសម្រាប់វិស័យបច្ចេកវិទ្យាធានារ៉ាប់រង បច្ចេកវិទ្យានិយ័តកម្ម និងធនាគារឌីជីថល។




ប្រភព៖ ប្រព័ន្ធអេកូឡូស៊ីនៃបច្ចេកវិទ្យានៅកម្ពុជារៀបចំឡើងដោយស្ថាប័នដៃគូយុទ្ធសាស្ត្រមេគង្គ




ប្រភព៖ បរិយាកាសនៃបច្ចេកវិទ្យាហិរញ្ញវត្ថុរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា (រូបភាពខាងលើគ្រាន់តែជ្រើសរើសយកមកជាឧទាហរណ៍សម្រាប់បង្ហាញប៉ុណ្ណោះ)

## II. ក្របខណ្ឌគតិយុត្តពាក់ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ

ចាប់តាំងពីឆ្នាំ២០១០ បទប្បញ្ញត្តិគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុត្រូវបានអនុម័តជាបន្តបន្ទាប់។ ធនាគារជាតិនៃកម្ពុជាបានដើរតួយ៉ាងសំខាន់ជាអាជ្ញាធរគ្រប់គ្រងនិងដាក់បទប្បញ្ញត្តិលើវិស័យធនាគារនិងហិរញ្ញវត្ថុ តាមរយៈការរៀបចំ និងដាក់ចេញក្របខណ្ឌបទប្បញ្ញត្តិរឹងមាំ និងប្រកបដោយប្រសិទ្ធភាព ចំណែកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានតួនាទីជាអាជ្ញាធរគ្រប់គ្រងគ្រឹះស្ថាន

មិនមែនធនាគារ។ បច្ចេកវិទ្យាហិរញ្ញវត្ថុត្រូវអនុលោមតាមបទប្បញ្ញត្តិនានាជាធរមាន ដែលដាក់ចេញដោយធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នមានសមត្ថកិច្ចផ្សេងៗទៀត អាស្រ័យលើប្រភេទនៃសកម្មភាពធុរកិច្ចរបស់ខ្លួន។

## ១. បទប្បញ្ញត្តិសម្រាប់រូបិយវត្ថុអេឡិចត្រូនិក និងសេវាទូទាត់សងប្រាក់ឌីជីថល

- **ប្រកាសស្តីពី អ្នកដំណើរការតតិយភាគី៖** កាលពីឆ្នាំ២០១០ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសស្តីពី អ្នកដំណើរការតតិយភាគី ដើម្បីគ្រប់គ្រង និងដាក់ឱ្យប្រើប្រាស់នីតិវិធីលើការផ្តល់អាជ្ញាបណ្ណដល់បុគ្គលស្របច្បាប់ដែលផ្តល់សេវាទូទាត់សងប្រាក់នៅកម្ពុជា។ គោលបំណងនៃប្រកាសនេះ ដើម្បីផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រគល់សិទ្ធិមួយផ្នែក ឬច្រើនផ្នែកនៃប្រតិបត្តិការសេវាទូទាត់សងប្រាក់ឱ្យអ្នកដំណើរការតតិយភាគីមួយ ឬច្រើន ដូចបានព្រមព្រៀងគ្នារវាងគ្រឹះស្ថានធនាគារ និងអ្នកដំណើរការតតិយភាគី។ អ្នកដំណើរការតតិយភាគីត្រូវទទួលបានការធានាដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីផ្តល់សេវាទូទាត់សងប្រាក់ទៅកាន់សាធារណជនជំនួសឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។
- **ប្រកាសស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់៖** កាលពីឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដើម្បីគ្រប់គ្រង និងដាក់ឱ្យប្រើប្រាស់នីតិវិធីលើការផ្តល់អាជ្ញាបណ្ណដល់បុគ្គលស្របច្បាប់ដែលផ្តល់សេវាទូទាត់សងប្រាក់នៅកម្ពុជា។ គោលបំណងរបស់ប្រកាសនេះ ដើម្បីធានាសុវត្ថិភាព និងភាពរឹងមាំនៃសេវាទូទាត់សងប្រាក់ ជំរុញនវានុវត្តន៍ និងការប្រកួតប្រជែង និងលើកកម្ពស់ទំនុកចិត្តរបស់សាធារណជនមកលើសេវាទូទាត់សងប្រាក់ ក៏ដូចជាគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យទូទាត់សងប្រាក់ និងផ្ទេរប្រាក់ ដោយអនុញ្ញាតឱ្យគ្រឹះស្ថានទាំងនោះដំណើរការដោយឯករាជ្យមិនពឹងផ្អែកលើគ្រឹះស្ថានធនាគារ។ ក្រោមវិសាលភាពនៃប្រកាសនេះ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់អាចរក្សាកិច្ចសហការជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាតភ្ជាប់ផ្ទាល់ជាមួយហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់។ ប្រកាសនេះក៏មានចែងអំពីវិធានការដើម្បីធានាសុវត្ថិភាព និងភាពរឹងមាំនៃសេវាទូទាត់សងប្រាក់ ដោយចែងបញ្ញត្តិពាក់ព័ន្ធការរក្សាស្ថិរភាព និងសុចរិតភាពដោយផ្តោតលើបញ្ហាសំខាន់ៗដូចជា សុវត្ថិភាពមូលនិធិ ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ហានិភ័យប្រតិបត្តិការ និងកិច្ចការពារអ្នកប្រើប្រាស់។

## ២. បទប្បញ្ញត្តិសម្រាប់មូលធនក្រោដហ្វាន់ឌីង

មូលធនក្រោដហ្វាន់ឌីងនៅកម្ពុជា ស្ថិតនៅក្រោមច្បាប់គ្រប់គ្រងស្តីពី ការបោះផ្សាយ និងជួញដូរមូលបត្រមហាជន ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ និងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ ស្តីពី ការទទួលពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនថែរក្សា

ទ្រព្យសម្បត្តិជំនួស ក្រុមហ៊ុនចែកចាយទិញ-លក់ត្រលប់មកវិញ ឬទូទាត់សងក្រុមហ៊ុនអភិបាលមូលនិធិ ភ្នាក់ងារគ្រប់គ្រងមូលនិធិ ភ្នាក់ងារក្រោជហ្វាន់ឌីង និងភ្នាក់ងារចែកចាយលក់មូលនិធិ។ ដោយសារប្រតិបត្តិការទាំងអស់នេះពាក់ព័ន្ធនឹងវិស័យមូលបត្រ គ្រឹះស្ថានដែលផ្តល់សេវាប្រភេទនេះត្រូវស្ថិតក្រោមដែនសមត្ថកិច្ចរបស់គណៈកម្មការមូលបត្រកម្ពុជា។ ទាំងគ្រឹះស្ថានចេញផ្សាយមូលបត្រ និងបច្ចេកវិទ្យាហិរញ្ញវត្ថុពាក់ព័ន្ធត្រូវបំពេញឱ្យបានគ្រប់គ្រាន់តាមលក្ខខណ្ឌបទប្បញ្ញត្តិមុននឹងចាប់ផ្តើមប្រតិបត្តិការមូលធនក្រោជហ្វាន់ឌីងនៅប្រទេសកម្ពុជា។

## ៣. បទប្បញ្ញត្តិសម្រាប់បច្ចេកវិទ្យាធានារ៉ាប់រង

រាល់សកម្មភាពសេវាធានារ៉ាប់រងទាំងអស់ រួមទាំងបច្ចេកវិទ្យាធានារ៉ាប់រងនៅកម្ពុជា ត្រូវបានកំណត់ដោយច្បាប់ស្តីពីការធានារ៉ាប់រង ដែលត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤។ ដោយសារបច្ចេកវិទ្យាធានារ៉ាប់រងផ្តល់សេវាពាក់ព័ន្ធការធានារ៉ាប់រង ហេតុនេះត្រូវស្ថិតក្រោមដែនសមត្ថកិច្ចរបស់អាជ្ញាធរត្រួតពិនិត្យគ្រឹះស្ថានមិនមែនធនាគារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ លក្ខណៈគតិយុត្តរវាងបច្ចេកវិទ្យាធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងទូទៅពុំមានភាពខុសគ្នា ដែលត្រូវស្ថិតនៅក្រោមលក្ខខណ្ឌដូចគ្នា ដើម្បីអាចធ្វើប្រតិបត្តិការស្របច្បាប់នៅប្រទេសកម្ពុជា។

## ៤. ច្បាប់ស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា ត្រូវបានកំណត់ដោយច្បាប់ស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩។ ច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក ចែងពីបទប្បញ្ញត្តិក្នុងការគ្រប់គ្រងសកម្មភាពអ្នកផ្តល់សេវាពាណិជ្ជកម្មអេឡិចត្រូនិក និងយថាភូតភាព សុក្រឹតភាព និងភាពអាចជឿទុកចិត្តបាននៃទម្រង់អេឡិចត្រូនិកក្នុងគោលបំណងជំរុញការធ្វើពាណិជ្ជកម្មអេឡិចត្រូនិកប្រកបដោយសុវត្ថិភាព លើកកម្ពស់ទំនុកចិត្តរបស់សាធារណជន និងសម្រួលដល់ការបំពេញឯកសារជាទម្រង់អេឡិចត្រូនិក តាមរយៈការប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកដែលអាចជឿទុកចិត្តបាននៅប្រទេសកម្ពុជា។

## ៥. ច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់

ច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់ ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ ២០១៩។ ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់នេះ ត្រូវបានបង្កើតឡើងដើម្បីធានាឱ្យមានកិច្ចការពារអ្នកប្រើប្រាស់ និងចូលរួមលើកកម្ពស់ការប្រកួតប្រជែងដោយសុចរិត។ លើសពីនេះ ច្បាប់នេះក៏បានកំណត់វិធាន និងយន្តការនានា ដើម្បីចូលរួមចំណែកបង្កើតបរិយាកាសធុរកិច្ចដែលក្នុងនោះសិទ្ធិនិងផលប្រយោជន៍របស់អ្នកប្រើប្រាស់ត្រូវបានការពារ។ ការធ្វើធុរកិច្ចត្រូវបានធ្វើឡើងជាមួយនឹងការប្រកួតប្រជែងដោយសុចរិត ហើយអ្នកប្រើប្រាស់និងពាណិជ្ជករអាចធ្វើសកម្មភាពជាមួយគ្នាដោយមានទំនុកចិត្ត។ ច្បាប់នេះអនុវត្តចំពោះបុគ្គលទាំងឡាយណាដែលធ្វើធុរកិច្ចទោះបីរកប្រាក់ចំណេញ ឬមិនរកប្រាក់ចំណេញក្តី រួមទាំង ការលក់ទំនិញឬសេវាផ្សេងៗ ឬសិទ្ធិប្រត្យក្សលើអចលនទ្រព្យឱ្យអ្នកប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានបទប្បញ្ញត្តិដោយឡែកដែលចែងផ្សេងពីនេះ។

## III. ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ដែលគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ

ប្រព័ន្ធទូទាត់សងប្រាក់បានរួមចំណែកយ៉ាងសំខាន់ ក្នុងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការផ្ដល់នូវហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ដើម្បីសម្រួលដល់ប្រតិបត្តិការផ្ទេរប្រាក់ ការទូទាត់ចំពោះការទិញ-លក់ទំនិញនិងសេវា និងការជួញដូរនៅលើទីផ្សារហិរញ្ញវត្ថុជាដើម។ លើសពីនេះ ប្រព័ន្ធទូទាត់សងប្រាក់ក៏បានរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងការអភិវឌ្ឍសេវា និងឧបករណ៍ទូទាត់សងប្រាក់ប្រកបដោយនវានុវត្តន៍ ដែលមានតម្លៃសមរម្យ និងមានលក្ខណៈទូលំទូលាយ ផ្ដល់លទ្ធភាពឱ្យប្រជាជននៅតាមជនបទអាចប្រើប្រាស់សេវាទូទាត់សងប្រាក់ តាមរយៈសេវាហិរញ្ញវត្ថុផ្លូវការ សំដៅចូលរួមកាត់បន្ថយភាពក្រីក្រ និងវិសមភាពសង្គម។ អាស្រ័យហេតុនេះ ការអភិវឌ្ឍ និងការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ត្រូវបានធនាគារជាតិនៃកម្ពុជាចាត់ទុកជាការងារអាទិភាព។ ស្របពេលនៃការរីកចម្រើននៃបច្ចេកវិទ្យា ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់ តាមរយៈកំណើននៃការដាក់ឱ្យប្រើនូវឧបករណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ។ កំណើននៃការដាក់ឱ្យប្រើនូវឧបករណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុនេះ បានធ្វើឱ្យប្រព័ន្ធទូទាត់សងប្រាក់ក្លាយជាធាតុសំខាន់មួយក្នុងប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុនៅប្រទេសកម្ពុជា។ បច្ចុប្បន្ន ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់និងសេវា ព្រមទាំងឧបករណ៍ទូទាត់ប្រកបដោយនវានុវត្តន៍ត្រូវបានដាក់ឱ្យប្រើប្រាស់ជាបន្តបន្ទាប់ ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃការទូទាត់សងប្រាក់នៅប្រទេសកម្ពុជា។ ដោយពិនិត្យឃើញពីសារៈសំខាន់នេះ ធនាគារជាតិនៃកម្ពុជាបានប្រើប្រាស់បច្ចេកវិទ្យា ដើម្បីធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ តាមរយៈការដាក់ឱ្យដំណើរការហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ជាច្រើន រួមមាន ប្រព័ន្ធទូទាត់តម្លៃធំ ប្រព័ន្ធទូទាត់រាយ ហើយថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធបាគង ដើម្បីជំរុញការប្រើប្រាស់សេវាទូទាត់សងប្រាក់ និងជំរុញឱ្យបុគ្គល គ្រួសារ និងសហគ្រាស អាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុឌីជីថលបានកាន់តែប្រសើរជាងមុន ជាពិសេសប្រជាជនដែលរស់នៅតាមជនបទ។

### ១. ប្រព័ន្ធទូទាត់តម្លៃធំ

ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យដំណើរការជាផ្លូវការសេវាផ្ទេរប្រាក់តាមប្រព័ន្ធធនាគារអនឡាញ កាលពីខែមករា ឆ្នាំ២០១៦ ក្នុងគោលបំណងកាត់បន្ថយចរាចរសាច់ប្រាក់ និងសម្រួលដល់នីតិវិធីរដ្ឋបាល ក្នុងការរៀបចំឯកសារផ្ទេរមូលនិធិដែលចំណាយពេលច្រើន និងមានលក្ខណៈស្មុគស្មាញ។ សេវាផ្ទេរប្រាក់តាមប្រព័ន្ធធនាគារអនឡាញអនុញ្ញាតឱ្យសមាជិកធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក និងពិនិត្យសមតុល្យគណនីដែលរួមចំណែកពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងសន្ទនីយភាពនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។ បច្ចុប្បន្ន ប្រព័ន្ធនេះមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាសមាជិកសរុបចំនួន ៦៦ រួមទាំងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ)។ ការពង្រីកសមាជិកភាពរបស់ប្រព័ន្ធនេះទៅអគ្គនាយកដ្ឋានរតនាគារជាតិ បានរួមចំណែកពង្រឹងការគ្រប់គ្រងថវិការបស់រាជរដ្ឋាភិបាលឱ្យកាន់តែមានប្រសិទ្ធភាព

តាមរយៈការប្រើប្រាស់ថ្នាលឌីជីថល ស្របតាមកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការកៀរគរចំណូល និងគ្រប់គ្រងការចំណាយថវិការដ្ឋតាមប្រព័ន្ធឌីជីថល។ គិតត្រឹមដំណាច់ឆ្នាំ២០២០ ប្រតិបត្តិការដែលធ្វើឡើងតាមរយៈសេវាផ្ទេរប្រាក់តាមប្រព័ន្ធធនាគារអនឡាញមានចំនួន ៣៣.០៥០ ប្រតិបត្តិការ សមមូលនឹង ១៥០,៧៣% នៃផលិតផលក្នុងស្រុកសរុប។

ធនាគារជាតិនៃកម្ពុជាបានរៀបចំអភិវឌ្ឍគម្រោងទូទាត់ដុលភ្លាមៗ នៅចុងឆ្នាំ២០១៦ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (២០១៦-២០២៥)។ ក្នុងពេលអនុវត្តគម្រោងទូទាត់ដុលភ្លាមៗ ធនាគារជាតិនៃកម្ពុជាបានសិក្សាពីសារៈប្រយោជន៍នៃបច្ចេកវិទ្យាឌីអិលធីក្នុងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ ហើយជាលទ្ធផលប្រព័ន្ធបាគងក៏ត្រូវបានដាក់ឱ្យដំណើរការនៅចុងឆ្នាំ២០២០។ ផ្អែកលើបទពិសោធន៍ថ្មីដែលទទួលបានពីការអភិវឌ្ឍប្រព័ន្ធបាគង ធនាគារជាតិនៃកម្ពុជាបាននិងកំពុងសិក្សាស្វែងយល់បន្ថែមអំពីសក្តានុពលក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីអិលធីនេះ ដើម្បីអភិវឌ្ឍប្រព័ន្ធទូទាត់តម្លៃធំ (LVPS)។ ការប្រើប្រាស់បច្ចេកវិទ្យាឌីអិលធីនេះកំពុងទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីធនាគារកណ្តាលជាច្រើន ក្នុងការទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យានេះ ដើម្បីប្រើ-ប្រាស់សម្រាប់គាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធទូទាត់តម្លៃធំ។ ផ្អែកលើសារៈប្រយោជន៍ក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីអិលធី ធនាគារជាតិនៃកម្ពុជាបានសម្រេចធ្វើការសិក្សាស្រាវជ្រាវបន្ថែម ដើម្បីអភិវឌ្ឍប្រព័ន្ធទូទាត់តម្លៃធំលើមុខងារមួយចំនួនរបស់ប្រព័ន្ធទូទាត់ដុលភ្លាមៗ។

## ២. ប្រព័ន្ធទូទាត់រាយ

នៅចុងឆ្នាំ២០១២ ប្រព័ន្ធជាត់ទាត់ជាតិត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ ដើម្បីជួយសម្រួលដល់ការជាត់ទាត់និងទូទាត់ប្រតិបត្តិការអន្តរធនាគារ។ ប្រព័ន្ធនេះមានសមត្ថភាពក្នុងការសម្របសម្រួលដល់កិច្ចដំណើរការទូទាត់អន្តរធនាគារលើប្រតិបត្តិការមូលប្បទានបត្រ និងបញ្ជាទូទាត់អេឡិចត្រូនិក ដូចជា ឥណទានផ្ទាល់ ឥណពន្ធផ្ទាល់ និងបញ្ជាផ្ទេរឥណទានជាប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិកជាដើម។ បច្ចុប្បន្ន ប្រព័ន្ធជាត់ទាត់ជាតិមានគ្រឹះស្ថានសមាជិកសរុបចំនួន ៥២ គ្រឹះស្ថាន ក្នុងនោះមានសមាជិកផ្ទាល់ចំនួន ៣៥ គ្រឹះស្ថាន និងសមាជិកមិនផ្ទាល់ចំនួន ១៧ គ្រឹះស្ថាន។ គិតត្រឹមចុងឆ្នាំ២០២០ ប្រតិបត្តិការសរុបដែលធ្វើឡើងតាមរយៈប្រព័ន្ធជាត់ទាត់ជាតិមានចំនួន ១.៥៧៤.២១០ ប្រតិបត្តិការ សមមូលនឹង ២៥៩,១៥% នៃផលិតផលក្នុងស្រុកសរុប។

ដើម្បីលើកកម្ពស់ការទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក និងការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធសេវាទូទាត់រហ័សនៅឆ្នាំ២០១៦។ ប្រព័ន្ធនេះដំណើរការផ្ទេរប្រាក់អន្តរធនាគារជាប្រាក់រៀល តាមរយៈបញ្ជាផ្ទេរឥណទានក្នុងទំហំប្រាក់អតិបរមា ៤០ លានរៀលក្នុងមួយប្រតិបត្តិការ និងអាចឱ្យអ្នកប្រើប្រាស់ទទួលបានមូលនិធិភ្លាមៗ។ បច្ចុប្បន្ន ប្រព័ន្ធសេវាទូទាត់រហ័ស មានគ្រឹះស្ថានជាសមាជិកសរុបចំនួន ៥៥ គ្រឹះស្ថាន រួមមាន ធនាគារពាណិជ្ជចំនួន ៤៩ ធនាគារឯកទេសចំនួន ១ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៥។ ដើម្បីពង្រីកវិសាលភាពក្នុងការធ្វើប្រតិបត្តិការ និងបង្កើនភាពងាយស្រួលក្នុងការប្រើប្រាស់ប្រព័ន្ធសេវាទូទាត់រហ័ស ធនាគារជាតិនៃកម្ពុជាបានបន្តលើកទឹកចិត្តឱ្យគ្រឹះស្ថានជាសមាជិក ពង្រីកបណ្តាញប្រតិបត្តិការប្រព័ន្ធនេះទៅក្នុងកម្មវិធីធនាគារចល័ត និងសេវាធនាគារតាមអ៊ីនធឺណិត ព្រមទាំងបណ្តាញ

មិនមែនធនាគារ។ បច្ចេកវិទ្យាហិរញ្ញវត្ថុត្រូវអនុលោមតាមបទប្បញ្ញត្តិនានាជាធរមាន ដែលដាក់ចេញដោយធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នមានសមត្ថកិច្ចផ្សេងៗទៀត អាស្រ័យលើប្រភេទនៃសកម្មភាពធុរកិច្ចរបស់ខ្លួន។

## ១. បទប្បញ្ញត្តិសម្រាប់រូបិយវត្ថុអេឡិចត្រូនិក និងសេវាទូទាត់សងប្រាក់ឌីជីថល

- **ប្រកាសស្តីពី អ្នកដំណើរការតតិយភាគី៖** កាលពីឆ្នាំ២០១០ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសស្តីពី អ្នកដំណើរការតតិយភាគី ដើម្បីគ្រប់គ្រង និងដាក់ឱ្យប្រើប្រាស់នីតិវិធីលើការផ្តល់អាជ្ញាបណ្ណដល់បុគ្គលស្របច្បាប់ដែលផ្តល់សេវាទូទាត់សងប្រាក់នៅកម្ពុជា។ គោលបំណងនៃប្រកាសនេះ ដើម្បីផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រគល់សិទ្ធិមួយផ្នែក ឬច្រើនផ្នែកនៃប្រតិបត្តិការសេវាទូទាត់សងប្រាក់ឱ្យអ្នកដំណើរការតតិយភាគីមួយ ឬច្រើន ដូចបានព្រមព្រៀងគ្នារវាងគ្រឹះស្ថានធនាគារ និងអ្នកដំណើរការតតិយភាគី។ អ្នកដំណើរការតតិយភាគីត្រូវទទួលបានការធានាដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីផ្តល់សេវាទូទាត់សងប្រាក់ទៅកាន់សាធារណជនជំនួសឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។
- **ប្រកាសស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់៖** កាលពីឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដើម្បីគ្រប់គ្រង និងដាក់ឱ្យប្រើប្រាស់នីតិវិធីលើការផ្តល់អាជ្ញាបណ្ណដល់បុគ្គលស្របច្បាប់ដែលផ្តល់សេវាទូទាត់សងប្រាក់នៅកម្ពុជា។ គោលបំណងរបស់ប្រកាសនេះ ដើម្បីធានាសុវត្ថិភាព និងភាពរឹងមាំនៃសេវាទូទាត់សងប្រាក់ ជំរុញនវានុវត្តន៍ និងការប្រកួតប្រជែង និងលើកកម្ពស់ទំនុកចិត្តរបស់សាធារណជនមកលើសេវាទូទាត់សងប្រាក់ ក៏ដូចជាគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យទូទាត់សងប្រាក់ និងផ្ទេរប្រាក់ ដោយអនុញ្ញាតឱ្យគ្រឹះស្ថានទាំងនោះដំណើរការដោយឯករាជ្យមិនពឹងផ្អែកលើគ្រឹះស្ថានធនាគារ។ ក្រោមវិសាលភាពនៃប្រកាសនេះ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់អាចរក្សាកិច្ចសហការជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាតភ្ជាប់ផ្ទាល់ជាមួយហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់។ ប្រកាសនេះក៏មានចែងអំពីវិធានការដើម្បីធានាសុវត្ថិភាព និងភាពរឹងមាំនៃសេវាទូទាត់សងប្រាក់ ដោយចែងបញ្ញត្តិពាក់ព័ន្ធការរក្សាស្ថិរភាព និងសុចរិតភាពដោយផ្តោតលើបញ្ហាសំខាន់ៗដូចជា សុវត្ថិភាពមូលនិធិ ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ហានិភ័យប្រតិបត្តិការ និងកិច្ចការពារអ្នកប្រើប្រាស់។

## ២. បទប្បញ្ញត្តិសម្រាប់មូលធនក្រោដហ្វាន់ឌីង

មូលធនក្រោដហ្វាន់ឌីងនៅកម្ពុជា ស្ថិតនៅក្រោមច្បាប់គ្រប់គ្រងស្តីពី ការបោះផ្សាយ និងជួញដូរមូលបត្រមហាជន ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ និងប្រកាសស្តីពី ការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ ស្តីពី ការទទួលពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនថែរក្សា

ទ្រព្យសម្បត្តិជំនួស ក្រុមហ៊ុនចែកចាយទិញ-លក់ត្រលប់មកវិញ ឬទូទាត់សងក្រុមហ៊ុនអភិបាលមូលនិធិ ភ្នាក់ងារគ្រប់គ្រងមូលនិធិ ភ្នាក់ងារក្រោដហ្វាន់ឌីង និងភ្នាក់ងារចែកចាយលក់មូលនិធិ។ ដោយសារប្រតិបត្តិការទាំងអស់នេះពាក់ព័ន្ធនឹងវិស័យមូលបត្រ គ្រឹះស្ថានដែលផ្តល់សេវាប្រភេទនេះត្រូវស្ថិតក្រោមដែនសមត្ថកិច្ចរបស់គណៈកម្មការមូលបត្រកម្ពុជា។ ទាំងគ្រឹះស្ថានចេញផ្សាយមូលបត្រ និងបច្ចេកវិទ្យាហិរញ្ញវត្ថុពាក់ព័ន្ធត្រូវបំពេញឱ្យបានគ្រប់គ្រាន់តាមលក្ខខណ្ឌបទប្បញ្ញត្តិមុននឹងចាប់ផ្តើមប្រតិបត្តិការមូលធនក្រោដហ្វាន់ឌីងនៅប្រទេសកម្ពុជា។

## ៣. បទប្បញ្ញត្តិសម្រាប់បច្ចេកវិទ្យាធានារ៉ាប់រង

រាល់សកម្មភាពសេវាធានារ៉ាប់រងទាំងអស់ រួមទាំងបច្ចេកវិទ្យាធានារ៉ាប់រងនៅកម្ពុជា ត្រូវបានកំណត់ដោយច្បាប់ស្តីពីការធានារ៉ាប់រង ដែលត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤។ ដោយសារបច្ចេកវិទ្យាធានារ៉ាប់រងផ្តល់សេវាពាក់ព័ន្ធការធានារ៉ាប់រង ហេតុនេះត្រូវស្ថិតក្រោមដែនសមត្ថកិច្ចរបស់អាជ្ញាធរត្រួតពិនិត្យគ្រឹះស្ថានមិនមែនធនាគារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ លក្ខណៈគតិយុត្តរវាងបច្ចេកវិទ្យាធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងទូទៅពុំមានភាពខុសគ្នា ដែលត្រូវស្ថិតនៅក្រោមលក្ខខណ្ឌដូចគ្នា ដើម្បីអាចធ្វើប្រតិបត្តិការស្របច្បាប់នៅប្រទេសកម្ពុជា។

## ៤. ច្បាប់ស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា ត្រូវបានកំណត់ដោយច្បាប់ស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩។ ច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក ចែងពីបទប្បញ្ញត្តិក្នុងការគ្រប់គ្រងសកម្មភាពអ្នកផ្តល់សេវាពាណិជ្ជកម្មអេឡិចត្រូនិក និងយថាភូតភាព សុក្រឹតភាព និងភាពអាចជឿទុកចិត្តបាននៃទម្រង់អេឡិចត្រូនិកក្នុងគោលបំណងជំរុញការធ្វើពាណិជ្ជកម្មអេឡិចត្រូនិកប្រកបដោយសុវត្ថិភាព លើកកម្ពស់ទំនុកចិត្តរបស់សាធារណជន និងសម្រួលដល់ការបំពេញឯកសារជាទម្រង់អេឡិចត្រូនិក តាមរយៈការប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកដែលអាចជឿទុកចិត្តបាននៅប្រទេសកម្ពុជា។

## ៥. ច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់

ច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់ ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ ២០១៩។ ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់នេះ ត្រូវបានបង្កើតឡើងដើម្បីធានាឱ្យមានកិច្ចការពារអ្នកប្រើប្រាស់ និងចូលរួមលើកកម្ពស់ការប្រកួតប្រជែងដោយសុចរិត។ លើសពីនេះ ច្បាប់នេះក៏បានកំណត់វិធាន និងយន្តការនានា ដើម្បីចូលរួមចំណែកបង្កើតបរិយាកាសធុរកិច្ចដែលក្នុងនោះសិទ្ធិនិងផលប្រយោជន៍របស់អ្នកប្រើប្រាស់ត្រូវបានការពារ។ ការធ្វើធុរកិច្ចត្រូវបានធ្វើឡើងជាមួយនឹងការប្រកួតប្រជែងដោយសុចរិត ហើយអ្នកប្រើប្រាស់និងពាណិជ្ជករអាចធ្វើសកម្មភាពជាមួយគ្នាដោយមានទំនុកចិត្ត។ ច្បាប់នេះអនុវត្តចំពោះបុគ្គលទាំងឡាយណាដែលធ្វើធុរកិច្ចទោះបីរកប្រាក់ចំណេញ ឬមិនរកប្រាក់ចំណេញក្តី រួមទាំង ការលក់ទំនិញឬសេវាផ្សេងៗ ឬសិទ្ធិប្រត្យក្សលើអចលនទ្រព្យឱ្យអ្នកប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានបទប្បញ្ញត្តិដោយឡែកដែលចែងផ្សេងពីនេះ។

## III. ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ដែលគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ

ប្រព័ន្ធទូទាត់សងប្រាក់បានរួមចំណែកយ៉ាងសំខាន់ ក្នុងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ដើម្បីសម្រួលដល់ប្រតិបត្តិការផ្ទេរប្រាក់ ការទូទាត់ចំពោះការទិញ-លក់ទំនិញនិងសេវា និងការជួញដូរនៅលើទីផ្សារហិរញ្ញវត្ថុជាដើម។ លើសពីនេះ ប្រព័ន្ធទូទាត់សងប្រាក់ក៏បានរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងការអភិវឌ្ឍសេវា និងឧបករណ៍ទូទាត់សងប្រាក់ប្រកបដោយនវានុវត្តន៍ ដែលមានតម្លៃសមរម្យ និងមានលក្ខណៈទូលំទូលាយ ផ្តល់លទ្ធភាពឱ្យប្រជាជននៅតាមជនបទអាចប្រើប្រាស់សេវាទូទាត់សងប្រាក់ តាមរយៈសេវាហិរញ្ញវត្ថុផ្លូវការ សំដៅចូលរួមកាត់បន្ថយភាពក្រីក្រ និងវិសមភាពសង្គម។ អាស្រ័យហេតុនេះ ការអភិវឌ្ឍ និងការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ត្រូវបានធនាគារជាតិនៃកម្ពុជាចាត់ទុកជាការងារអាទិភាព។ ស្របពេលនៃការរីកចម្រើននៃបច្ចេកវិទ្យា ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់ តាមរយៈកំណើននៃការដាក់ឱ្យប្រើនូវឧបករណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ។ កំណើននៃការដាក់ឱ្យប្រើនូវឧបករណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុនេះ បានធ្វើឱ្យប្រព័ន្ធទូទាត់សងប្រាក់ក្លាយជាធាតុសំខាន់មួយក្នុងប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុនៅប្រទេសកម្ពុជា។ បច្ចុប្បន្ន ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់និងសេវា ព្រមទាំងឧបករណ៍ទូទាត់ប្រកបដោយនវានុវត្តន៍ត្រូវបានដាក់ឱ្យប្រើប្រាស់ជាបន្តបន្ទាប់ ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃការទូទាត់សងប្រាក់នៅប្រទេសកម្ពុជា។ ដោយពិនិត្យឃើញពីសារៈសំខាន់នេះ ធនាគារជាតិនៃកម្ពុជាបានប្រើប្រាស់បច្ចេកវិទ្យា ដើម្បីធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ តាមរយៈការដាក់ឱ្យដំណើរការហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ជាច្រើន រួមមាន ប្រព័ន្ធទូទាត់តម្លៃធំ ប្រព័ន្ធទូទាត់រាយ ហើយថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធបាគង ដើម្បីជំរុញការប្រើប្រាស់សេវាទូទាត់សងប្រាក់ និងជំរុញឱ្យបុគ្គល គ្រួសារ និងសហគ្រាស អាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុឌីជីថលបានកាន់តែប្រសើរជាងមុន ជាពិសេសប្រជាជនដែលរស់នៅតាមជនបទ។

### ១. ប្រព័ន្ធទូទាត់តម្លៃធំ

ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យដំណើរការជាផ្លូវការសេវាផ្ទេរប្រាក់តាមប្រព័ន្ធធនាគារអនឡាញ កាលពីខែមករា ឆ្នាំ២០១៦ ក្នុងគោលបំណងកាត់បន្ថយចរាចរសាច់ប្រាក់ និងសម្រួលដល់នីតិវិធីរដ្ឋបាល ក្នុងការរៀបចំឯកសារផ្ទេរមូលនិធិដែលចំណាយពេលច្រើន និងមានលក្ខណៈស្មុគស្មាញ។ សេវាផ្ទេរប្រាក់តាមប្រព័ន្ធធនាគារអនឡាញអនុញ្ញាតឱ្យសមាជិកធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក និងពិនិត្យសមតុល្យគណនីដែលរួមចំណែកពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងសន្ទនីយភាពនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។ បច្ចុប្បន្ន ប្រព័ន្ធនេះមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាសមាជិកសរុបចំនួន ៦៦ រួមទាំងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ)។ ការពង្រីកសមាជិកភាពរបស់ប្រព័ន្ធនេះទៅអគ្គនាយកដ្ឋានរតនាគារជាតិ បានរួមចំណែកពង្រឹងការគ្រប់គ្រងថវិការបស់រាជរដ្ឋាភិបាលឱ្យកាន់តែមានប្រសិទ្ធភាព

តាមរយៈការប្រើប្រាស់ថ្នាលឌីជីថល ស្របតាមកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការកៀរគរចំណូល និងគ្រប់គ្រងការចំណាយថវិការដ្ឋតាមប្រព័ន្ធឌីជីថល។ គិតត្រឹមដំណាច់ឆ្នាំ២០២០ ប្រតិបត្តិការដែលធ្វើឡើងតាមរយៈសេវាផ្ទេរប្រាក់តាមប្រព័ន្ធធនាគារអនឡាញមានចំនួន ៣៣.០៩០ ប្រតិបត្តិការ សមមូលនឹង ១៨០,៧៣% នៃផលិតផលក្នុងស្រុកសរុប។

ធនាគារជាតិនៃកម្ពុជាបានរៀបចំអភិវឌ្ឍគម្រោងទូទាត់ដុលភ្លាមៗ នៅចុងឆ្នាំ២០១៦ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (២០១៦-២០២៥)។ ក្នុងពេលអនុវត្តគម្រោងទូទាត់ដុលភ្លាមៗ ធនាគារជាតិនៃកម្ពុជាបានសិក្សាពីសារៈប្រយោជន៍នៃបច្ចេកវិទ្យាឌីអិលធីក្នុងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ ហើយជាលទ្ធផលប្រព័ន្ធបាគងក៏ត្រូវបានដាក់ឱ្យដំណើរការនៅចុងឆ្នាំ២០២០។ ផ្អែកលើបទពិសោធន៍ថ្មីដែលទទួលបានពីការអភិវឌ្ឍប្រព័ន្ធបាគង ធនាគារជាតិនៃកម្ពុជាបាននិងកំពុងសិក្សាស្វែងយល់បន្ថែមអំពីសក្ដានុពលក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីអិលធីនេះ ដើម្បីអភិវឌ្ឍប្រព័ន្ធទូទាត់តម្លៃធំ (LVPS)។ ការប្រើប្រាស់បច្ចេកវិទ្យាឌីអិលធីនេះកំពុងទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីធនាគារកណ្តាលជាច្រើន ក្នុងការទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យានេះ ដើម្បីប្រើប្រាស់សម្រាប់គាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធទូទាត់តម្លៃធំ។ ផ្អែកលើសារៈប្រយោជន៍ក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីអិលធី ធនាគារជាតិនៃកម្ពុជាបានសម្រេចធ្វើការសិក្សាស្រាវជ្រាវបន្ថែម ដើម្បីអភិវឌ្ឍប្រព័ន្ធទូទាត់តម្លៃធំលើមុខងារមួយចំនួនរបស់ប្រព័ន្ធទូទាត់ដុលភ្លាមៗ។

## ២. ប្រព័ន្ធទូទាត់រាយ

នៅចុងឆ្នាំ២០១២ ប្រព័ន្ធផាត់ទាត់ជាតិត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ ដើម្បីជួយសម្រួលដល់ការផាត់ទាត់និងទូទាត់ប្រតិបត្តិការអន្តរធនាគារ។ ប្រព័ន្ធនេះមានសមត្ថភាពក្នុងការសម្របសម្រួលដល់កិច្ចដំណើរការទូទាត់អន្តរធនាគារលើប្រតិបត្តិការមូលប្បទានបត្រ និងបញ្ជាទូទាត់អេឡិចត្រូនិក ដូចជា ឥណទានផ្ទាល់ ឥណពន្ធផ្ទាល់ និងបញ្ជាផ្ទេរឥណទានជាប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិក ជាដើម។ បច្ចុប្បន្ន ប្រព័ន្ធផាត់ទាត់ជាតិមានគ្រឹះស្ថានសមាជិកសរុបចំនួន ៥២ គ្រឹះស្ថាន ក្នុងនោះមានសមាជិកផ្ទាល់ចំនួន ៣៥ គ្រឹះស្ថាន និងសមាជិកមិនផ្ទាល់ចំនួន ១៧ គ្រឹះស្ថាន។ គិតត្រឹមចុងឆ្នាំ២០២០ ប្រតិបត្តិការសរុបដែលធ្វើឡើងតាមរយៈប្រព័ន្ធផាត់ទាត់ជាតិមានចំនួន ១.៥៧៤.២១០ ប្រតិបត្តិការ សមមូលនឹង ២៥៩,១៥% នៃផលិតផលក្នុងស្រុកសរុប។

ដើម្បីលើកកម្ពស់ការទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក និងការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធសេវាទូទាត់រហ័សនៅឆ្នាំ២០១៦។ ប្រព័ន្ធនេះដំណើរការផ្ទេរប្រាក់អន្តរធនាគារជាប្រាក់រៀល តាមរយៈបញ្ជាផ្ទេរឥណទានក្នុងទំហំប្រាក់អតិបរមា ៤០ លានរៀលក្នុងមួយប្រតិបត្តិការ និងអាចឱ្យអ្នកប្រើប្រាស់ទទួលបានមូលនិធិភ្លាមៗ។ បច្ចុប្បន្ន ប្រព័ន្ធសេវាទូទាត់រហ័ស មានគ្រឹះស្ថានជាសមាជិកសរុបចំនួន ៥៥ គ្រឹះស្ថាន រួមមាន ធនាគារពាណិជ្ជចំនួន ៤៩ ធនាគារឯកទេសចំនួន ១ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៥។ ដើម្បីពង្រីកវិសាលភាពក្នុងការធ្វើប្រតិបត្តិការ និងបង្កើនភាពងាយស្រួលក្នុងការប្រើប្រាស់ប្រព័ន្ធសេវាទូទាត់រហ័ស ធនាគារជាតិនៃកម្ពុជាបានបន្តលើកទឹកចិត្តឱ្យគ្រឹះស្ថានជាសមាជិក ពង្រីកបណ្តាញប្រតិបត្តិការប្រព័ន្ធនេះទៅក្នុងកម្មវិធីធនាគារចល័ត និងសេវាធនាគារតាមអ៊ីនធឺណិត ព្រមទាំងបណ្តាញ

- **ការប្រើប្រាស់សេវាទូរស័ព្ទចល័ត៖** ការប្រើប្រាស់សេវាទូរស័ព្ទចល័តនៅប្រទេសកម្ពុជាមានចំនួន ២០,៨ លាន (ស្មើនឹង ១២៥% នៃប្រជាជនកម្ពុជាចំនួន ១៦,៦ លាននាក់) ដោយកើនឡើងចំនួន ០,៧៦ លាន ឬស្មើនឹង ៣,៧% បើធៀបនឹងឆ្នាំមុន។
- **ប្រជាជនវ័យជំទង់៖** ប្រជាជនកម្ពុជាដែលមានអាយុចាប់ពី ១៦ឆ្នាំឡើងទៅមាន ចំនួន ៦៥% ឬស្មើនឹង ១០,៦ លាននាក់(យោងតាមរបាយការណ៍ DataReportal ក្នុងឆ្នាំ២០២០)។ ប្រជាជនវ័យជំទង់ ជាចំណែកទីផ្សារដ៏ធំក្នុងការប្រើប្រាស់សេវាទូទាត់ទំនិញបែបឌីជីថលនៅប្រទេសកម្ពុជា ជាពិសេសនៅក្នុងតំបន់ទីប្រជុំជន។ បន្ថែមលើនេះ សម្រាប់ក្រុមវ័យជំទង់នេះមាននិន្នាការក្នុងការប្រើប្រាស់ ឬងាយទទួលយកផលិតផលនិងសេវាថ្មីៗប្រកបដោយនវានុវត្តន៍ដើម្បីផ្លាស់ប្តូរបរិបទនៃការរស់នៅរបស់ពួកគេ ឱ្យស្របទៅនឹងការវិវត្តន៍យ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល បើប្រៀបធៀបនឹងប្រជាជនក្នុងវ័យផ្សេងទៀត។

# ជំពូក ៤ ទិដ្ឋភាពគោលនយោបាយបច្ចេកវិទ្យាហិរញ្ញវត្ថុ

នៅក្នុងជំពូកនេះ នឹងពិនិត្យអំពីចំណុចសំខាន់ៗចំនួន ៣ ដើម្បីស្វែងយល់ពីបរិយាកាសបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា រួមមាន សេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ បច្ចេកវិទ្យាគាំទ្រ និងគោលនយោបាយជំរុញ។ សេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ ឬការប្រើប្រាស់បច្ចេកវិទ្យាក្នុងការផ្តល់សេវាហិរញ្ញវត្ថុមានទម្រង់ច្រើនប្រភេទ និងគ្របដណ្តប់គ្រប់វិស័យនៃឧស្សាហកម្មហិរញ្ញវត្ថុ។ បច្ចេកវិទ្យាគាំទ្រ ជំរុញឱ្យមាននវានុវត្តភាពចំពោះការផ្តល់សេវាហិរញ្ញវត្ថុ និងផ្តល់ជាកន្លែងសម្រាប់សេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ។ គោលនយោបាយជំរុញ សំដៅដល់វិធានការគោលនយោបាយ និងគំនិតផ្តួចផ្តើមជាសាធារណៈនានា ដើម្បីជំរុញការអភិវឌ្ឍសេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ និងការប្រើប្រាស់បច្ចេកវិទ្យាគាំទ្រ។ នៅក្នុងបរិបទនេះ អាជ្ញាធរហិរញ្ញវត្ថុធ្វើការកែសម្រួលក្របខណ្ឌគោលនយោបាយ និងដាក់ចេញគោលការណ៍ណែនាំដោយផ្អែកលើការវាយតម្លៃលើផលប៉ះពាល់នៃបច្ចេកវិទ្យាថ្មីៗ ចំពោះវិស័យហិរញ្ញវត្ថុ។ ការទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យាហិរញ្ញវត្ថុឱ្យបានច្រើនជាអតិបរមា ខណៈដែលហានិភ័យលើប្រព័ន្ធហិរញ្ញវត្ថុត្រូវបានរក្សាក្នុងកម្រិតអប្បបរមា ជាបញ្ហាប្រឈមសម្រាប់អ្នករៀបចំគោលនយោបាយ។ ប៉ុន្តែកិច្ចការនេះ មិនមានភាពងាយស្រួល ដោយសារអាជ្ញាធរត្រូវប្រឈមនឹងឧបសគ្គជាច្រើន។ ការវិវត្តន៍នៃបច្ចេកវិទ្យាហិរញ្ញវត្ថុបានឆ្លុះបញ្ចាំងពីបញ្ហាដែលហួសពីវិសាលភាពត្រួតពិនិត្យរបស់អាជ្ញាធរហិរញ្ញវត្ថុ ដោយសារសន្ទុះនៃនវានុវត្តន៍បណ្តាលឱ្យមានផលវិបាកក្នុងការឆ្លើយតបទាន់ពេលវេលា។

## I. សេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ

### ១. សេវាធនាគារឌីជីថល

#### ក. ស្ថានភាពបច្ចុប្បន្ន

ប្រតិបត្តិការនៅក្នុងប្រព័ន្ធធនាគារ បានវិវត្តពីការអនុវត្តតាមបែបប្រពៃណីដោយប្រើប្រាស់បញ្ជរសាខាទៅជាការអនុវត្តតាមបណ្តាញអនឡាញក្នុងយុគសម័យអ៊ីនធឺណិត។ បច្ចុប្បន្ន សេវាធនាគារតាមអ៊ីនធឺណិត និងសេវាធនាគារចល័តបានវិវត្តទៅជាថ្នាលសេវាកម្មរួម ហៅថាសេវាធនាគារឌីជីថល ដែលផ្តល់សេវាធនាគារពីភាគីម្ខាងទៅភាគីម្ខាងទៀតតាមប្រព័ន្ធអនឡាញ ព្រមទាំងផ្តល់ហេដ្ឋារចនាសម្ព័ន្ធ និងដំណើរការជាអេឡិចត្រូនិកនៅក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផងដែរ។

គ្រឹះស្ថានធនាគារផ្តល់សេវាធនាគារឌីជីថល ជាគ្រឹះស្ថានទទួលប្រាក់បញ្ញើដែលជាសមាជិកនៃអង្គភាពការពារប្រាក់បញ្ញើ ហើយផ្តល់សេវាធនាគារជាចម្បងតាមប្រព័ន្ធអេឡិចត្រូនិកជំនួសឱ្យបញ្ជរសាខាធនាគារ។ សេវាធនាគារឌីជីថលត្រូវប្រឈមនឹងបរិវត្តកម្មហានិភ័យដូចគ្នាទៅនឹងធនាគារទូទៅដែរដែលធ្វើប្រតិបត្តិការតាមបែបប្រពៃណី ប៉ុន្តែមានទម្រង់ធុរកិច្ចតាមបែបបច្ចេកវិទ្យាដែលអាចផ្តល់សេវាពីចម្ងាយដោយមិនចាំបាច់មានសាខា ឬមានសាខាតិចតួច។

សេវាធនាគារឌីជីថលផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់អ្នកប្រើប្រាស់ដូចជា ផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់ បង្កើនរយៈពេលនៃការផ្តល់សេវាតាមម៉ាស៊ីនដក/ដាក់ប្រាក់ដោយស្វ័យប្រវត្តិ (ATM) បានគ្រប់ពេលវេលា បំពេញតម្រូវការអ្នកប្រើប្រាស់បានប្រសើរជាងមុន ផ្តល់លទ្ធភាពប្រើប្រាស់សេវាហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិតក្នុងតម្លៃសមស្រប សម្រួលដល់ជីវភាពរស់នៅ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ដែលកត្តាទាំងនេះជួយជំរុញកំណើនសេដ្ឋកិច្ច។ ប៉ុន្តែសេវាធនាគារឌីជីថលក៏នាំមកនូវបញ្ហាប្រឈម និងហានិភ័យមួយចំនួនផងដែរ ដូចជា ការបន្លំឆបោកតាមប្រព័ន្ធអ៊ីនធឺណិត ការបំពានលើសន្តិសុខសាយប័រ និងកង្វះខាតនៃហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទប់ទល់ ដែលជាបញ្ហាប្រឈមចម្បងជាងគេ។

នៅក្នុងប្រទេសកម្ពុជា វត្តមាននៃបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ (ដូចជា រូបិយវត្ថុអេឡិចត្រូនិក និងសេវាទូទាត់សងប្រាក់ឌីជីថល) បានជំរុញឱ្យគ្រឹះស្ថានធនាគារបង្កើនការវិនិយោគលើសេវាធនាគារឌីជីថល ដើម្បីឱ្យដំណើរការទូទាត់កាន់តែមានភាពរលូន។ គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើជាច្រើន ចាប់ផ្តើមផ្តល់សេវាធនាគារឌីជីថល ដូចជាផ្តល់ឧបករណ៍ទូទាត់អេឡិចត្រូនិក សេវាធនាគារតាមអ៊ីនធឺណិត និងសេវាធនាគារចល័ត។ នៅក្នុងឆ្នាំ២០២០ ចំនួនប្រតិបត្តិការតាមរយៈសេវាធនាគារឌីជីថលមានចំនួនសរុបជាង ២២២ លានប្រតិបត្តិការ និងមានទំហំប្រាក់ប្រមាណ ២៥៤% នៃផលិតផលក្នុងស្រុកសរុប។

ប្រតិបត្តិការធនាគារនៅកម្ពុជាត្រូវបានស្ថិតនៅក្រោមច្បាប់ស្តីពី "ការរៀបចំនិងការប្រព្រឹត្តិទៅរបស់ធនាគារជាតិនៃកម្ពុជា" ដែលប្រកាសឱ្យប្រើនៅឆ្នាំ១៩៩៦ ច្បាប់ស្តីពី "គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ" ដែលប្រកាសឱ្យប្រើនៅឆ្នាំ១៩៩៩ ច្បាប់ស្តីពី "ការគ្រប់គ្រងការប្តូរប្រាក់" ដែលប្រកាសឱ្យប្រើនៅឆ្នាំ១៩៩៧ និងច្បាប់ស្តីពី "ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់" ដែលប្រកាសឱ្យប្រើនៅឆ្នាំ២០០៦ ក៏ដូចជាបទប្បញ្ញត្តិ និងសារាចរផ្សេងៗដែលដាក់ចេញដោយធនាគារជាតិនៃកម្ពុជា។ គ្រឹះស្ថានធនាគារដែលផ្តល់សេវាធនាគារឌីជីថល ក៏ត្រូវស្ថិតក្រោមបទប្បញ្ញត្តិដូចគ្នា ដោយមិនមានប្រព្រឹត្តិកម្មផ្សេងគ្នាចំពោះសកម្មភាពប្រតិបត្តិការដែលអនុញ្ញាត ឬរបបគ្រប់គ្រងសម្រាប់សេវាធនាគារឌីជីថល។ បច្ចុប្បន្ន គ្រឹះស្ថានបច្ចេកវិទ្យាហិរញ្ញវត្ថុដែលធ្វើសកម្មភាពពាក់ព័ន្ធនឹងផ្នែកណាមួយក្នុងចំណោមមុខងារដូចជា ការប្រមូលប្រាក់បញ្ញើ ការផ្តល់មធ្យោបាយទូទាត់ និងការផ្តល់ឥណទាន ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិគ្រប់គ្រងទៅតាមសកម្មភាពនីមួយៗ។

### ខ. បញ្ហាប្រឈម

ក្របខណ្ឌសេវាធនាគារឌីជីថល ជាទស្សនទានថ្មីនៅឡើយសម្រាប់បណ្តាប្រទេសមួយចំនួនធំ។ ទោះបីជាក្របខណ្ឌនេះបានជំរុញឱ្យប្រព័ន្ធធនាគារកាន់តែមានប្រសិទ្ធភាព និងប្រកបដោយបរិយាបន្នក៏ដោយ បញ្ហាប្រឈមសម្រាប់ក្របខណ្ឌនេះនៅតែមាន។ នៅក្នុងបរិបទប្រទេសកម្ពុជា ការដាក់ចេញក្របខណ្ឌសេវាធនាគារឌីជីថលនៅមិនទាន់អាចធ្វើការសន្និដ្ឋានបានទេ ដោយសារការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល រួមមាន អត្តសញ្ញាណឌីជីថល ការអនុញ្ញាតនិងការព្រមព្រៀង និងការផ្លាស់ប្តូរទិន្នន័យនៅមិនទាន់មានភាពពេញលេញនៅឡើយ។ លើសពីនេះ ក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិដែលពាក់ព័ន្ធការការពារទិន្នន័យ និងសន្តិសុខសាយប័រនៅមិនទាន់មានដើម្បីជំរុញប្រតិបត្តិការឌីជីថល

ឱ្យប្រព្រឹត្តិទៅដោយរលូន។ ការវិវត្តន៍បន្ថែមទៀតនៃសេវាធនាគារឌីជីថលនៅបណ្តាប្រទេសជុំវិញពិភពលោកនឹងផ្តល់ឱកាសគ្រប់គ្រាន់សម្រាប់កម្ពុជាយកមកសិក្សា និងអនុវត្ត។ សម្រាប់ទិសដៅអនាគត អាជ្ញាធរត្រួតពិនិត្យត្រូវព្យាយាមតាមដានឱ្យទាន់សភាពការណ៍នៃការរីកចម្រើនបច្ចេកវិទ្យា និងដោះស្រាយរាល់បញ្ហាប្រឈមនានាលើក្របខណ្ឌបទប្បញ្ញត្តិ ដើម្បីជំរុញនវានុវត្តន៍សេវាធនាគារឌីជីថល។

## ២. ថ្នាលហិរញ្ញប្បទានបច្ចេកវិទ្យាហិរញ្ញវត្ថុ

### ក. ស្ថានភាពបច្ចុប្បន្ន

ថ្នាលបច្ចេកវិទ្យាហិរញ្ញវត្ថុផ្តល់នូវសេវាហិរញ្ញវត្ថុច្រើនប្រភេទ រួមមាន ថ្នាលផ្តល់ឥណទានផ្អែកលើតារាងតុល្យការដែលទទួលមូលនិធិពីអ្នកផ្តល់ឥណទាន ហើយផ្តល់កម្ចីដល់អ្នកខ្ចីប្រាក់ និងថ្នាលបច្ចេកវិទ្យាហិរញ្ញវត្ថុដើរតួនាទីជាអន្តរការីរវាងអ្នកផ្តល់កម្ចី និងអ្នកខ្ចីប្រាក់។ ដោយសារក្របខណ្ឌគតិយុត្តសម្រាប់ថ្នាលបច្ចេកវិទ្យាហិរញ្ញវត្ថុមិនមានច្បាស់លាស់ នោះប្រតិបត្តិការលើថ្នាលបច្ចេកវិទ្យាហិរញ្ញវត្ថុនីមួយៗត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិគ្រប់គ្រងនៃគំរូធុរកិច្ចផ្សេងៗគ្នា។ ក្នុងន័យនេះ បទប្បញ្ញត្តិគ្រប់គ្រងសម្រាប់ថ្នាលបច្ចេកវិទ្យាហិរញ្ញវត្ថុត្រូវបានកំណត់ទៅតាមប្រភេទសកម្មភាពធុរកិច្ច ប្រភេទនៃភាគីពាក់ព័ន្ធក្នុងធុរកិច្ច និងហានិភ័យទាក់ទងនឹងសកម្មភាពធុរកិច្ច និងភាគីពាក់ព័ន្ធ។ ជាទូទៅ របបគ្រប់គ្រងនៃថ្នាលហិរញ្ញប្បទានបច្ចេកវិទ្យាហិរញ្ញវត្ថុពាក់ព័ន្ធនឹងបទប្បញ្ញត្តិប្រតិបត្តិការធនាគារ បទប្បញ្ញត្តិប្រតិបត្តិការមូលបត្រ និងបទប្បញ្ញត្តិប្រតិបត្តិការទូទាត់។ ដូចនេះ របបគ្រប់គ្រងសម្រាប់ថ្នាលហិរញ្ញប្បទាន ផ្តោតសំខាន់ទៅលើគំរូធុរកិច្ចជាក់លាក់ដូចជា ថ្នាលផ្តល់ឥណទានផ្អែកលើតារាងតុល្យការ ថ្នាលអន្តរការីយកម្មឥណទានឌីជីថល និងមូលធនក្រោដហ្វាន់ឌីង។

ប្រទេសភាគច្រើនពុំទាន់មានបទប្បញ្ញត្តិជាក់លាក់សម្រាប់គ្រប់គ្រងថ្នាលផ្តល់ឥណទានផ្អែកលើតារាងតុល្យការ ដែលយន្តការបទប្បញ្ញត្តិភាគច្រើនផ្តោតទៅលើគ្រឹះស្ថានផ្តល់សេវាឥណទានជាសកម្មភាពប្រក្រតី ដោយមិនមានចែងអំពីលទ្ធភាពទទួលបានសេវាឥណទានតាមរយៈថ្នាលបច្ចេកវិទ្យាហិរញ្ញវត្ថុនៅលើគេហទំព័រ ឬតាមអ្នកផ្តល់កម្ចីដោយផ្ទាល់នោះទេ។ ដោយឡែក ថ្នាលអន្តរការីយកម្មឥណទានឌីជីថលផ្តោតលើសាធារណជនទូទៅដែលប្រើប្រាស់អ៊ីនធឺណិត និងធ្វើការផ្គូផ្គងរវាងអ្នកផ្តល់កម្ចី និងអ្នកខ្ចី ហើយមិនផ្តល់សេវាកម្មពាក់ព័ន្ធនឹងការបំប្លែងហានិភ័យ និងការផ្តល់សេវាឥណទានដោយផ្ទាល់។ មូលធនក្រោដហ្វាន់ឌីងនឹងត្រូវលើកយកមកពិភាក្សានៅក្នុងផ្នែកបន្ទាប់។ ការប្រើប្រាស់ថ្នាលហិរញ្ញប្បទានបច្ចេកវិទ្យាហិរញ្ញវត្ថុបានផ្តល់លទ្ធភាពដល់សាធារណជនទូទៅ និងសហគ្រាសធុនតូចនិងមធ្យមទទួលបានឥណទានដែលមិនផ្តល់ដោយគ្រឹះស្ថានធនាគារ។ ជាមួយគ្នានេះ ដំណើរការស្នើសុំប្រាក់កម្ចី និងការវាយតម្លៃឥណទានតាមរយៈថ្នាលបច្ចេកវិទ្យាហិរញ្ញវត្ថុ បានជួយកាត់បន្ថយការចំណាយក្នុងការផ្តល់ហិរញ្ញប្បទាន និងជួយបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងមូលនិធិ ប៉ុន្តែក៏ត្រូវប្រឈមនឹងហានិភ័យមួយចំនួនដូចជា ការក្លែងបន្លំ និងការវាយប្រហារតាមប្រព័ន្ធសាយប័រ។

នៅប្រទេសកម្ពុជា ដោយសារបច្ចេកវិទ្យាហិរញ្ញវត្ថុមានការរីកចម្រើនយ៉ាងឆាប់រហ័ស បានជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដាក់ចេញនូវផលិតផល និងសេវាឌីជីថលប្រកបដោយនវានុវត្តន៍ដែលផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់បានតាមរយៈប្រព័ន្ធអ៊ីនធឺណិត និងទូរស័ព្ទចល័ត។ ផលិតផល និង

សេវាដែលបានដាក់ឱ្យដំណើរការភាគច្រើនផ្តោតលើសេវាសន្សំ និងសេវាទូទាត់សងប្រាក់ ចំណែកឯសេវាផ្តល់ឥណទាននៅមានកម្រិតតិចតួចនៅឡើយ ក្នុងនោះប្រតិបត្តិការបច្ចេកវិទ្យាហិរញ្ញវត្ថុមួយចំនួនបានចូលរួមក្នុងសកម្មភាពផ្តល់ប្រាក់កម្ចីដល់អ្នកដែលមិនមានលទ្ធភាពប្រើប្រាស់សេវាហិរញ្ញវត្ថុ។ ប្រតិបត្តិការដូចជា "Spean Luy" បានដាក់ឱ្យដំណើរការថ្នាលផ្តល់ប្រឹក្សាប្រាក់កម្ចីតាមអនឡាញ ដែលផ្តល់ព័ត៌មានអំពីលក្ខខណ្ឌឥណទាននៅតាមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចំណែកប្រតិបត្តិការផ្សេងទៀតដូចជា "Karprak" តភ្ជាប់ជាមួយអ្នកប្រើប្រាស់តាមរយៈបណ្តាញទំនាក់ទំនងសង្គម ជាពិសេសតាមហ្វេសប៊ុក និងកម្មវិធីផ្សេងទៀត ដើម្បីផ្តល់ឥណទានដោយផ្ទាល់ ឬដៃគូសហការផ្សេងទៀតទៅកាន់អ្នកប្រើប្រាស់។ ទោះជាយ៉ាងណា ថ្នាលបច្ចេកវិទ្យាហិរញ្ញវត្ថុមានលក្ខណៈជាអន្តរការីសម្រាប់ផ្គូផ្គងរវាងអ្នកផ្តល់ឥណទាន និងអ្នកសុំខ្ចីនៅមិនទាន់មាននៅឡើយ ហើយក្របខណ្ឌបទប្បញ្ញត្តិដែលអនុវត្តលើសកម្មភាពផ្តល់ឥណទាននាពេលបច្ចុប្បន្ន មិនមានចែងអំពីភាពខុសគ្នារវាងសកម្មភាពផ្តល់ឥណទានតាមបែបប្រពៃណី និងតាមបែបឌីជីថលឡើយ។

### ខ. បញ្ហាប្រឈម

ថ្នាលផ្តល់ឥណទានផ្អែកលើតារាងតុល្យការស្ថិតនៅក្រោមច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ប៉ុន្តែក្របខណ្ឌគតិយុត្តសម្រាប់ថ្នាលអន្តរការីយកម្មឥណទានឌីជីថលនៅមិនទាន់មាននៅឡើយ។ ការដាក់ចេញនូវក្របខណ្ឌបទប្បញ្ញត្តិដែលមានលក្ខណៈអំណោយផល នឹងជួយជំរុញការអភិវឌ្ឍថ្នាលហិរញ្ញប្បទានបច្ចេកវិទ្យាហិរញ្ញវត្ថុបន្ថែមទៀត ដោយសារថ្នាលបច្ចេកវិទ្យាហិរញ្ញវត្ថុមានសារៈសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ក៏ដូចជាបរិវត្តកម្មឌីជីថលនៅក្នុងវិស័យធនាគារ។ ដោយមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារជាតិនៃកម្ពុជាបានពិនិត្យលទ្ធភាពអភិវឌ្ឍថ្នាលអន្តរការីយកម្មឥណទានឌីជីថលនៅកម្ពុជា ដោយផ្តោតលើបទពិសោធន៍ប្រទេសនានានៅក្នុងតំបន់ ដើម្បីយកមកអនុវត្តឱ្យសមស្របនឹងទីផ្សារកម្ពុជា។ ធនាគារអភិវឌ្ឍន៍អាស៊ី នឹងផ្តល់អនុសាសន៍លើក្របខណ្ឌគតិយុត្ត និងគោលនយោបាយមួយចំនួនដូចជាទីផ្សារប្រកួតប្រជែង ឯកជនភាពទិន្នន័យ ការគ្រប់គ្រងហានិភ័យ អភិបាលកិច្ច និងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ ម្យ៉ាងទៀត បទប្បញ្ញត្តិស្តីពីថ្នាលអន្តរការីយកម្មឥណទានឌីជីថលនឹងមានលក្ខណៈស្របទៅនឹងបរិបទកម្ពុជា ដែលនឹងជំរុញឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។

## ៣. មូលធនក្រោដហ្វាន់ឌីង

នៅប្រទេសកម្ពុជា ការកៀរគរមូលធនតាមរយៈបច្ចេកវិទ្យាហិរញ្ញវត្ថុមានក្រោមរូបភាពជាមូលធនក្រោដហ្វាន់ឌីង។ មូលធនក្រោដហ្វាន់ឌីង សំដៅលើសកម្មភាពដែលវិនិយោគិនផ្តល់ទុនដល់គ្រឹះស្ថានឯកជនក្នុងទម្រង់ជាភាគហ៊ុន។ ថ្នាលបច្ចេកវិទ្យាហិរញ្ញវត្ថុនឹងជួយផ្គូផ្គងវិនិយោគិនជាមួយនឹងគ្រឹះស្ថានដែលខ្លួនមានបំណងវិនិយោគ ដើម្បីផ្តល់ទុនដល់ធុរកិច្ចថ្មី និងក្រុមហ៊ុនដទៃផ្សេងទៀតនៅក្នុងដំណាក់កាលបឋម។

កាលពីខែវិច្ឆិកា ឆ្នាំ២០១៥ Tos Fund ដែលជាថ្នាលក្រោដហ្វាន់ឌីងត្រូវបានដាក់ឱ្យដំណើរការក្នុងគោលបំណងប្រើប្រាស់មូលធនក្រោដហ្វាន់ឌីង ដើម្បីគាំទ្រដល់គម្រោងក្នុងវិស័យព័ត៌មានវិទ្យា

និងសិល្បៈ ប៉ុន្តែមិនមានប្រតិបត្តិការចាប់តាំងពីខែកក្កដា ឆ្នាំ២០១៦ មកម្ល៉េះ។ នាថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ Cambodian Investors Capital Partners Plc បានទទួលអាជ្ញាបណ្ណដំបូងពីនិយ័តករមូលបត្រកម្ពុជាលើគម្រោងវិនិយោគរួម សម្រាប់ថ្នាល "Phnom Penh-Based Crowd-Funding" ក្នុងគោលបំណងចែកចាយមូលធនវិនិយោគបន្តទៅឱ្យសហគ្រាសធុនតូចនិងមធ្យមដែលជួបប្រទះបញ្ហាហិរញ្ញវត្ថុ។ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ Gold Whale Co Ltd បានទទួលអាជ្ញាបណ្ណគ្រប់គ្រងមូលនិធិពីនិយ័តករមូលបត្រកម្ពុជាលើគម្រោងវិនិយោគរួមតាមរយៈប្រព័ន្ធអេឡិចត្រូនិក ដើម្បីគ្រប់គ្រងមូលនិធិសាធារណៈ និង/ឬឯកជន។

មូលធនក្រោដហ្វាន់ឌីងនៅប្រទេសកម្ពុជាត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពី "ការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន" ដែលបានដាក់ឱ្យប្រើនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ចំណែកការផ្តល់អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតសម្រាប់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ក្រុមហ៊ុនចែកចាយទិញ-លក់ត្រឡប់មកវិញ ឬទូទាត់សងប្រាក់ ក្រុមហ៊ុនអភិបាលមូលនិធិ ភ្នាក់ងារគ្រប់គ្រងមូលនិធិ ភ្នាក់ងារក្រោដហ្វាន់ឌីង និងភ្នាក់ងារចែកចាយលក់មូលនិធិ ស្ថិតនៅក្រោមគម្រោងវិនិយោគរួម ដែលបានដាក់ឱ្យប្រើកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨។ ដោយសារសកម្មភាពទាំងនេះពាក់ព័ន្ធនឹងការជួញដូរមូលបត្រ បច្ចេកវិទ្យាហិរញ្ញវត្ថុដែលផ្តល់មូលធនក្រោដ-ហ្វាន់ឌីងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់និយ័តករមូលបត្រកម្ពុជា។ បន្ថែមពីនេះ ទាំងបុគ្គលបោះផ្សាយមូលបត្រ និងអ្នកផ្តល់ថ្នាលបច្ចេកវិទ្យាហិរញ្ញវត្ថុត្រូវតែបំពេញតាមលក្ខខណ្ឌច្បាប់ឱ្យបានគ្រប់គ្រាន់មុននឹងអាចធ្វើប្រតិបត្តិការក្រោដហ្វាន់ឌីងនៅប្រទេសកម្ពុជា។ អនុលោមតាមមាត្រាទី២៣ នៃបទប្បញ្ញត្តិខាងលើ ថ្នាលបច្ចេកវិទ្យាហិរញ្ញវត្ថុដែលគាំទ្រការបោះផ្សាយ និងជួញដូរមូលបត្រត្រូវមានការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជា ដែលជាអ្នកសម្រេចអំពីប្រភេទអាជ្ញាបណ្ណផ្អែកលើបទប្បញ្ញត្តិពាក់ព័ន្ធ។

## ៤. សេវាបម្រើអតិថិជនស្វ័យប្រវត្តិ

ការប្រែប្រួលនៃបច្ចេកវិទ្យាបានជះឥទ្ធិពលយ៉ាងខ្លាំងមកលើការរស់នៅប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗ ជាពិសេសទៅលើការប្រាស្រ័យទាក់ទងគ្នាទាំងលក្ខណៈបុគ្គល និងជំនាញ។ អ្នកប្រើប្រាស់ចង់បាននូវការឆ្លើយតបដោះស្រាយយ៉ាងឆាប់រហ័សចំពោះបញ្ហាផ្សេងៗដែលបានជួបប្រទះ។ ធុរកិច្ចគ្រប់ប្រភេទត្រូវទទួលរងនូវសម្ពាធខ្លាំងក្នុងការឆ្លើយតបទៅនឹងបម្រែបម្រួលឥរិយាបទសង្គម ក៏ដូចជាក្នុងការធានាប្រសិទ្ធភាពធុរកិច្ច ដើម្បីមានលទ្ធភាពឈរជើងប្រកួតប្រជែងក្នុងទីផ្សារជាបន្តទៀត។

សេវាបម្រើអតិថិជនស្វ័យប្រវត្តិ សំដៅលើថ្នាលឌីជីថលដែលផ្តល់នូវការឆ្លើយតបដោះស្រាយបញ្ហាដោយស្វ័យប្រវត្តិ ដោយបំពាក់នូវក្បួនខ្នាតគណនារកដំណោះស្រាយ តាមអាល់ហ្គោរីសឹម ដែលប្រតិបត្តិការរបស់សេវានេះស្ទើរតែមិនមានការត្រួតពិនិត្យពីមនុស្ស។ ជាទូទៅ សេវាបម្រើអតិថិជនស្វ័យប្រវត្តិធ្វើការប្រមូលនូវទិន្នន័យអតិថិជនទាក់ទងនឹងស្ថានភាព និងគោលបំណងតាមរយៈការស្ទង់មតិអនឡាញ ហើយក៏ប្រើប្រាស់ធាតុចូលទាំងនេះគណនារកដំណោះស្រាយ ដើម្បីជាការណែនាំសម្រាប់អតិថិជន។ ជាមួយនឹងការរីកចម្រើននៃបច្ចេកវិទ្យា ការប្រើប្រាស់សេវាបម្រើអតិថិជនស្វ័យប្រវត្តិ ឬការសន្ទនាស្វ័យប្រវត្តិមានការកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ គ្រឹះស្ថានជាច្រើន

ចាប់ផ្តើមប្រើប្រាស់បច្ចេកវិទ្យានេះ ដើម្បីគាំទ្រដល់ការរីកចម្រើននៃធុរកិច្ច ក៏ដូចជាជួយពង្រឹងផលិតភាព និងប្រសិទ្ធភាពបន្ថែមទៀតជូនអតិថិជន។ ស្របពេលជាមួយគ្នានេះដែរ ការកើនឡើងនៃការប្រើប្រាស់ទូរស័ព្ទវៃឆ្លាត និងកម្មវិធីបណ្តាញសង្គមជាច្រើនបានក្លាយជាចលករមួយដ៏សំខាន់ ក្នុងការជំរុញឱ្យគ្រឹះស្ថានដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យានេះបម្រើនៅក្នុងដំណើរការធុរកិច្ចរបស់ខ្លួន។

សេវាបម្រើអតិថិជនស្វ័យប្រវត្តិ ជាសកម្មភាពថ្មីមួយនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែបច្ចេកវិទ្យាហិរញ្ញវត្ថុដែលធ្វើប្រតិបត្តិការនៅក្នុងវិស័យនេះមានចំនួនតិច ហើយការប្រើប្រាស់សេវាកម្មនេះនៅក្នុងវិស័យហិរញ្ញវត្ថុមិនទាន់មានភាពទូលំទូលាយ។ ថ្មីៗនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អេ អឹម ខេ បានដាក់ដំណើរការសេវាបម្រើអតិថិជនស្វ័យប្រវត្តិ ឬប្រអប់សន្ទនាស្វ័យប្រវត្តិ ដើម្បីបម្រើដល់អតិថិជនរបស់ខ្លួនស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល និងការផ្លាស់ប្តូរឥរិយាបទរស់នៅប្រចាំថ្ងៃ។ សេវាបម្រើអតិថិជនស្វ័យប្រវត្តិនេះ ផ្តល់នូវអត្ថប្រយោជន៍ច្រើនចំពោះអតិថិជន និងគ្រឹះស្ថានផ្តល់សេវាតាមរយៈការធ្វើប្រតិបត្តិការ ២៤ម៉ោង/៧ថ្ងៃ ដោយមិនតម្រូវឱ្យអតិថិជនធ្វើការតម្រង់ជួរនៅតាមបញ្ជរសាខា ដែលកត្តានេះជួយបង្កើនប្រសិទ្ធភាពចំពោះផលិតផលនិងសេវា និងកាត់បន្ថយការប្រើប្រាស់ធនធានមនុស្សច្រើនក្នុងការបម្រើសេវាអតិថិជន។

## ៥. រូបិយវត្ថុអេឡិចត្រូនិក និងសេវាទូទាត់សងប្រាក់ឌីជីថល

### ក. ស្ថានភាពបច្ចុប្បន្ន

សេវាទូទាត់សងប្រាក់ឌីជីថលមានការរីកចម្រើនជាលំដាប់នៅក្នុងប្រទេសកម្ពុជា ដោយបានធ្វើការផ្លាស់ប្តូរនូវប្រព័ន្ធធនាគារឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល។ ការកើនឡើងនូវចំនួនគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ គ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុបានជំរុញឱ្យមានការប្រកួតប្រជែង និងពង្រីកសេវាហិរញ្ញវត្ថុឌីជីថលការកាន់តែទូលំទូលាយនៅក្នុងប្រទេស។ បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យទូទាត់សងប្រាក់ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិស្តីពី "ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់" ដែលអនុញ្ញាតឱ្យធ្វើប្រតិបត្តិការដូចជា ការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក ផ្ទេរប្រាក់ ដាក់/ដកប្រាក់ សេវាទូទាត់រាយ ទូទាត់វិក្កយបត្រ ទូទាត់អនឡាញ ផ្ទេរប្រាក់ឆ្លងដែន និងការទូទាត់តាមគម្រោងទូទាត់អន្តរជាតិ។ គិតត្រឹមឆ្នាំ២០២០ មានគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន ២៨ គ្រឹះស្ថានទទួលបានអាជ្ញាបណ្ណធ្វើប្រតិបត្តិការទូទាត់សងប្រាក់ពីធនាគារជាតិនៃកម្ពុជា ដោយបានចេញផ្សាយគណនីរូបិយវត្ថុអេឡិចត្រូនិកចំនួន ៣,៦ លានគណនី ផ្តល់នូវបណ្តាញភ្នាក់ងារទូទាត់សងប្រាក់ចំនួន ៣១.៦៤៣ ទីតាំង និងពាណិជ្ជករទូទាត់រាយចំនួន ១៩.១២៧ ទីតាំង។ សមតុល្យនៃគណនីរូបិយវត្ថុអេឡិចត្រូនិកដែលបានចេញផ្សាយគិតជាមធ្យមមានចំនួន ៥,៦ លានដុល្លារអាមេរិក និងទំហំប្រាក់ធ្វើប្រតិបត្តិការបានកើនឡើងរហូតដល់ចំនួន ៥,៦ ប៊ីលានដុល្លារអាមេរិក។ ជាមួយគ្នានេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏បានចូលរួមយ៉ាងសកម្មនៅក្នុងការទូទាត់សងប្រាក់ឌីជីថល។ គ្រឹះស្ថានមួយចំនួនបានចេញផ្សាយគណនីរូបិយវត្ថុអេឡិចត្រូនិកបន្ថែមពីលើគណនីធនាគារជូនអ្នកប្រើប្រាស់ និងផ្តល់សេវាទូទាត់ផ្សេងៗមានលក្ខណៈប្រហាក់ប្រហែលនឹងសេវាកម្មដែលផ្តល់ដោយគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។ សេវាទូទាត់សងប្រាក់ឌីជីថលដែលផ្តល់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានការកើនឡើងចំនួន ៣៥,២% ធៀបនឹងឆ្នាំមុន ជាមួយនឹងទំហំប្រាក់រហូតដល់ ៣៨ ប៊ីលានដុល្លារ

អាមេរិក ក្នុងឆ្នាំ២០២០។ បើទោះបីជាសេវាទូទាត់សងប្រាក់ឌីជីថលដែលផ្តល់ដោយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់មានលក្ខណៈប្រហាក់ប្រហែលគ្នា ចំណែកទីផ្សារ និងអ្នកប្រើប្រាស់គោលដៅនៃគ្រឹះស្ថានទាំងនេះនៅតែមានភាពខុសគ្នាយ៉ាងខ្លាំង។ គ្រឹះស្ថានធនាគារផ្តោតសំខាន់លើអ្នកប្រើប្រាស់ដែលមានលទ្ធភាពប្រើប្រាស់សេវាកម្មធនាគារ ចំណែកឯគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ផ្តោតលើអ្នកប្រើប្រាស់ដែលមិនមានលទ្ធភាពប្រើប្រាស់សេវាកម្មធនាគារ។ ទំហំប្រតិបត្តិការទូទាត់សងប្រាក់នៅក្នុងឆ្នាំ២០២០ ដែលដំណើរការដោយគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់បានកើនឡើងយ៉ាងខ្លាំងរហូតដល់ ១៦១,៩% ធៀបនឹងផលិតផលក្នុងស្រុកសរុប។ លទ្ធផលទាំងនេះបានបង្ហាញឱ្យឃើញពីសារៈសំខាន់នៃសេវាទូទាត់សងប្រាក់ឌីជីថលនៅក្នុងវិស័យធនាគារ។

### ខ. បញ្ហាប្រឈម

ក្របខណ្ឌគតិយុត្តដែលមានពាក់ព័ន្ធនឹងសេវាទូទាត់សងប្រាក់ឌីជីថល បានដាក់ចេញនូវគោលការណ៍គ្រប់គ្រងហានិភ័យចម្បងៗរួចទៅហើយ រួមមាន ការគ្រប់គ្រងអភិបាលកិច្ច ការការពារសុវត្ថិភាពមូលនិធិ ការកម្រិតដើមទុនអប្បបរមា ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ ដូចជា ក្របខណ្ឌសន្តិសុខសាយប័រ កិច្ចការពារអ្នកប្រើប្រាស់ និងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មជាដើម។ ទោះជាយ៉ាងណា ការកើនឡើងនៃចំនួនគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងប្រតិបត្តិការទូទាត់សងប្រាក់ ទាមទារឱ្យមានការធ្វើបច្ចុប្បន្នកម្មនូវក្របខណ្ឌគតិយុត្ត ក្នុងគោលដៅបង្កលក្ខណៈងាយស្រួលដល់ការរីកចម្រើន ក៏ដូចជាគ្រប់គ្រងនូវហានិភ័យថ្មីៗឱ្យមានប្រសិទ្ធភាព។ ចំពោះការបង្កលក្ខណៈងាយស្រួលដល់ការទូទាត់សងប្រាក់ឌីជីថលប្រកបដោយនវានុវត្តន៍ ការដាក់ចេញនូវគោលនយោបាយសំខាន់ៗមានភាពចាំបាច់ដូចជា ការប្រើប្រាស់អត្តសញ្ញាណឌីជីថល ការដាក់ឱ្យដំណើរការថ្នាលប្រតិបត្តិការទូទាត់ឆ្លងអន្តរគ្រឹះស្ថាន និងការបើកទូលាយឱ្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធកណ្តាលសម្រាប់ប្រតិបត្តិការជាត់ទាត់ និងទូទាត់សងប្រាក់។ ចំពោះការគ្រប់គ្រងហានិភ័យថ្មីៗប្រកបដោយប្រសិទ្ធភាព ត្រូវផ្តោតលើគំរូធុរកិច្ចថ្មី និងភាពប្រទាក់ក្រឡានៃកិច្ចសហការរវាងគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។

## ៦. បច្ចេកវិទ្យាធានារ៉ាប់រង

នៅក្នុងឆ្នាំ២០១៤ BIMA ជាក្រុមហ៊ុនដំបូងដែលបានដាក់ឱ្យដំណើរការបច្ចេកវិទ្យាធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជា។ BIMA តាមរយៈការចាប់ដៃគូសហការជាមួយក្រុមហ៊ុនទូរស័ព្ទចល័ត SMART AXIATA BIMA បានផ្តល់សេវាធានារ៉ាប់រងតាមទូរស័ព្ទចល័តក្រោមកម្មវិធី "Smart Life Insurance" សម្រាប់អ្នកប្រើប្រាស់របស់ក្រុមហ៊ុន SMART AXIATA ។ បច្ចុប្បន្ននេះ BIMA បានផ្តល់សេវាធានារ៉ាប់រងជាច្រើនតាមរយៈទូរស័ព្ទចល័ត រួមមាន សេវាធានារ៉ាប់រងអាយុជីវិត ឧបទ្ទវហេតុ និងសុខភាព។ បន្ទាប់មក ការចាប់ដៃគូសហការជាមួយនឹងបច្ចេកវិទ្យាធានារ៉ាប់រងមានការកើនឡើងជាបន្តបន្ទាប់។ នៅក្នុងខែកញ្ញា ឆ្នាំ២០១៨ ក្រុមហ៊ុន IG AETINS CAMBODIA ត្រូវបានបង្កើតឡើងដើម្បីផ្គត់ផ្គង់នូវបច្ចេកវិទ្យាសម្រាប់សម្រួលដល់ដំណើរការរបស់គ្រឹះស្ថានផ្តល់សេវាធានារ៉ាប់រង។ ក្នុងខែមីនា ឆ្នាំ២០១៩ គ្រឹះស្ថានផ្តល់សេវាធានារ៉ាប់រង CAMBODIA LIFE INSURANCE បានធ្វើសេចក្តីប្រកាសអំពីការផ្តល់

សេវាធានារ៉ាប់រងខ្នាតតូចលើអាយុជីវិត និងសុខភាពតាមរយៈទូរស័ព្ទដៃវៃឆ្លាត ដោយបានចាប់ដៃគូសហការជាមួយក្រុមហ៊ុន DEMOCRANCE UAE និងក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចល័ត CELLCARD។

## ៧. ទ្រព្យសកម្មគ្រីបតូ និងសកម្មភាពពាក់ព័ន្ធ

យោងតាមធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) ទ្រព្យសកម្មគ្រីបតូត្រូវបានឱ្យនិយមន័យថាជាទ្រព្យសកម្មមួយប្រភេទដែលធ្វើប្រតិបត្តិការផ្អែកលើបច្ចេកវិទ្យាគ្រីបតូក្រាហ្វី និងបច្ចេកវិទ្យាឌីអិលធី ឬបច្ចេកវិទ្យាដទៃទៀតដែលមានលក្ខណៈប្រហាក់ប្រហែល។ ការឱ្យនិយមន័យនេះ រួមបញ្ចូលនូវមធ្យោបាយទូទាត់សងប្រាក់ឌីជីថល និងកាសឌីជីថលផ្សេងទៀត។ ការកំណត់ចរិតលក្ខណៈរបស់ទ្រព្យសកម្មគ្រីបតូផ្អែកលើកត្តាផ្សេងៗជាច្រើនដូចជា គោលបំណងនៃការចេញផ្សាយមុខងារមូលដ្ឋានផ្នែកសេដ្ឋកិច្ច និងមូលដ្ឋានទ្រព្យសកម្មជាដើម។ ហេតុដូចនេះ កង្វះអត្តសញ្ញាណរួមនៃទ្រព្យសកម្មគ្រីបតូ ជាឧបសគ្គសម្រាប់និយ័តករក្នុងការដាក់ចេញនូវបទប្បញ្ញត្តិសមស្របសម្រាប់គ្រប់គ្រង។ ទ្រព្យសកម្មគ្រីបតូ បង្កនូវហានិភ័យជាច្រើន រួមមាន ហានិភ័យសន្ទនីយភាព ហានិភ័យឥណទាន ហានិភ័យទីផ្សារ ហានិភ័យការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ហានិភ័យគតិយុត្ត និងហានិភ័យកេរ្តិ៍ឈ្មោះ។ ការដាក់ចេញបទប្បញ្ញត្តិ និងគោលនយោបាយលើទ្រព្យសកម្មគ្រីបតូមានលក្ខណៈខុសៗគ្នាទៅតាមប្រទេសនីមួយៗ នៅក្នុងករណីមួយចំនួនធំ អាជ្ញាធរពាក់ព័ន្ធបានធ្វើការហាមឃាត់ជាសាធារណៈអំពីការចរាចរ និងការជួញដូរទ្រព្យសកម្មនេះ និងចំណែកករណីខ្លះទៀត អាជ្ញាធរបានចេញសេចក្តីថ្លែងការណ៍ និងដាក់ចេញនូវវិធានការគោលនយោបាយផ្សេងៗ ដើម្បីបញ្ជាក់ពីការអនុវត្តបទប្បញ្ញត្តិទៅលើទ្រព្យសកម្មគ្រីបតូទាំងនេះ និងសកម្មភាពពាក់ព័ន្ធនានា។

នៅប្រទេសកម្ពុជា ក្របខណ្ឌបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងទ្រព្យសកម្មគ្រីបតូនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ។ កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជា និយ័តករមូលបត្រកម្ពុជា និងអគ្គស្នងការនគរបាលជាតិ បានចេញសេចក្តីថ្លែងការណ៍រួមអំពីហានិភ័យពាក់ព័ន្ធប្រតិបត្តិការទ្រព្យសកម្មគ្រីបតូដល់សាធារណជន និងហាមឃាត់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុធ្វើការទទួលយក និងការជួញដូរដោយផ្ទាល់ឬដោយប្រយោលទៅលើទ្រព្យសកម្មគ្រីបតូ។ ស្របពេលជាមួយគ្នានេះដែរ អាជ្ញាធរពាក់ព័ន្ធកំពុងរៀបចំដាក់ចេញបទប្បញ្ញត្តិសមស្របសម្រាប់ទ្រព្យសកម្មគ្រីបតូនេះផងដែរ។

# II. បច្ចេកវិទ្យាគាំទ្រ

## ១. សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ

### ក. ស្ថានភាពបច្ចុប្បន្ន

សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ សំដៅលើបច្ចេកទេសសន្ទានកម្មសម្រាប់កម្មវិធីសូហ្វវែរ ដែលបច្ចុប្បន្នកំពុងវិវត្តកាន់តែទំនើប និងក្លាយជាធាតុសំខាន់មួយរបស់ប្រព័ន្ធអ៊ីនធឺណិតនៃបរិក្ខារដែលត្រូវបានយកទៅប្រើប្រាស់ជាមួយឧបករណ៍ឆ្លាតវៃ ដើម្បីផ្តល់ដំណោះស្រាយដល់អ្នកប្រើប្រាស់។ តាមរយៈនេះ សន្ទានកម្មនៃកម្មវិធីកុំព្យូទ័របានធ្វើឱ្យការតភ្ជាប់ប្រព័ន្ធរវាងភាគីពាក់ព័ន្ធកាន់តែមាន

ភាពងាយស្រួល និងប្រសិទ្ធភាពបន្ថែមទៀត។ បច្ចុប្បន្ននេះ ការប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័របានផ្លាស់ប្តូរនូវរបៀបរបបនៃសេវាធនាគារជាសកល។ នៅក្នុងបរិបទធនាគារ ការធ្វើសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រជួយសម្រួលតតិយភាគីឱ្យមានលទ្ធភាពចូលទៅតភ្ជាប់ប្រព័ន្ធរួមរបស់ធនាគារ ដើម្បីប្រើប្រាស់សេវាធនាគារ និងពិនិត្យលើព័ត៌មានសំខាន់ៗដូចជា ព័ត៌មានហិរញ្ញវត្ថុ គណនីអ្នកប្រើប្រាស់ និងប្រភេទនៃផលិតផលនិងសេវាកម្មនានា។ សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រនាំឱ្យការតភ្ជាប់ប្រព័ន្ធរវាងធនាគារ និងតតិយភាគីកាន់តែរហ័ស ងាយស្រួល និងចំណាយទាប។ ការសម្របសម្រួលដល់ការទទួលបានទិន្នន័យសំខាន់ៗនឹងនាំឱ្យអ្នកប្រើប្រាស់ទទួលបាននូវសេវាធនាគារល្អប្រសើរជាងមុន នៅពេលធ្វើប្រតិបត្តិការហិរញ្ញវត្ថុ។ ជាឧទាហរណ៍ សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រអាចវិភាគលើសំណុំទិន្នន័យប្រតិបត្តិការ ដើម្បីជ្រើសរើសការផ្តល់សេវាហិរញ្ញវត្ថុដែលសមស្របនឹងតម្រូវការរបស់អ្នកប្រើប្រាស់ដូចជា ការបន្ថយអត្រាការប្រាក់លើប័ណ្ណឥណទាន ការផ្តល់កម្ចីស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់ ឬការផ្តល់អត្រាការប្រាក់ខ្ពស់សម្រាប់គណនីសន្សំ។

នាពេលថ្មីៗនេះ អាជ្ញាធរបានយកចិត្តទុកដាក់លើសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ ដោយសារបច្ចេកវិទ្យាមួយនេះជាមធ្យោបាយក្នុងការផ្តល់អន្តរការីយកម្មរវាងគ្រឹះស្ថានធនាគារ និងតតិយភាគីក្នុងការចែករំលែកព័ត៌មានរបស់អ្នកប្រើប្រាស់ ដែលជាបញ្ហាប្រឈមទាក់ទងនឹងសុវត្ថិភាពទិន្នន័យ។ អាជ្ញាធរក្នុងប្រទេសមួយចំនួនបានតម្រូវឱ្យគ្រឹះស្ថានធនាគារបង្កើតនូវយន្តការដើម្បីផ្តល់លទ្ធភាពឱ្យតតិយភាគីចូលប្រើប្រាស់ទិន្នន័យ ហើយអាជ្ញាធរមួយចំនួនទៀតបានដាក់ចេញគោលការណ៍ណែនាំដើម្បីលើកទឹកចិត្ត និងសម្របសម្រួលក្នុងការអនុវត្តសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ ដើម្បីជំរុញឱ្យមាននវានុវត្តន៍នៃសេវាហិរញ្ញវត្ថុ។ នៅក្នុងប្រទេសកម្ពុជា គ្រឹះស្ថានធនាគារភាគច្រើនកំពុងប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រនៅក្នុងប្រតិបត្តិការរបស់ខ្លួន ជាពិសេសប្រតិបត្តិការផ្ទេរប្រាក់ ទូទាត់វិក្កយបត្រ និងការពិនិត្យលើព័ត៌មានគណនី។

## ខ. បញ្ហាប្រឈម

បច្ចុប្បន្ននេះ ប្រទេសកម្ពុជានៅពុំទាន់មានគោលការណ៍ណែនាំជាផ្លូវការណាមួយក្នុងការគ្រប់គ្រងសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រនៅឡើយ។ កង្វះស្តង់ដារ និងគោលការណ៍ណែនាំបានរារាំងដល់ការអភិវឌ្ឍ និងការអនុវត្តបច្ចេកវិទ្យាសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ ដែលនាំឱ្យមានការរាំងស្ទះដល់ការធ្វើអន្តរប្រតិបត្តិការនិងសុវត្ថិភាពទិន្នន័យក្នុងវិស័យធនាគារ។ ជាទូទៅ គ្រឹះស្ថានធនាគារបានបង្កើតសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រសម្រាប់ប្រើប្រាស់ផ្ទៃក្នុង និងជាមួយដៃគូតែប៉ុណ្ណោះ។ សន្ទានកម្មនៃកម្មវិធីកុំព្យូទ័របង្កើតឡើងទៅតាមគំរូទិន្នន័យ និងគំរូបច្ចេកវិទ្យា/ថ្នាលរបស់គ្រឹះស្ថាននីមួយៗដែលបង្កើតឱ្យមានភាពស្មុគស្មាញលើមុខងារប្រើប្រាស់ប្រហាក់ប្រហែលគ្នា។ ទោះជាការអភិវឌ្ឍសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រនៅក្នុងគ្រឹះស្ថាននីមួយៗមានភាពចាំបាច់ ការងារនេះនឹងបណ្តាលឱ្យមានការអភិវឌ្ឍច្រើន ហើយមានការចំណាយខ្ពស់។ ដូចនេះ ការបង្កើតឱ្យមានស្តង់ដារសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រនឹងផ្តល់អត្ថប្រយោជន៍សំខាន់ៗជាច្រើន។ បន្ថែមលើនេះ ការដាក់ចេញស្តង់ដារសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រនៅក្នុងវិស័យហិរញ្ញវត្ថុ បង្កឱ្យមានបរិយាកាសល្អប្រសើរសម្រាប់បច្ចេកវិទ្យាហិរញ្ញវត្ថុបង្កើតនូវដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតសម្រាប់អ្នកប្រើប្រាស់។

## ២. បញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សា

### ក. ស្ថានភាពបច្ចុប្បន្ន

បញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សា ជាផ្នែកមួយនៃវិទ្យាសាស្ត្រកុំព្យូទ័រដែលមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក។ បច្ចេកវិទ្យាទាំងពីរនេះ ជាបច្ចេកវិទ្យាដែលមានការនិយមបំផុតប្រើប្រាស់សម្រាប់បង្កើតប្រព័ន្ធវៃឆ្លាត។ ជាទូទៅ បញ្ញាសិប្បនិម្មិតជាទស្សនទានធំក្នុងការបង្កើតម៉ាស៊ីនស្វ័យសិក្សាដែលមានលទ្ធភាពក្នុងការត្រាប់តាមការគិត និងឥរិយាបថរបស់មនុស្ស ចំណែកម៉ាស៊ីនស្វ័យសិក្សាជាកម្មវិធីឬសំណុំរងរបស់បញ្ញាសិប្បនិម្មិត ដែលបើកលទ្ធភាពឱ្យម៉ាស៊ីនសិក្សាពីទិន្នន័យដោយមិនចាំបាច់ធ្វើកម្មវិធីណាមួយជាក់លាក់។ បញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សាត្រូវបានយកប្រើប្រាស់នៅក្នុងវិស័យហិរញ្ញវត្ថុ ក្នុងនោះមានការបង្កើតជាកម្មវិធី និងប្រតិបត្តិការប្រើប្រាស់ជាច្រើនរួចមកហើយ ការប្រើប្រាស់បច្ចេកវិទ្យានេះត្រូវបានជំរុញដោយកត្តាផ្គត់ផ្គង់ និងតម្រូវការ។ កត្តាផ្គត់ផ្គង់សំដៅលើការរីកចម្រើនផ្នែកបច្ចេកវិទ្យា ព្រមទាំងទំហំទិន្នន័យ និងហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យហិរញ្ញវត្ថុ ចំណែកកត្តាតម្រូវការសំដៅលើតម្រូវការប្រាក់ចំណេញ ការប្រកួតប្រជែងជាមួយស្ថាប័នដទៃទៀត និងការអនុវត្តតាមបទប្បញ្ញត្តិហិរញ្ញវត្ថុ។ បញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សាត្រូវបានដាក់ឱ្យប្រើប្រាស់លើប្រតិបត្តិការដូចជា ការវាយតម្លៃគុណភាពឥណទាន ការប្រាស្រ័យទាក់ទងដោយស្វ័យប្រវត្តិជាមួយអ្នកប្រើប្រាស់ ការរៀបចំកិច្ចព្រមព្រៀងជួញដូរ ការអនុវត្តតាមបទប្បញ្ញត្តិ ការឃ្លាំមើល និងការការពារការក្លែងបន្លំ។

ទោះបីជាបញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សាបានផ្តល់អត្ថប្រយោជន៍ក្នុងការបង្កើតផលិត-ផលនិងសេវាកម្មក៏ដោយ បច្ចេកវិទ្យាទាំងពីរនេះមានបញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យហានិភ័យ ដែលចាំបាច់ត្រូវប្រកាន់ខ្ជាប់គោលការណ៍ពាក់ព័ន្ធនឹងឯកជនភាពទិន្នន័យ ការការពារអ្នកប្រើប្រាស់ និងក្របខណ្ឌសន្តិសុខសាយប័រ។ ជារួម ការប្រើប្រាស់បញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សាផ្តល់នូវសក្តានុពលខ្ពស់ ប្រសិនបើហានិភ័យត្រូវបានគ្រប់គ្រងឱ្យបានត្រឹមត្រូវ។ បច្ចុប្បន្ន បទប្បញ្ញត្តិពាក់ព័ន្ធការប្រើប្រាស់បញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សាសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ។ អាជ្ញាធរមួយចំនួនបានដាក់ចេញនូវគោល-ការណ៍មិនចងជាកាតព្វកិច្ច ដើម្បីជំរុញការប្រើប្រាស់បញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សាដោយគ្រឹះស្ថានហិរញ្ញវត្ថុប្រកបដោយក្រមសីលធម៌ និងមានទំនួលខុសត្រូវ ដែលមានវិសាលភាពគ្របដណ្តប់លើអភិបាលកិច្ច ស្មើភាព សីលធម៌ គណនេយ្យភាព និងតម្លាភាព។ នៅក្នុងប្រទេសកម្ពុជា ការដាក់ឱ្យប្រើប្រាស់បញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សាស្ថិតក្នុងដំណាក់កាលបឋម ដែលផ្តោតលើប្រតិបត្តិការតាមដានការក្លែងបន្លំដោយស្វ័យប្រវត្តិ និងសុវត្ថិភាពព័ត៌មានវិទ្យាដូចជា ករណីធនាគារអេស៊ីលីដា និងធនាគារភ្នំពេញពាណិជ្ជ ចំណែកគ្រឹះស្ថានមួយចំនួនទៀតបានសាកល្បងប្រើប្រាស់បច្ចេកវិទ្យានេះ ប៉ុន្តែពុំទទួលបានជោគជ័យក្នុងការបង្កើតជាប្រតិបត្តិការប្រើប្រាស់ជាក់ស្តែង។ គ្រឹះស្ថានមួយចំនួនធំពិនិត្យឃើញថា ប្រព័ន្ធបច្ចេកវិទ្យានេះនៅមិនទាន់មានភាពចាំបាច់សម្រាប់សកម្មភាពធុរកិច្ច និងសមស្របសម្រាប់ការវិនិយោគនោះទេ។

### ខ. បញ្ហាប្រឈម

បច្ចុប្បន្ន បច្ចេកវិទ្យាហិរញ្ញវត្ថុផ្តល់សេវាកម្មពាក់ព័ន្ធនឹងបញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សានៅពុំទាន់មាននៅឡើយ។ គ្រឹះស្ថានហិរញ្ញវត្ថុដែលប្រើប្រាស់បច្ចេកវិទ្យានេះ បានទទួលការសហការជាមួយនឹងដៃគូផ្សេងទៀត។ គ្រឹះស្ថានមួយចំនួនធំពិនិត្យឃើញថា ការប្រើប្រាស់បច្ចេកវិទ្យានេះនៅមិនទាន់សមស្របតាមសកម្មភាពធុរកិច្ចបច្ចុប្បន្ននៅឡើយ ហើយការចំណាយលើការវិនិយោគមានកម្រិតច្រើនលើសលប់ពីអត្ថប្រយោជន៍ដែលនឹងទទួលបាន។ លើសពីនេះ ទំហំទិន្នន័យមានភាពមិនគ្រប់គ្រាន់ក្នុងការដាក់ចេញប្រតិបត្តិការប្រើប្រាស់នៅក្នុងវិស័យហិរញ្ញវត្ថុ។ បច្ចុប្បន្ន បទប្បញ្ញត្តិពាក់ព័ន្ធបញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សានៅពុំទាន់មានចែងច្បាស់លាស់លើបញ្ហាដូចជា ការទទួលខុសត្រូវរបស់ភ្នាក់ងារសិប្បនិម្មិតក្នុងករណីមានគ្រោះថ្នាក់ និងការបង្កើតឱ្យមានភាពមិនប្រក្រតីឬភាពលំអៀងនៅពេលដែលការសម្រេចចិត្តធ្វើឡើងដោយស្វ័យប្រវត្តិ។ ផលវិបាកបណ្តាលមកពីការប្រើប្រាស់បច្ចេកវិទ្យាអាចនឹងកើតមានឡើង ដែលតម្រូវឱ្យមានវិធានការដើម្បីកាត់បន្ថយហានិភ័យដូចជា ការដាក់ចេញនូវគោលការណ៍ស្តីពីបញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សាដែលផ្តោតលើក្រមសីលធម៌ និងអភិបាលកិច្ច។ ដូច្នេះ ការពិចារណាក្នុងការដាក់ចេញនូវគោលការណ៍ត្រឹមត្រូវនិងច្បាស់លាស់ នឹងជំរុញឱ្យមានការប្រើប្រាស់បញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សាប្រកបដោយទំនួលខុសត្រូវខ្ពស់ក្នុងវិស័យហិរញ្ញវត្ថុ។

## ៣. បច្ចេកវិទ្យាជីវមាត្រសម្រាប់ការកំណត់ និងផ្ទៀងផ្ទាត់អត្តសញ្ញាណ

### ក. ស្ថានភាពបច្ចុប្បន្ន

បច្ចេកវិទ្យាជីវមាត្រ ជាវិធីសាស្ត្រស្វ័យប្រវត្តិមួយដែលប្រើប្រាស់ក្នុងការចំណាំ និងសម្គាល់អ្នកប្រើប្រាស់ តាមរយៈជីវសាស្ត្រនៃបុគ្គលិកលក្ខណៈ និងចរិតលក្ខណៈដែលមានដូចជា ក្រយៅម្រាមដៃ លំនាំសរសៃម្រាមដៃ ប្រស្រីភ្នែក (iris) និងសំលេង។ បច្ចេកវិទ្យាជីវមាត្រមានលក្ខណៈពិសេសដាច់ដោយឡែកពីគ្នាសម្រាប់បុគ្គលម្នាក់ៗ និងពិបាកក្នុងការក្លែងបន្លំ ហើយនេះជាមូលហេតុដែលការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវតាមរយៈបច្ចេកវិទ្យាជីវមាត្រត្រូវបានយកមកប្រើប្រាស់ជាប្រចាំលើការគ្រប់គ្រងអន្តោប្រវេសន៍ ការអនុវត្តច្បាប់ និងការសិក្សាផ្នែកកោសល្យវិច្ច័យ។ គ្រឹះស្ថានធនាគារមួយចំនួនធំនៅជុំវិញពិភពលោក បាននិងកំពុងដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាជីវមាត្រនៅក្នុងប្រព័ន្ធរបស់ធនាគារ ដើម្បីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវរបស់និយោជិត និងអ្នកប្រើប្រាស់របស់ខ្លួន។

ការប្រើប្រាស់បច្ចេកវិទ្យាជីវមាត្រសម្រាប់ការធ្វើអត្តសញ្ញាណកម្មអ្នកប្រើប្រាស់ និងការផ្ទៀង-ផ្ទាត់ភាពត្រឹមត្រូវពីចម្ងាយនៅក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ស្ថិតនៅដំណាក់កាលបឋមនៅឡើយ។ ជាទូទៅការចុះឈ្មោះដំបូង ឬចុះឈ្មោះសារជាថ្មីជាមួយនឹងលេខទូរស័ព្ទ/គណនីថ្មី តម្រូវឱ្យបញ្ចូលលេខឬពាក្យសម្ងាត់តែមួយដងសម្រាប់អនុញ្ញាត និងកំណត់អត្តសញ្ញាណម្ចាស់គណនីនិង/ឬលេខទូរស័ព្ទ ដើម្បីប្រើប្រាស់សេវាធនាគារឌីជីថលមានដូចជា ការប្រើប្រាស់សេវាធនាគារចល័ត ឬការទូទាត់សងប្រាក់ចល័ត។

ការសម្គាល់តាមរយៈក្រយៅម្រាមដៃ ឬទម្រង់ផ្ទៃមុខដែលមានស្រាប់នៅក្នុងទូរស័ព្ទដៃ ដើម្បីភ្ជាប់នឹងសេវាធនាគារឌីជីថលជំនួសឱ្យការដាក់បំពេញលេខកូដ ឬពាក្យសម្ងាត់ដដែលរាល់ពេលប្រើប្រាស់ម្តងៗធ្វើឱ្យមានភាពងាយស្រួលជាងមុន។ ទោះជាយ៉ាងណាក្តី ដោយសារតែបច្ចេកវិទ្យាសម្គាល់ជីវមាត្រដែលមានស្រាប់នៅក្នុងទូរស័ព្ទដៃ នៅមិនទាន់បានទទួលស្គាល់ដោយអាជ្ញាធរនៅឡើយ ការបំពេញលេខកូដ ឬពាក្យសម្ងាត់នៅតែតម្រូវឱ្យមានមុននឹងឈានដល់ការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការហិរញ្ញវត្ថុណាមួយ។ ដោយសារប្រព័ន្ធបច្ចុប្បន្នមានលក្ខណៈផ្តាច់មុខ និងមិនទាន់មានយន្តការសម្គាល់អត្តសញ្ញាណកម្មឌីជីថលជារួមនៅកម្ពុជានៅឡើយ ដូច្នេះ កង្វះហេដ្ឋារចនាសម្ព័ន្ធរួមបានរារាំងវិស័យធនាគារក្នុងការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាជីវមាត្រយ៉ាងទូលំទូលាយ។

### ខ. បញ្ហាប្រឈម

ក្នុងវិស័យធនាគារ ការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាជីវមាត្រស្ថិតក្នុងដំណាក់កាលបឋមនៅឡើយ ជាពិសេសសម្រាប់ផលិតផល និងសេវាកម្មមួយចំនួនដូចជា ការទូទាត់ចល័ត និងម៉ាស៊ីនដាក់/ដកប្រាក់ដោយស្វ័យប្រវត្តិ (ATM) ដោយសារប្រតិបត្តិការផ្គត់ផ្គង់បច្ចេកវិទ្យានេះមានចំនួនតិច ហើយគ្រឹះស្ថានធនាគារក៏មិនទាន់មានតម្រូវការ។ ទោះបីជាមានគ្រឹះស្ថានមួយចំនួនមានគម្រោងបង្កើតនិងប្រើប្រាស់បច្ចេកវិទ្យាជីវមាត្រ ប្រព័ន្ធដែលនឹងបង្កើតឡើងមានលក្ខណៈផ្តាច់មុខ ខុសប្លែកពីការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរួម ដែលអាចឱ្យគ្រឹះស្ថានដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាបានឆាប់រហ័ស និងងាយស្រួលក្នុងការប្រើប្រាស់។

បច្ចុប្បន្ន ក្របខណ្ឌបទប្បញ្ញត្តិស្តីពីការដាក់ឱ្យប្រើប្រាស់ទិន្នន័យជីវមាត្រក្នុងការកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់ពីចម្ងាយសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុនៅមិនទាន់មាននៅឡើយ ប៉ុន្តែជាការអនុវត្តជាក់ស្តែង ការអនុញ្ញាតឱ្យមានការទទួលស្គាល់បច្ចេកវិទ្យាជីវមាត្រត្រូវបានពិនិត្យទៅតាមករណីនីមួយៗ។ ហេតុនេះ ទាមទារឱ្យមានការពិនិត្យលើក្របខណ្ឌបទប្បញ្ញត្តិឡើងវិញ ដើម្បីអនុញ្ញាតឱ្យមានការប្រើប្រាស់ទិន្នន័យជីវមាត្រក្នុងការកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់នៅពេលបើកគណនីធនាគារ។

## ៤.បច្ចេកវិទ្យាក្លោដ

### ក. ស្ថានភាពបច្ចុប្បន្ន

បច្ចេកវិទ្យាក្លោដ ជាពាក្យបច្ចេកទេសដែលមជ្ឈដ្ឋានទូទៅសំដៅលើបរិស្ថានមួយដែលប្រព័ន្ធព័ត៌មានវិទ្យាអាចដំណើរការកម្មវិធីប្រតិបត្តិការជាលក្ខណៈនិម្មិតដោយបុគ្គល ឬសហគ្រាស អាចទាញយកមកប្រើប្រាស់នូវកម្មវិធី និងទិន្នន័យរក្សាទុកនៅក្នុងថ្នាលកុំព្យូទ័ររួមមួយ។ បច្ចេកវិទ្យានេះអាចដំណើរការបានតាមប្រព័ន្ធអ៊ីនធឺណិត ឬតាមប្រព័ន្ធផ្ទៃក្នុងជាលក្ខណៈឯកជនរបស់សហគ្រាសនីមួយៗ។ បច្ចេកវិទ្យាក្លោដ ផ្តល់នូវប្រព័ន្ធអនឡាញដែលអាចដំណើរការបានទូលំទូលាយ ក្នុងការទ្រទ្រង់ដំណើរប្រតិបត្តិការដោយមិនធ្វើឱ្យរាំងស្ទះដល់ដំណើរការប្រព័ន្ធ។ បច្ចេកវិទ្យានេះក៏ផ្តល់នូវកម្មវិធីប្រតិបត្តិការក្នុងការបង្កើតផលិតភាពធុរកិច្ចសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដោយមិនចាំបាច់ធ្វើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធព័ត៌មានវិទ្យា។ ជាមួយគ្នានេះដែរ បច្ចេកវិទ្យាក្លោដ

បានផ្តល់នូវអត្ថប្រយោជន៍ជាច្រើន រួមមាន កាត់បន្ថយការចំណាយលើការវិនិយោគ ចំណាយទាបសម្រាប់ប្រតិបត្តិការព័ត៌មានវិទ្យា លើកកម្ពស់ប្រតិបត្តិការ និងបង្កើនប្រសិទ្ធភាព ប៉ុន្តែក៏មានហានិភ័យមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងទិន្នន័យ សុវត្ថិភាពនិងឯកជនភាពទិន្នន័យ ការធានានិរន្តរភាពធុរកិច្ច និងការសង្គ្រោះទិន្នន័យ។

នៅប្រទេសកម្ពុជា ការប្រើប្រាស់បច្ចេកវិទ្យាក្លោដនៅមានកម្រិតតិចតួចនៅឡើយ។ ទោះបីជាគ្រឹះស្ថានជាច្រើនបាននិងកំពុងប្រើប្រាស់បច្ចេកវិទ្យាក្លោដ ការប្រើប្រាស់នៅមានកម្រិត និងមិនទាន់អស់សក្តានុពល។ នៅក្នុងវិស័យហិរញ្ញវត្ថុ ការប្រើប្រាស់បច្ចេកវិទ្យាក្លោដពីសំណាក់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានភាពយឺតយ៉ាវ ដែលអាចជួយកាត់បន្ថយចំណាយ និងបង្កើនប្រសិទ្ធភាពប្រតិបត្តិការតិចតួចប៉ុណ្ណោះ។ ខុសប្លែកពីគ្រឹះស្ថានហិរញ្ញវត្ថុបែបប្រពៃណី បច្ចេកវិទ្យាហិរញ្ញវត្ថុនឹងមិនអាចទ្រទ្រង់ធុរកិច្ចបានទេ ប្រសិនបើមិនប្រើប្រាស់បច្ចេកវិទ្យាក្លោដ ដែលកត្តានេះជាចលករមួយជំរុញឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលប្រតិបត្តិការ។ ក្របខណ្ឌបទប្បញ្ញត្តិនៅក្នុងវិស័យធនាគារបានតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្នើសុំការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងការជ្រើសរើសតតិយភាគីឱ្យធ្វើប្រតិបត្តិការជំនួសលើការប្រើប្រាស់បច្ចេកវិទ្យាក្លោដ ដោយត្រូវគោរពតាមលក្ខខណ្ឌតម្រូវដោយអាជ្ញាធរមានសមត្ថកិច្ច។ ទោះជាយ៉ាងណា ប្រតិបត្តិករផ្តល់សេវាកម្មក្លោដមួយចំនួនធំមិនបានអនុលោមតាមឧត្តមានុវត្តភាព និងវិធានអន្តរជាតិនោះទេ ហេតុដូចនេះ អាជ្ញាធរពាក់ព័ន្ធបានយកចិត្តទុកដាក់ក្នុងការរៀបចំគោលនយោបាយស្តីពីការប្រើប្រាស់បច្ចេកវិទ្យាក្លោដ និងមជ្ឈមណ្ឌលរក្សាទិន្នន័យឱ្យស្របតាមស្តង់ដារអន្តរជាតិ។

### ខ. បញ្ហាប្រឈម

បច្ចុប្បន្ននេះ ក្របខណ្ឌបទប្បញ្ញត្តិសម្រាប់ការពារសុវត្ថិភាពទិន្នន័យ នៅមិនទាន់មាននៅឡើយ។ ការដាក់ចេញនូវបទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងលំហូរទិន្នន័យឆ្លងដែន នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញ និងគ្រប់គ្រងការប្រើប្រាស់បច្ចេកវិទ្យាក្លោដ។ ការយល់ដឹងផ្នែកវិជ្ជាជីវៈបច្ចេកទេសនិងការគ្រប់គ្រងពាណិជ្ជកម្មអំពីអត្ថប្រយោជន៍នៃបច្ចេកវិទ្យាក្លោដ ចាំបាច់ត្រូវតែពង្រឹងបន្ថែមទៀតដើម្បីជំរុញឱ្យការប្រើប្រាស់បច្ចេកវិទ្យាមានភាពឆាប់រហ័ស។ គោលដៅឆ្ពោះទៅរកសេដ្ឋកិច្ចឌីជីថលរបស់ប្រទេសកម្ពុជា ជាចលករមួយក្នុងការជំរុញការប្រើប្រាស់បច្ចេកវិទ្យាក្លោដមួយកម្រិតទៀត។ ប្រតិបត្តិករធុរកិច្ចថ្មី ទោះបីជាមានចំនួនតិច ក៏បាននាំមុខគេក្នុងការជំរុញការប្រើប្រាស់បច្ចេកវិទ្យាក្លោដដោយមិនជ្រើសរើសវិធានប្រពៃណី។ ទោះជាយ៉ាងនេះក្តី នៅក្នុងវិស័យហិរញ្ញវត្ថុ ការដាក់ចេញតម្រូវការ និងក្របខណ្ឌបទប្បញ្ញត្តិក្នុងការប្រើប្រាស់សេវាកម្មតតិយភាគីពាក់ព័ន្ធបច្ចេកវិទ្យាក្លោដប្រកបដោយតម្លាភាពថែមទៀត មានភាពចាំបាច់ក្នុងការជំរុញការប្រើប្រាស់បច្ចេកវិទ្យា។

## ៥. បច្ចេកវិទ្យាឌីអិលធី

### ក. ស្ថានភាពបច្ចុប្បន្ន

បច្ចេកវិទ្យាឌីអិលធីដែលជាទូទៅសំដៅលើបច្ចេកវិទ្យាប្លុកឆេន ជាប្រព័ន្ធដំណើរការរបស់មជ្ឈមណ្ឌលទិន្នន័យឌីជីថលបែបវិមជ្ឈការដែលមានសុវត្ថិភាពខ្ពស់ និងបង្ការការអន្តរាគមន៍ពីអាជ្ញាធរ

កណ្តាលក្នុងការកែសម្រួលទិន្នន័យប្រតិបត្តិការ។ បច្ចេកវិទ្យាឌីអិលធីនេះ ផ្តល់នូវសុវត្ថិភាពខ្ពស់ និងភាពត្រឹមត្រូវបំផុតចំពោះការរក្សាទិន្នន័យដោយប្រើប្រាស់គ្រីបតូក្រាហ្វី ដែលទិន្នន័យទាំងអស់មិនអាចធ្វើការកែប្រែបានដោយភាគីណាមួយនោះទេនៅពេលទិន្នន័យត្រូវបានកត់ត្រា និងរក្សាទុក ហើយដំណើរការរបស់បច្ចេកវិទ្យានេះត្រូវបានគ្រប់គ្រងដោយវិធានរបស់បណ្តាញទាំងមូល។ បច្ចេកវិទ្យាឌីអិលធី ដែលកំពុងទទួលបានការពេញនិយមប្រើប្រាស់បច្ចុប្បន្នមានដូចជា Ehereum Hyperledger Fabric R3Corda និង Quorum។

ទោះបីជាបច្ចេកវិទ្យាឌីអិលធីទើបនឹងមានវត្តមានក៏ដោយ ប៉ុន្តែដំណើរការរបស់បច្ចេកវិទ្យានេះអាចនឹងមានភាពប្រទាក់ក្រឡាគ្នាច្រើនជាងបច្ចេកវិទ្យាដទៃទៀត និងមានសក្តានុពលក្នុងការយកទៅប្រើប្រាស់នៅក្នុងមុខងារផ្សេងៗជាច្រើន។ ជាក់ស្តែង បច្ចេកវិទ្យាឌីអិលធីកំពុងត្រូវបានពិចារណាយកទៅប្រើប្រាស់ក្នុងប្រតិបត្តិការជាច្រើន សម្រាប់សម្រួលការផ្ទេរទ្រព្យសកម្មដោយមិនឆ្លងកាត់អន្តរការីដូចជា សមភាគីកណ្តាល មណ្ឌលរក្សាទុកមូលបត្រ និងបង្កើនប្រសិទ្ធភាពអន្តរការីយកម្មដោយកាត់បន្ថយរយៈពេលទូទាត់ ឬពង្រឹងតម្លាភាពលើការចុះកិច្ចបញ្ជិកា និងរបាយការណ៍។ លើសពីនេះការប្រើប្រាស់បច្ចេកវិទ្យាឌីអិលធីមួយចំនួន ក៏បានបម្រើដល់ការងារប្រតិបត្តិការជួរខាងក្រោយរបស់គ្រឹះស្ថានធនាគារផងដែរ ដែលជួយសម្រួលដល់ការចែករំលែកព័ត៌មានកាន់តែល្អប្រសើរដល់ដំណើរការប្រតិបត្តិការរបស់ធនាគារ។ ក្រៅពីនេះ ការប្រើប្រាស់បច្ចេកវិទ្យាឌីអិលធីផ្តល់នូវអត្ថប្រយោជន៍ផ្សេងបន្ថែមទៀត រួមមាន ការលុបបំបាត់នូវការបញ្ចូលទិន្នន័យស្ទួនគ្នា និងការកាត់បន្ថយការចំណាយសោហ៊ុយលើការថែរក្សាប្រព័ន្ធជាដើម។ ទោះបីជាបច្ចេកវិទ្យាឌីអិលធីមានលក្ខណៈខុសប្លែកគ្នាច្រើន និងការប្រើប្រាស់មិនទាន់មានភាពពេញលេញ ការអភិវឌ្ឍបច្ចេកវិទ្យានេះអាចបង្កឱ្យមានហានិភ័យដោយសារសមត្ថភាពរបស់បច្ចេកវិទ្យាមួយចំនួននៅមានកម្រិត និងមិនទាន់អាចការពារឯកជនភាពទិន្នន័យរបស់អ្នកប្រើប្រាស់ ឬគោរពតាមស្តង់ដារអន្តរជាតិ ក៏ដូចជាមិនទាន់អាចដំណើរការជាលក្ខណៈអន្តរប្រតិបត្តិការនៅឡើយផងដែរ។ គ្រឹះស្ថានហិរញ្ញវត្ថុមួយចំនួនបានធ្វើការវិនិយោគទៅលើបច្ចេក-វិទ្យានេះ ដោយសម្រេចបាននូវការប្រើប្រាស់ផ្ទៃក្នុងជាមួយគ្រឹះស្ថានដទៃទៀតដែលស្ថិតនៅក្នុងសម្ព័ន្ធក្រុមហ៊ុនតែមួយ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវា។ ថ្នាលបច្ចេកវិទ្យាឌីអិលធី ដែលកំពុងស្ថិតនៅក្នុងដំណាក់កាលសាកល្បងឬអភិវឌ្ឍរួចរាល់ ត្រូវបានយកទៅប្រើប្រាស់ក្នុងការផ្តល់សេវាដូចជា ហិរញ្ញប្បទានពាណិជ្ជកម្ម សហជីពឥណទាន ផាត់ទាត់ប្រតិបត្តិការរីប៉ូ និងការកត់ត្រាប្រតិបត្តិការ និងដំណើរការឧបករណ៍និស្សន្ទ។

នៅក្នុងវិស័យធនាគារ សង្កេតឃើញមានការប្រើប្រាស់បច្ចេកវិទ្យាឌីអិលធីក្នុងប្រតិបត្តិការមួយចំនួន ដូចជា ការចេញផ្សាយរូបិយប័ណ្ណឌីជីថល ការផ្ទេរប្រាក់អន្តរជាតិនិងការទូទាត់ឆ្លងដែនការផាត់ទាត់និងទូទាត់ប្រតិបត្តិការធនាគារ និងការជួញដូររូបិយប័ណ្ណ។ នៅលើសកលលោក ធនាគារកណ្តាលជាច្រើនកំពុងធ្វើការសិក្សាយ៉ាងយកចិត្តទុកដាក់ ដើម្បីពិនិត្យលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាឌីអិលធីបានតាមរយៈការស្រាវជ្រាវ និងដាក់ដំណើរការសាកល្បង។ ក្នុងចំណោមប្រតិបត្តិការទាំងនោះសង្កេតឃើញថា ធនាគារកណ្តាលជាច្រើនបាននិងកំពុងធ្វើការសិក្សាទៅលើលទ្ធភាពការចេញផ្សាយនិងដំណើរការរូបិយប័ណ្ណឌីជីថលធនាគារកណ្តាល ដែលបានបែងចែងជា ២ ប្រភេទ រួមមាន រូបិយប័ណ្ណឌីជីថលដុំ និងរូបិយប័ណ្ណឌីជីថលរាយ។ លើសពីនេះ ករណីប្រើប្រាស់បច្ចេកវិទ្យាឌីអិលធីជាច្រើនផ្សេង

ទៀត ក៏ត្រូវបានពិនិត្យឃើញនៅក្នុងប្រតិបត្តិការផ្ទេរប្រាក់អន្តរជាតិ និងការទូទាត់ឆ្លងដែនមានជាអាទិ៍ ពហុរូបិយប័ណ្ណឌីជីថលធនាគារកណ្តាល ដែលផ្តួចផ្តើមឡើងរួមគ្នាដោយអាជ្ញាធររូបិយវត្ថុក្រុងហុងកុង និងធនាគារកណ្តាលថៃ ដើម្បីធ្វើការទូទាត់ឆ្លងដែនរវាងទីក្រុងហុងកុង និងប្រទេសថៃ និងករណីប្រើប្រាស់ផ្សេងទៀតមាននៅក្នុងប្រតិបត្តិការផ្ទេរប្រាក់អន្តរជាតិដូចជា Ripple និង Ethereum ជាដើម។

នៅប្រទេសកម្ពុជា បច្ចេកវិទ្យាជាច្រើនត្រូវបានធនាគារជាតិនៃកម្ពុជាលើកយកមកសិក្សា ដែលក្នុងនោះក៏មានបច្ចេកវិទ្យាឌីអិលធីនេះផងដែរ ហើយនៅឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានសម្រេចចាប់ផ្តើមអភិវឌ្ឍគម្រោង "បាគង" ដោយបានជ្រើសរើសយកបច្ចេកវិទ្យា "Hyperledger Iroha" ធ្វើជាថ្នាលសម្រាប់ដំណើរការបច្ចេកវិទ្យាឌីអិលធី។ គម្រោង "បាគង" ត្រូវបានអភិវឌ្ឍឡើង ក្នុងគោលដៅផ្តល់លទ្ធភាពទូទាត់ឆ្លងគ្រឹះស្ថានប្រកបដោយប្រសិទ្ធភាព កាត់បន្ថយចំណាយប្រតិបត្តិការ មានភាពឆាប់រហ័ស និងពង្រឹងសុវត្ថិភាពប្រព័ន្ធទូទាត់សងប្រាក់បច្ចុប្បន្ន។ លើសពីនេះ ការអភិវឌ្ឍគម្រោង "បាគង" នេះក៏មានគោលបំណងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងសម្រួលដល់ការប្រើប្រាស់រូបិយវត្ថុជាតិផងដែរ។ បន្ទាប់ពីបានដាក់ឱ្យដំណើរការសាកល្បងក្នុងឆ្នាំ២០១៩ ប្រព័ន្ធទូទាត់ "បាគង" ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនាថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ដោយមានការចូលរួមជាសមាជិកពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ជាច្រើន។

## ខ. បញ្ហាប្រឈម

ដោយបច្ចេកវិទ្យាឌីអិលធីអាចយកទៅប្រើប្រាស់នៅក្នុងមុខងារជាច្រើន ហើយការប្រើប្រាស់នៅក្នុងវិស័យហិរញ្ញវត្ថុមានលក្ខណៈឆាប់រហ័សពេក និយ័តករជាច្រើនកំពុងធ្វើការសិក្សាលើបច្ចេកវិទ្យានេះតាមរយៈការចងក្រងជាឯកសារពិភាក្សា ដោយធ្វើការវិភាគទៅលើចរិតលក្ខណៈ កាលានុវត្តភាព ហានិភ័យ ករណីប្រើប្រាស់ផ្សេងៗ និងផលប៉ះពាល់មកលើទីផ្សារហិរញ្ញវត្ថុ ដើម្បីធ្វើការឆ្លើយតបឱ្យបានសមស្របក្នុងការគ្រប់គ្រងបច្ចេកវិទ្យានេះ។ អាជ្ញាធរមានសមត្ថកិច្ចមួយចំនួនបានដាក់ចេញនូវបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងបច្ចេកវិទ្យាឌីអិលធី ដោយមិនអនុញ្ញាត ឬហាមឃាត់ការប្រើប្រាស់បច្ចេកវិទ្យានេះបម្រើដល់ដំណើរការទ្រព្យសកម្មគ្រីបតូនៅក្នុងដែនយុត្តាធិការរបស់ខ្លួន។ សម្រាប់ប្រទេសកម្ពុជា មិនទាន់មានបទប្បញ្ញត្តិជាក់លាក់ណាមួយដែលបានដាក់ចេញ ដើម្បីគ្រប់គ្រងលើបច្ចេកវិទ្យាឌីអិលធីនៅឡើយ ហើយក្របខណ្ឌបទប្បញ្ញត្តិបច្ចុប្បន្នផ្តោតសំខាន់តែទៅលើប្រតិបត្តិការប្រើប្រាស់តែប៉ុណ្ណោះ។ ទោះជាយ៉ាងណា និយ័តករមូលបត្រកម្ពុជាកំពុងពិចារណាអំពីលទ្ធភាពក្នុងការគ្រប់គ្រងលើទីផ្សារជួញដូរទ្រព្យសកម្មគ្រីបតូ ដោយសារវិធានគ្រប់គ្រងលើបច្ចេកវិទ្យាឌីអិលធីសម្រាប់ការជួញដូរទ្រព្យសកម្មគ្រីបតូ នៅមិនទាន់មានភាពច្បាស់លាស់។ ប្រតិបត្តិការប្រើប្រាស់បច្ចេកវិទ្យាឌីអិលធីសម្រាប់សេវាទូទាត់ឌីជីថល និងការទូទាត់អន្តរជាតិស្ថិតនៅក្រោមបទប្បញ្ញត្តិស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។ ប្រតិបត្តិការប្រើប្រាស់ដែលមានសក្តានុពលត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃក្របខណ្ឌបទប្បញ្ញត្តិនីមួយៗផ្អែកលើប្រភេទសេវាកម្មនៃប្រតិបត្តិការប្រើប្រាស់នោះ។ ហេតុនេះ ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីអិលធីមានភាពចាំបាច់ ដោយសារបច្ចេកវិទ្យានេះមានអត្ថប្រយោជន៍ច្រើនដល់នវានុវត្តន៍ហិរញ្ញវត្ថុ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍគម្រោង "បាគង" ដោយប្រើប្រាស់បច្ចេកវិទ្យាឌីអិលធី ដើម្បីដាក់ឱ្យដំណើរការហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់

សងប្រាក់ជាលក្ខណៈអន្តរប្រតិបត្តិការ ដែលជាកត្តាជំរុញឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាឌីអិលធី នៅក្នុងវិស័យធនាគារ។ បច្ចុប្បន្ននេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចាប់ផ្តើមមានជំនឿចិត្តមកលើការប្រើប្រាស់បច្ចេកវិទ្យានេះ ដោយគ្រឹះស្ថានមួយចំនួនបានចាប់ផ្តើមដាក់ដំណើរការប្រតិបត្តិការផ្ទេរប្រាក់អន្តរជាតិ តាមរយៈការចូលជាសមាជិកនៃបណ្តាញ Ripple។ ទោះជាយ៉ាងណា ការបើកឱ្យមានកិច្ចពិភាក្សារវាងភាគីពាក់ព័ន្ធអំពីហានិភ័យ និងអត្ថប្រយោជន៍សំខាន់ៗរបស់បច្ចេកវិទ្យានេះនៅក្នុងសហគមហិរញ្ញវត្ថុ នឹងជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីអិលធីកាន់តែទូលំទូលាយបន្ថែមទៀត។

## III. គោលនយោបាយជំរុញ

### ១. អត្តសញ្ញាណឌីជីថល

#### ក. ស្ថានភាពបច្ចុប្បន្ន

បច្ចុប្បន្ននេះ ដោយសារភាពរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ពិភពលោកកំពុងតែវិវត្តឆ្ពោះទៅរកសេដ្ឋកិច្ចនិងសង្គមឌីជីថល។ ដើម្បីគាំទ្រដល់ដំណើរបរិវត្តកម្មនេះ អត្តសញ្ញាណឌីជីថលមានតួនាទីយ៉ាងសំខាន់សម្រាប់ធ្វើសមាហរណកម្មសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយសារអត្តសញ្ញាណឌីជីថលអាចជំរុញសកម្មភាពការងារយ៉ាងរលូនទាំងក្នុងវិស័យសាធារណៈ និងឯកជន។ បច្ចេកវិទ្យាថ្មីៗបានបង្កើតបរិយាកាសអំណោយផលក្នុងការអភិវឌ្ឍប្រព័ន្ធព័ត៌មានសម្រាប់ចុះបញ្ជី និងកំណត់អត្តសញ្ញាណប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងមានប្រសិទ្ធផល។ ផ្អែកលើវឌ្ឍនភាពក្នុងការអភិវឌ្ឍប្រព័ន្ធចុះបញ្ជី និងអត្តសញ្ញាណប័ណ្ណនៅក្នុងប្រទេសកម្ពុជា និងសិក្សាពីបញ្ហាប្រឈមនានា ស្ថាប័នពាក់ព័ន្ធបានកំណត់គោលដៅច្បាស់លាស់ និងដាក់ចេញសកម្មភាពការងារដើម្បីសម្រេចបានគោលដៅទាំងនេះ។ ប្រជាជនកម្ពុជាប្រមាណ ១១ លាននាក់បានចុះបញ្ជី និងទទួលបានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររួចហើយ ដែលជាមូលដ្ឋានឆ្ពោះទៅរកការអភិវឌ្ឍអត្តសញ្ញាណឌីជីថល។ ក្រសួងមហាផ្ទៃដែលបានដឹកនាំគម្រោងយុទ្ធសាស្ត្រជាតិសម្រាប់ការធ្វើអត្តសញ្ញាណកម្មបាននិងកំពុងពិចារណាលើការបង្កើតគណៈកម្មាធិការដឹកនាំថ្នាក់ជាតិស្តីពី ការបង្កើតអត្តសញ្ញាណឌីជីថលជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ដែលអាចពន្លឿនលទ្ធភាពចូលទៅប្រើប្រាស់ប្រព័ន្ធអត្តសញ្ញាណប័ណ្ណជាតិ ក៏ដូចជាទិន្នន័យនៃការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ការអភិវឌ្ឍទាំងនេះបានបង្កឱ្យមានបរិដ្ឋានអំណោយផលសម្រាប់ប្រទេសកម្ពុជាក្នុងការប្រើប្រាស់អត្តសញ្ញាណឌីជីថលក្នុងវិស័យផ្សេងៗ ដើម្បីគាំទ្រដល់សេវារដ្ឋាភិបាលឌីជីថល ពាណិជ្ជកម្មអេឡិចត្រូនិក ក៏ដូចជាលើក-កម្ពស់ប្រតិបត្តិការសង្គមនិងហិរញ្ញវត្ថុឱ្យប្រសើរឡើង។ បច្ចុប្បន្ន ប្រតិបត្តិការនៃថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជាស្ថិតនៅក្នុងដំណាក់កាលដំបូង និងមានវិសាលភាពសម្រាប់ការចុះបញ្ជីធុរកិច្ចតាមអ៊ីនធឺណិតប៉ុណ្ណោះ និងពុំទាន់អាចជួយសម្រួលការកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់ក្នុងវិស័យធនាគារបានទេ ដែលនេះជាបញ្ហាប្រឈមចម្បងមួយ ដោយសារការផ្ទៀងផ្ទាត់ផ្អែកលើឯកសាររូបវន្តមួយចំនួនដូចជាអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន សៀវភៅគ្រួសារ និងឯកសារពាក់ព័ន្ធផ្សេងទៀតដែលចេញដោយអាជ្ញាធរ។ តាមរយៈការអភិវឌ្ឍនៃសេវាធនាគារឌីជីថល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួនបាន

ចាប់ផ្តើមអនុវត្តការចុះឈ្មោះ និងកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់ដោយប្រើប្រាស់ថ្នាលឌីជីថល ដូចជា សេវាធនាគារចល័តជាដើម ប៉ុន្តែការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៅក្នុងប្រតិបត្តិការធនាគារធ្វើឡើងតាមរយៈកម្មវិធីឌីជីថលរបស់ធនាគារផ្ទាល់ដូចជា លេខកូដសម្ងាត់ ឬលេខកូដបញ្ជាក់ ដែលផ្តល់ការលំបាកដល់អ្នកប្រើប្រាស់ ជាពិសេសអ្នកដែលមានការយល់ដឹងតិចតួចអំពីបច្ចេកវិទ្យាថ្មីៗ។

### ខ. បញ្ហាប្រឈម

ជាការពិតណាស់ កង្វះខាតអត្តសញ្ញាណឌីជីថល និងការផ្ទៀងផ្ទាត់ទិន្នន័យសម្រាប់អ្នកប្រើប្រាស់សក្តានុពល ជាបញ្ហាប្រឈមចម្បងមួយក្នុងការទទួលបានសេវាហិរញ្ញវត្ថុនៅកម្ពុជា។ ចំពោះការអនុវត្តការកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់នៅក្នុងវិស័យធនាគារនាពេលបច្ចុប្បន្ននៅមានភាពរអាក់រអួល និងពុំទាន់មានប្រសិទ្ធភាពសម្រាប់ធនាគារ និងអ្នកប្រើប្រាស់នៅឡើយ ដោយសារអ្នកប្រើប្រាស់តម្រូវឱ្យទៅបង្ហាញខ្លួនដោយផ្ទាល់ និងភ្ជាប់ឯកសារជាភស្តុតាង ចំណែកគ្រឹះស្ថានធនាគារត្រូវធ្វើការផ្ទៀងផ្ទាត់ឯកសារច្រើនប្រភេទ។ ទោះបីជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួនបានដាក់ឱ្យដំណើរការការកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់តាមអនឡាញសម្រាប់ការបើកគណនី ការអនុវត្តបែបនេះពុំអាចចាត់ទុកថាអនុលោមតាមច្បាប់ និងកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់បានពេញលេញទេ ហេតុនេះអ្នកប្រើប្រាស់អាចទទួលបានសេវាធនាគារនៅត្រឹមកម្រិតណាមួយប៉ុណ្ណោះ។ លើសពីនេះទៀត មិនមានប្រភពផ្លូវការទទួលស្គាល់ដោយអាជ្ញាធរពាក់ព័ន្ធ ដែលបើកលទ្ធភាពឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្ទៀងផ្ទាត់ទិន្នន័យលក្ខណៈឌីជីថលផ្តល់ដោយបុគ្គល និងធុរកិច្ចនៅឡើយទេ។ ទោះបីជាទិន្នន័យអត្តសញ្ញាណ និងថ្នាលចែករំលែកទិន្នន័យត្រូវបានដាក់ឱ្យដំណើរការ និងអាចធ្វើការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃទិន្នន័យលក្ខណៈឌីជីថលក៏ដោយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុពុំទាន់មានលទ្ធភាពប្រើប្រាស់ថ្នាលចែករំលែកទិន្នន័យនេះនៅឡើយ ដែលជាបញ្ហាប្រឈមក្នុងការដាក់ចេញយន្តការកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់តាមប្រព័ន្ធអេឡិចត្រូនិក។ ម៉្យាងទៀត ដើម្បីសម្រេចបានការកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់ជាអេឡិចត្រូនិក និងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដោយប្រើប្រាស់អត្តសញ្ញាណឌីជីថលតម្រូវឱ្យមានក្របខណ្ឌបទប្បញ្ញត្តិពេញលេញ អភិបាលកិច្ចល្អ ហេដ្ឋារចនាសម្ព័ន្ធរឹងមាំ និងការអនុវត្តសមស្រប។

អត្តសញ្ញាណឌីជីថលនឹងជួយលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុដែលអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលអ្នកប្រើប្រាស់ថ្មីចូលមកប្រព័ន្ធហិរញ្ញវត្ថុផ្លូវការតាមរយៈថ្នាលឌីជីថល។ ដើម្បីដោះស្រាយបញ្ហានេះ ចាំបាច់ត្រូវធ្វើការសិក្សាពីលទ្ធភាពក្នុងការដាក់ឱ្យប្រើប្រាស់អត្តសញ្ញាណឌីជីថល ហើយលទ្ធផលនៃការសិក្សានេះនឹងផ្តល់នូវមូលដ្ឋានសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថល ក៏ដូចជាកែសម្រួលយន្តការកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់ និងការផ្ទៀងផ្ទាត់អត្តសញ្ញាណឌីជីថលក្នុងវិស័យធនាគារនាពេលបច្ចុប្បន្ន។ សម្រាប់ជំហានបន្ទាប់ ការបង្កើនប្រសិទ្ធភាពនៃការកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់មានសារៈសំខាន់ណាស់ តាមរយៈការអភិវឌ្ឍថ្នាលរួមមួយតភ្ជាប់ជាមួយថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ដើម្បីសម្របសម្រួលដល់ការចែករំលែកទិន្នន័យសម្រាប់ការកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់លក្ខណៈបុគ្គលនិងធុរកិច្ច អនុលោមតាមបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ លើសពីនេះទៀត ដើម្បីពង្រឹងជំនឿទុកចិត្ត និង

លើកកម្ពស់ការប្រើប្រាស់ថ្នាលរួមនេះ ទាមទារឱ្យមានការដាក់ចេញក្របខណ្ឌបទប្បញ្ញត្តិ និងអភិបាល-កិច្ចច្បាស់លាស់ ដើម្បីគ្រប់គ្រងសកម្មភាពផ្តល់ការកំណត់អត្តសញ្ញាណជាលក្ខណៈអេឡិចត្រូនិក ការចែករំលែកនិងការការពារទិន្នន័យ និងប្រតិបត្តិការនៅក្នុងថ្នាលរួមនេះ។ ក្រៅពីនេះ ដោយសារបច្ចេកវិទ្យាមានការរីកចម្រើនឆាប់រហ័ស ការអភិវឌ្ឍថ្នាលរួមនេះចាំបាច់ត្រូវមានការថែទាំ និងកែលំអជាប្រចាំ ដើម្បីធានាបាននូវសុវត្ថិភាពនិងភាពធន់។ សម្រាប់ជំហានចុងក្រោយ ការពង្រីកវិសាលភាព និងការធ្វើអន្តរប្រតិបត្តិការជាមួយប្រព័ន្ធផ្សេងទៀត ត្រូវពិនិត្យមើលផងដែរ ដើម្បីពន្លឿនការប្រើប្រាស់អត្តសញ្ញាណឌីជីថលនៅក្នុងផ្នែកផ្សេងៗនៃវិស័យធនាគារ។

## ២. ក្របខណ្ឌធនាគារបើកចំហ

### ក. ស្ថានភាពបច្ចុប្បន្ន

តាមរយៈការអភិវឌ្ឍសេវាធនាគារអនឡាញ និងសេវាធនាគារចល័ត អ្នកប្រើប្រាស់ជាច្រើនផ្តល់សិទ្ធិឱ្យតតិយភាគីមានលទ្ធភាពក្នុងការចូលប្រើប្រាស់ទិន្នន័យធនាគារផ្ទាល់ខ្លួន ដើម្បីទទួលបានសេវាផ្សេងៗទៀត។ ការចែករំលែកទិន្នន័យបាននាំឱ្យមាននវានុវត្តន៍ទៅលើសេវា និងផលិតផលហិរញ្ញវត្ថុ ដូចជា ការផ្តល់ឧបករណ៍គ្រប់គ្រងហិរញ្ញវត្ថុដែលបង្ហាញគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុនៅលើថ្នាលរួមមួយ ការធ្វើប្រតិបត្តិការទូទាត់រវាងគណនីផ្សេងគ្នានៅគ្រឹះស្ថានផ្សេងគ្នាប្រកបដោយភាពរលូន ការធ្វើប្រតិបត្តិការតូចៗមានលក្ខណៈជាការទូទាត់ប្រចាំថ្ងៃ ការបង់សេវាធនាគារ និងការប្រៀបធៀបលើកម្ចីអចលនទ្រព្យជាដើម។ ការផ្តល់សេវាហិរញ្ញវត្ថុដល់អ្នកប្រើប្រាស់ដែលកន្លងមកផ្តល់ដោយគ្រឹះស្ថានធនាគារ ត្រូវបានផ្តល់ជំនួសដោយតតិយភាគីដូចជា បច្ចេកវិទ្យាហិរញ្ញវត្ថុជាដើម។ ទន្ទឹមនឹងនេះដែរ តតិយភាគីអាចបង្កើតសេវាថ្មីដែលផ្តល់តម្លៃបន្ថែមដល់គ្រឹះស្ថានធនាគារ ក្នុងការពង្រីកបណ្តាញសេវាកម្ម។ ការអនុវត្តបែបនេះជាទិដ្ឋភាពនៃក្របខណ្ឌធនាគារបើកចំហ។

គ្រឹះស្ថានធនាគារ និងតតិយភាគីពិនិត្យឃើញថា ការផ្តល់សិទ្ធិអនុញ្ញាតតាមរយៈសន្ទានកម្មនៃកម្មវិធីកុំព្យូទ័របានផ្តល់នូវការគ្រប់គ្រងបន្ថែមលើប្រភេទទិន្នន័យ និងទំហំទិន្នន័យដែលបានចែករំលែក និងការរក្សាទុកប្រកបដោយសុវត្ថិភាពក្នុងការធ្វើទំនាក់ទំនងជាមួយតតិយភាគី។ សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រអនុញ្ញាតឱ្យកម្មវិធីសូហ្វវែរធ្វើការប្រាស្រ័យទាក់ទង និងចែករំលែកព័ត៌មានដោយពុំមានការអន្តរាគមន៍ពីមនុស្ស។ សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រមិនមែនជាបច្ចេកវិទ្យាដែលទើបតែបង្កើតថ្មីទេ ការប្រើប្រាស់កម្មវិធីសូហ្វវែរសម្រាប់ធ្វើការប្រាស្រ័យទាក់ទងលើប្រព័ន្ធអ៊ីនធឺណិតត្រូវបានប្រើប្រាស់ជាយូរអង្វែងមកហើយ។ ទោះយ៉ាងណាក្តី ការអភិវឌ្ឍនិងការថែរក្សាសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រជាសាធារណៈ ត្រូវចំណាយពេលវេលា និងថវិកាច្រើន ជាពិសេសចំពោះការអនុវត្តលើមូលដ្ឋានទ្វេភាគីរវាងធនាគារនីមួយៗនិងតតិយភាគី ដែលនេះអាចជាបញ្ហាប្រឈមសម្រាប់គ្រឹះស្ថានធនាគារខ្នាតតូចដែលទំហំប្រតិបត្តិការនៅមានកម្រិតធៀបនឹងគ្រឹះស្ថានធំៗ។ កង្វះខាតស្តង់ដារសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រជាបញ្ហាប្រឈមបន្ថែមទៀត។ ការប្រើប្រាស់បច្ចេកវិទ្យាសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រជាសាធារណៈសម្រាប់ការចែករំលែកទិន្នន័យ បានផ្តល់កាលានុវត្តភាពសម្រាប់គ្រឹះស្ថានធនាគារ និងតតិយភាគីទទួលបានបទពិសោធន៍ ក៏ដូចជាជំរុញនវានុវត្តន៍លើសេវាហិរញ្ញវត្ថុ។ ការចែករំលែកទិន្នន័យអាចនាំឱ្យមានការផ្លាស់ប្តូរគំរូធុរកិច្ចធនាគារតាមបែបប្រពៃណី ប៉ុន្តែការបើកទូលាយហួសហេតុក៏អាច

នាំឱ្យវិស័យធនាគារប្រឈមនឹងហានិភ័យមួយចំនួនពាក់ព័ន្ធហានិភ័យប្រតិបត្តិការ និងហានិភ័យកេរ្តិ៍ឈ្មោះផងដែរ។

អាជ្ញាធរជាច្រើនបានដាក់ឱ្យអនុវត្ត ឬកំពុងរៀបចំដាក់ឱ្យអនុវត្តក្របខណ្ឌប្រតិបត្តិការធនាគារបើកចំហ ដែលតម្រូវឱ្យគ្រឹះស្ថានធនាគារចែករំលែកទិន្នន័យជាមួយតតិយភាគី។ អាជ្ញាធរមួយចំនួនបានដាក់ចេញវិធានការកំណត់ដែលតម្រូវឱ្យគ្រឹះស្ថានធនាគារចែករំលែកទិន្នន័យ និងតម្រូវឱ្យតតិយ-ភាគីដែលមានបំណងប្រើប្រាស់ទិន្នន័យចុះបញ្ជីជាមួយនិយ័តករ ឬអាជ្ញាធរត្រួតពិនិត្យ។ អាជ្ញាធរមួយចំនួនផ្សេងទៀតបានអនុវត្តវិធានការសម្របសម្រួល ដោយបានដាក់ចេញនូវគោលការណ៍ និងអនុសាសន៍ណែនាំ និងដាក់ឱ្យប្រើប្រាស់នូវស្តង់ដារសន្ធានកម្មនៃកម្មវិធីកុំព្យូទ័របើកចំហ ព្រមទាំងគំរូបរិច្ឆិនបច្ចេកទេស។ អាជ្ញាធរដោយឡែកទៀត ដាក់ឱ្យអនុវត្តវិធានការជំរុញផ្អែកលើទីផ្សារដោយមិនមានដាក់ចេញបទប្បញ្ញត្តិ ឬការណែនាំស្តីពីការអនុញ្ញាត ឬហាមឃាត់ការចែករំលែកទិន្នន័យរវាងគ្រឹះស្ថានធនាគារជាមួយតតិយភាគី។ ទោះយ៉ាងណាក្តី ការអភិវឌ្ឍក្របខណ្ឌធនាគារបើកចំហស្ថិតនៅក្នុងដំណាក់កាលបឋម ហើយវិសាលភាពនិងតម្រូវការនៅពុំទាន់មានសង្គតភាពនៅឡើយ។ គុណសម្បត្តិ និងគុណវិបត្តិនៃក្របខណ្ឌធនាគារបើកចំហ ស្ថិតនៅលើវិធានការនីមួយៗដែលបានដាក់ចេញ ហើយស្ថិតនៅក្នុងរង្វង់គោលដៅធានាសុវត្ថិភាពនិងភាពមុតមាំ ជំរុញនវានុវត្តន៍ និងការការពារអ្នកប្រើប្រាស់។

នៅប្រទេសកម្ពុជាការអភិវឌ្ឍក្របខណ្ឌធនាគារបើកចំហស្ថិតនៅក្នុងដំណាក់កាលបឋមនៅឡើយ បច្ចុប្បន្នមានគំនិតផ្តួចផ្តើមក្នុងការផ្លាស់ប្តូរទិន្នន័យនៅក្នុងស្ថាប័នរាជរដ្ឋាភិបាល តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ដែលជាថ្នាលមួយស្ថិតនៅក្រោមមជ្ឈមណ្ឌលបណ្តុះធុរកិច្ចតេជោ (TECHO Startup Center)។ ប៉ុន្តែវិសាលភាពក្នុងការផ្លាស់ប្តូរទិន្នន័យមិនគ្របដណ្តប់លើទិន្នន័យក្នុងវិស័យហិរញ្ញវត្ថុទេ ព្រោះការអនុវត្តផ្អែកលើគោលការណ៍ស្ម័គ្រចិត្តក្នុងការចែករំលែកទិន្នន័យ។ គ្រឹះស្ថានធនាគារមួយចំនួនតូចបានផ្តល់លទ្ធភាពក្នុងការចែករំលែកព័ត៌មានអ្នកប្រើប្រាស់ដល់តតិយ-ភាគី ដើម្បីជំរុញនវានុវត្តន៍លើផលិតផល និងសេវា។ បន្ថែមលើនេះ សហគមបច្ចេកវិទ្យាហិរញ្ញវត្ថុបានសហការគ្នាដាក់ចេញនូវថ្នាលចែករំលែកទិន្នន័យ ដើម្បីបើកឱកាសឱ្យធុរកិច្ចថ្មី និងធុរកិច្ចនានាចូលរួមនៅក្នុងគំនិតផ្តួចផ្តើមចែករំលែកទិន្នន័យ។

## ខ. បញ្ហាប្រឈម

បច្ចេកវិទ្យាហិរញ្ញវត្ថុ និងគ្រឹះស្ថានធនាគារ នឹងទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រក្នុងការបង្កើតនូវក្របខណ្ឌធនាគារបើកទំហ។ ប៉ុន្តែការប្រើប្រាស់សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រនឹងបង្កើតឱ្យមាននូវហានិភ័យថ្មីៗ ដូច្នេះការរៀបចំបទប្បញ្ញត្តិ និងការវាយតម្លៃហានិភ័យលើសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រត្រូវពិនិត្យលើកត្តាសំខាន់ៗដូចជា ការការពារទិន្នន័យ ការធ្វើផតថល ការផ្តល់សិទ្ធិប្រើប្រាស់ទិន្នន័យ ក៏ដូចជាស្តង់ដារសុវត្ថិភាពដែលទាក់ទងនឹងការបញ្ជាក់ភាពត្រឹមត្រូវ ការអនុញ្ញាតឱ្យចូលប្រើប្រាស់ និងការអ៊ិនគ្រីបទិន្នន័យ។ ការកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី និងការទទួលខុសត្រូវលើគ្រប់ភាគីពាក់ព័ន្ធនៅក្នុងបណ្តាញចែករំលែកទិន្នន័យមានភាពចាំបាច់ផងដែរ។ ដោយសារបទប្បញ្ញត្តិទាក់ទងនឹងការការពារទិន្នន័យនៅពុំទាន់មាននៅឡើយ ដូច្នេះ

ក្របខណ្ឌលើការចែករំលែកទិន្នន័យនៅក្នុងវិស័យធនាគារតាមរយៈការផ្ដល់សិទ្ធិប្រើប្រាស់ នឹងសម្រួលដល់ការអនុវត្តក្របខណ្ឌធនាគារបើកចំហនៅក្នុងវិស័យធនាគារ។ បន្ថែមលើនេះ ការបើកឱ្យមានកិច្ចពិភាក្សារវាងភាគីពាក់ព័ន្ធស្ដីពីក្របខណ្ឌធនាគារបើកចំហ នឹងអាចដោះស្រាយរាល់បញ្ហាប្រឈមសម្រាប់គ្រប់ភាគីទាំងអស់។

## ៣. ក្របខណ្ឌការពារទិន្នន័យ

### ក. ស្ថានភាពបច្ចុប្បន្ន

ក្របខណ្ឌការពារទិន្នន័យ ជាសំណុំយុទ្ធសាស្ត្រ និងដំណើរការដែលអាចប្រើប្រាស់ដើម្បីធានានូវឯកជនភាព លទ្ធភាពទទួលបាន និងសុចរិតភាពនៃទិន្នន័យផ្ទាល់ខ្លួន។ ទិន្នន័យផ្ទាល់ខ្លួនបានដើរតួនាទីសំខាន់ខ្លាំងឡើងនៅក្នុងសេដ្ឋកិច្ច និងសង្គមរបស់យើង។ ខណៈពេលដែលបច្ចេកវិទ្យាថ្មី និងការប្រើប្រាស់ទិន្នន័យប្រកបដោយទំនួលខុសត្រូវ បានផ្ដល់ផលប្រយោជន៍ដល់សង្គមនិងសេដ្ឋកិច្ចយ៉ាងច្រើន ភាពសម្បូរបែបនិងប្រទាក់ក្រឡានៃទិន្នន័យផ្ទាល់ខ្លួន នាំមកនូវហានិភ័យថ្មីៗដល់ឯកជនភាពរបស់បុគ្គលម្នាក់ៗ។ ទិន្នន័យផ្ទាល់ខ្លួនត្រូវបានប្រើប្រាស់ខ្លាំងឡើងមិនដូចការគ្រោងទុកនៅពេលដែលទិន្នន័យត្រូវបានបង្កើតដោយអ្នកប្រើប្រាស់មិនបានដឹងច្បាស់អំពីរបៀបដែលទិន្នន័យផ្ទាល់ខ្លួនត្រូវបានប្រមូល រក្សាទុក និងប្រើប្រាស់។ និន្នាការទាំងនេះជះឥទ្ធិពលលើវិស័យសេវាហិរញ្ញវត្ថុ និងអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ។ នវានុវត្តន៍បច្ចេកវិទ្យាបានបង្កើនសមត្ថភាពរបស់អ្នកផ្ដល់សេវាហិរញ្ញវត្ថុក្នុងការចាប់យក រក្សាទុក បញ្ចូលគ្នា និងវិភាគទិន្នន័យអ្នកប្រើប្រាស់ជាច្រើនគិតចាប់ពីទីតាំងប្រើប្រាស់បច្ចុប្បន្ន ឬទីតាំងពីមុនរហូតដល់ឥរិយាបថ និងចំណូលចិត្តរបស់អ្នកប្រើប្រាស់។ កត្តាទាំងនេះអាចនាំមកនូវអត្ថប្រយោជន៍ដល់អ្នកប្រើប្រាស់ ប៉ុន្តែក៏អាចនាំមកនូវហានិភ័យថ្មីៗដែលជាក់លាក់ចំពោះវិស័យសេវាហិរញ្ញវត្ថុ ហើយទាមទារឱ្យមានគោលនយោបាយឆ្លើយតប។ គ្រឹះស្ថានហិរញ្ញវត្ថុក៏ត្រូវប្រឈមនឹងបញ្ហានៅពេលដាក់ចេញក្របខណ្ឌបទប្បញ្ញត្តិស្ដីពីឯកជនភាពដូចជា ភាពបត់បែននៃព័ត៌មាន ការរីកសាយនៃប្រព័ន្ធផ្សព្វផ្សាយសង្គម ឧក្រិដ្ឋកម្មសាយប័រ និងការលើកកម្ពស់ចំណេះដឹងនិយោជិតពាក់ព័ន្ធការការពារទិន្នន័យ។ ការងារទាំងនេះពាក់ព័ន្ធការរៀបចំក្របខណ្ឌការពារអ្នកប្រើប្រាស់សមស្របនៅក្នុងបរិដ្ឋានឌីជីថល ស្ថាប័នទទួលបន្ទុកការការពារទិន្នន័យ និងចំណេះដឹងផ្នែកឌីជីថលនិងហិរញ្ញវត្ថុ។

### ខ. បញ្ហាប្រឈម

ដោយសារទិន្នន័យបានផ្ដល់អត្ថប្រយោជន៍សម្រាប់សេដ្ឋកិច្ចឌីជីថល តាមរយៈការផ្ដល់ព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ច សង្គម និងនយោបាយ សិទ្ធិក្នុងការរក្សាឯកជនភាពទិន្នន័យផ្ទាល់ខ្លួនទទួលបានការចាប់អារម្មណ៍កាន់តែខ្លាំងឡើងនាពេលថ្មីៗនេះ។ បទប្បញ្ញត្តិស្ដីពីក្របខណ្ឌការពារទិន្នន័យមានចែងជាយូរមកហើយនៅតាមវិស័យនីមួយៗ ប៉ុន្តែបរិវត្តកម្មសេដ្ឋកិច្ចឌីជីថលនៅទូទាំងពិភពលោកធ្វើឱ្យអាជ្ញាធរនៅក្នុងប្រទេសនីមួយៗដាក់ចេញបទប្បញ្ញត្តិថ្មីៗ ឬធ្វើបច្ចុប្បន្នកម្មបទប្បញ្ញត្តិដែលមានស្រាប់ទាក់ទងនឹងការប្រមូលទិន្នន័យ ការប្រើប្រាស់ និងការការពារទិន្នន័យ។ ដោយហេតុថាប្រទេសកម្ពុជាមិនមានក្របខណ្ឌច្បាប់ស្ដីពីការការពារទិន្នន័យ ការរៀបចំក្របខណ្ឌការពារទិន្នន័យសម្រាប់

វិស័យធនាគារអាចនឹងបញ្ជាក់ឱ្យកាន់តែច្បាស់ថែមទៀតនូវរាល់បញ្ហាពាក់ព័ន្ធទិន្នន័យ ក្នុងគោលបំណង លើកកម្ពស់ផលិតផល និងសេវាប្រកបដោយនវានុវត្តន៍ ក៏ដូចជាការអភិវឌ្ឍវិស័យធនាគារ និងវិស័យ បច្ចេកវិទ្យាហិរញ្ញវត្ថុ។

## ៤. ក្របខណ្ឌសន្តិសុខសាយប័រ

### ក. ស្ថានភាពបច្ចុប្បន្ន

ក្របខណ្ឌសន្តិសុខសាយប័រ ជាការអនុវត្តវិធានការការពារប្រព័ន្ធសំខាន់ៗ និងព័ត៌មានសំខាន់ៗ ពីការវាយប្រហារតាមប្រព័ន្ធឌីជីថល។ វិធានការសន្តិសុខសាយប័រ ឬសន្តិសុខព័ត៌មានវិទ្យាត្រូវបាន បង្កើតឡើង ដើម្បីប្រយុទ្ធប្រឆាំងនឹងការគំរាមកំហែងមកលើបណ្តាញប្រព័ន្ធ និងកម្មវិធីពីប្រភពខាង ក្នុង ឬខាងក្រៅស្ថាប័ន។ បច្ចុប្បន្ន បច្ចេកវិទ្យាឌីជីថលរូបនីយកម្មបានផ្លាស់ប្តូររបៀបនៃការចំណាយ សន្សំ និងផ្តល់ប្រាក់កម្ចី ស្របពេលដែលការផ្តល់ផលិតផលនិងសេវាតាមមធ្យោបាយអនឡាញកាន់តែ ច្រើនបានធ្វើឱ្យក្របខណ្ឌសន្តិសុខសាយប័រក្លាយជាបញ្ហាប្រឈមមួយសម្រាប់បច្ចេកវិទ្យាហិរញ្ញវត្ថុ និងវិស័យហិរញ្ញវត្ថុ។ អាជ្ញាធរមានសមត្ថកិច្ចកំពុងដោះស្រាយបញ្ហានេះ តាមរយៈការដាក់ចេញ វិធានការបទប្បញ្ញត្តិមួយចំនួនរួមមាន ការចេញបទប្បញ្ញត្តិថ្នាក់ជាតិនិង/ឬតាមវិស័យ គោលការណ៍ ណែនាំ និងការត្រួតពិនិត្យដែលមានគោលដៅរួម ក្នុងការបង្កើតក្របខណ្ឌសន្តិសុខសាយប័រ សម្រាប់ សម្រួលដល់ស្ថាប័ននិងគ្រឹះស្ថានក្នុងការកាត់បន្ថយហានិភ័យសាប័រ និងការឆ្លើយតប និងការស្តារ ឡើងវិញពីការវាយប្រហារតាមសាយប័រប្រកបដោយប្រសិទ្ធភាព។ វិធានការបទប្បញ្ញត្តិទាំងនេះ ត្រូវបានដកស្រង់ចេញពីក្របខណ្ឌសន្តិសុខសាយប័រ និងការណែនាំផ្សេងៗជាច្រើនដែលរៀបចំដោយ ស្ថាប័នជាតិ អន្តរជាតិ ទាំងវិស័យសាធារណៈ និងឯកជន។ ការកសាងក្របខណ្ឌសន្តិសុខសាយប័រ ចាប់ផ្តើមពីការតម្រូវឱ្យគ្រឹះស្ថានហិរញ្ញវត្ថុរៀបចំចងក្រងកម្មវិធី ឬគោលនយោបាយស្តីពី សន្តិសុខ សាយប័រ ព្រមទាំងកំណត់អត្តសញ្ញាណព័ត៌មានសំខាន់ៗដែលចាំបាច់ត្រូវការពារ។ ការធ្វើតេស្ត សាកល្បងលើភាពងាយរងគ្រោះ និងភាពធន់របស់គ្រឹះស្ថានទប់ទល់នឹងហានិភ័យសាយប័រ ក៏ដូចជា ការរាយការណ៍អំពីព្រឹត្តិការណ៍សាយប័រជាលក្ខខណ្ឌតម្រូវចាំបាច់។ ការបែងចែកតួនាទីនិងភារកិច្ច នៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុ និងការធានានូវគុណវុឌ្ឍន៍របស់តតិយភាគីក៏ ជាសមាសធាតុសំខាន់នៅ ក្នុងលក្ខខណ្ឌតម្រូវនានានៃក្របខណ្ឌសន្តិសុខសាយប័រ។

នៅប្រទេសកម្ពុជា អាជ្ញាធរមានសមត្ថកិច្ចព្យាយាមឆ្លើយតបទៅនឹងបញ្ហាទាំងនេះតាមរយៈ ការរៀបចំក្របខណ្ឌបទប្បញ្ញត្តិ ក៏ដូចជាការបង្កើតស្ថាប័នទទួលបន្ទុកសន្តិសុខសាយប័រ។ នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ ក្រុមការងាររៀបចំច្បាប់របស់ទីស្តីការគណៈរដ្ឋមន្ត្រីបានបញ្ចប់សេចក្តីព្រាងច្បាប់ ស្តីពី "ឧក្រិដ្ឋកម្មសាយប័រ"។ សេចក្តីព្រាងច្បាប់នេះ ធ្វើនិយ័តកម្មរាល់បញ្ហាដែលទាក់ទងនឹងសាយប័រ រួមមាន សន្តិសុខសាយប័រ និងឧក្រិដ្ឋកម្មសាយប័រ ក្រោមការត្រួតពិនិត្យរបស់គណៈកម្មាធិការជាតិ ប្រឆាំងឧក្រិដ្ឋកម្មសាយប័រ ដែលមានតួនាទីក្នុងការអនុវត្តច្បាប់ និងធ្វើការស៊ើបអង្កេត។ នៅក្នុងកិច្ច ខិតខំប្រឹងប្រែងស្តីពីសន្តិសុខសាយប័រនេះដែរ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញគោលការណ៍ ណែនាំស្តីពី "ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា" ដើម្បីសម្របសម្រួលដល់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុក្នុងការបង្កើតប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាប្រកបដោយសុវត្ថិភាព។ ការអនុវត្តត្រូវផ្អែកលើ

គោលការណ៍ហានិភ័យ ដូចមានចែងនៅក្នុងគោលការណ៍ណែនាំ ក្នុងគោលដៅបង្កើនសុវត្ថិភាព សន្តិសុខ និងប្រសិទ្ធភាពនៃប្រតិបត្តិការធុរកិច្ច ដែលនឹងផ្តល់អត្ថប្រយោជន៍ដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងអ្នកប្រើប្រាស់។

### ខ. បញ្ហាប្រឈម

ក្របខណ្ឌសន្តិសុខសាយប័រថ្នាក់ជាតិ ស្ថិតក្នុងដំណាក់កាលរៀបចំនៅឡើយ ហើយទាមទារឱ្យមានការចូលរួមពីគ្រប់វិស័យ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ។ សម្រាប់វិស័យធនាគារ គោលការណ៍ណែនាំស្តីពី "ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា" ត្រូវបានដាក់ឱ្យប្រើប្រាស់នៅក្នុងខែកក្កដា ឆ្នាំ២០១៩ ដើម្បីសម្របសម្រួលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការបង្កើតប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាប្រកបដោយសុវត្ថិភាព។ ប៉ុន្តែគោលការណ៍ណែនាំនេះមិនបានលើកឡើងអំពី សន្តិសុខសាយប័រនៅក្នុងវិស័យធនាគារ ដែលកំណត់ពីតួនាទី និងការទទួលខុសត្រូវរបស់អាជ្ញាធរត្រួតពិនិត្យ និងគ្រឹះស្ថានហិរញ្ញវត្ថុក្នុងករណីមានការវាយប្រហារសាយប័រធ្ងន់ធ្ងរ ក៏ដូចជាគាំទ្រដល់ក្របខណ្ឌសន្តិសុខសាយប័រថ្នាក់ជាតិ។ បន្ថែមពីនេះទៀត ក្របខណ្ឌសន្តិសុខសាយប័រចាំបាច់ត្រូវអនុលោមតាមស្តង់ដារនិងឧត្តមានុវត្តន៍អន្តរជាតិ ព្រមទាំងស្របតាមក្របខណ្ឌសន្តិសុខសាយប័រថ្នាក់ជាតិ ដើម្បីធានាឱ្យមានកិច្ចសហប្រតិបត្តិការកាន់តែស៊ីជម្រៅរវាងនិយ័តករនីមួយៗ និងអនុញ្ញាតឱ្យគ្រឹះស្ថានហិរញ្ញវត្ថុឆ្លើយតបបានទាន់ពេលវេលា មានបរិដ្ឋានរាយការណ៍មិនលំអៀង និងប្រសិទ្ធភាព ព្រមទាំងដាក់ទណ្ឌកម្មចំពោះជនល្មើសលើឧក្រិដ្ឋកម្មឌីជីថលដែលបានកើតឡើង ដូចជាការបោកប្រាស់ ការបោកបញ្ឆោត ការវាយប្រហារ និងការបំពានសន្តិសុខសាយប័រផ្សេងៗ។

## ៥. ចំណេះដឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ និងឌីជីថល

### ក. ស្ថានភាពបច្ចុប្បន្ន

បច្ចេកវិទ្យាហិរញ្ញវត្ថុដែលប្រើប្រាស់មធ្យោបាយឌីជីថល ដើម្បីផ្តល់សេវាហិរញ្ញវត្ថុដល់អ្នកប្រើប្រាស់ និងធុរកិច្ចតាមរយៈឧបករណ៍ឌីជីថលដូចជា ទូរស័ព្ទវៃឆ្លាតជាដើម ត្រូវបានទទួលស្គាល់ថាជាឧបករណ៍ដែលមានសក្តានុពលក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ ទោះជាយ៉ាងណាការលើកកម្ពស់លទ្ធភាពទទួលបាននូវសេវាហិរញ្ញវត្ថុដែលមានភាពល្អប្រសើរតាមរយៈបច្ចេកវិទ្យាហិរញ្ញវត្ថុទាមទារនូវការយល់ដឹងផ្នែកហិរញ្ញវត្ថុឌីជីថលខ្ពស់ ដើម្បីប្រើប្រាស់សេវាទាំងនោះឱ្យមានប្រសិទ្ធភាព និងជៀសវាងការឆបោក ការក្លែងបន្លំ ការប្រើប្រាស់ទិន្នន័យដោយគ្មានការអនុញ្ញាត ការផ្តល់សេវាដោយមិនស្មើភាព និងបញ្ហាផ្សេងៗពាក់ព័ន្ធនឹងឥរិយាបថដូចជា ការខ្ចីហួសកម្រិត ជាដើម។ ដូចនេះ ចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថល មានសារៈសំខាន់កាន់តែខ្លាំងឡើងសម្រាប់ការអប់រំនៅក្នុងយុគសម័យឌីជីថល។ ការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុបែបរិមជ្ឈការតម្រូវឱ្យអ្នកប្រើប្រាស់មានសមត្ថភាព និងចំណេះដឹងគ្រប់គ្រាន់ក្នុងការវិភាគព័ត៌មានហិរញ្ញវត្ថុ។ កត្តានេះបង្ហាញពីភាពចាំបាច់ក្នុងការដាក់បញ្ចូលការអប់រំផ្នែកហិរញ្ញវត្ថុឌីជីថលទៅក្នុងយុទ្ធសាស្ត្រអប់រំផ្នែកហិរញ្ញវត្ថុ ដោយសារយុទ្ធសាស្ត្រនេះមិនបានលើកឡើងអំពីចំណេះដឹងហិរញ្ញវត្ថុឌីជីថលនោះទេ ប៉ុន្តែផ្តោតសំខាន់ទៅលើតែទស្សនទានហិរញ្ញវត្ថុមូលដ្ឋានប៉ុណ្ណោះ។

នៅប្រទេសកម្ពុជា ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុជាការងារអាទិភាពរបស់ធនាគារ-ជាតិនៃកម្ពុជា។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ដើម្បីអនុវត្តការងារអាទិភាពនេះ ដូចដែលបានកំណត់នៅក្នុងយុទ្ធសាស្រ្តជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥។ ធនាគារជាតិនៃកម្ពុជាបានអនុវត្តកម្មវិធីចំណេះដឹងផ្នែកហិរញ្ញវត្ថុជាបន្តបន្ទាប់ ដើម្បីអប់រំសាធារណជនកម្ពុជាឱ្យយល់ដឹងពីសិទ្ធិរបស់អ្នកប្រើប្រាស់ និងតម្លាភាពនៃវិស័យហិរញ្ញវត្ថុ ក្នុងគោលបំណងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងការពារដល់អ្នកប្រើប្រាស់ដែលងាយរងគ្រោះ។ កម្មវិធីចំណេះដឹងផ្នែកហិរញ្ញវត្ថុនេះ ក៏ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ ដែលមុខវិជ្ជាពាក់ព័ន្ធនឹងសេវាហិរញ្ញវត្ថុត្រូវបានរៀបចំឡើង និងដាក់ឱ្យអនុវត្តក្នុងកម្មវិធីសិក្សា។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានអនុវត្តកម្មវិធីផ្សព្វផ្សាយជាសាធារណៈ ដោយសហការជាមួយដៃគូនានាដូចជា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រសួងកិច្ចការនារី និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុកាន់តែទូលំទូលាយ។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានសហការជាមួយស្ថាប័ន "Good Return" ដើម្បីអនុវត្តយុទ្ធនាការ "តោះ និយាយពីលុយ" តាមរយៈការបោះពុម្ពជាសៀវភៅត្លុក ការផ្សព្វផ្សាយតាមកម្មវិធីទូរស័ព្ទចល័ត (NBC-Edu) បណ្តាញសង្គមហ្វេសប៊ុក វិទ្យុ និងគេហទំព័រ "តោះ! និយាយពីលុយ"។

ទោះជាយ៉ាងណា កម្មវិធីចំណេះដឹងផ្នែកហិរញ្ញវត្ថុបច្ចុប្បន្ន មិនបានលើកយកនូវទិដ្ឋភាពផ្សេងៗនៃសេវាធនាគារឌីជីថលមកសិក្សាឱ្យស្របតាមការរីកចម្រើននៃបច្ចេកវិទ្យា និងកំណើននៃការប្រើ-ប្រាស់សេវាឌីជីថលនៅក្នុងវិស័យធនាគារនោះទេ។ ហេតុដូចនេះ ការចូលរួមពីភាគីពាក់ព័ន្ធផ្សេងៗជាភាពចាំបាច់ ដើម្បីពង្រីកវិសាលភាពនៃកម្មវិធីសិក្សាបច្ចុប្បន្នបន្ថែមទៀត ក្នុងគោលដៅផ្តល់ និងលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុឌីជីថល។

### ខ. បញ្ហាប្រឈម

ការរីកចម្រើននៃសេវាធនាគារឌីជីថលដ៏សំបូរបែបផ្តល់ដោយគ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ បានជំរុញឱ្យការរៀបចំមុខវិជ្ជាផ្នែកចំណេះដឹងហិរញ្ញវត្ថុកាន់តែមានភាពស្មុគស្មាញឡើង។ កំណើនប្រតិបត្តិការឌីជីថលជាចំនុចសំខាន់មួយទៀតដែលបង្ហាញថា សាធារណជនចាំបាច់ត្រូវទទួលបាននូវការអប់រំអំពីចំណេះដឹងផ្នែកឌីជីថល។ ធនាគារ-ជាតិនៃកម្ពុជាគាំទ្រឱ្យមានកិច្ចសហប្រតិបត្តិការជាមួយគ្រប់ភាគីពាក់ព័ន្ធនៅក្នុងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីលើកទឹកចិត្តនិងជំរុញដល់ការដាក់ចេញយុទ្ធសាស្រ្ត និងកម្មវិធីលើកកម្ពស់ចំណេះដឹងអំពីផលិតផលនិងសេវាកម្មផ្តល់ដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ ក៏ដូចជាពង្រឹងការអប់រំអំពីចំណេះដឹងហិរញ្ញវត្ថុឌីជីថល។ ក្រោមកិច្ចខិតខំប្រឹងប្រែងនេះ បច្ចេកវិទ្យាហិរញ្ញវត្ថុត្រូវបានលើកទឹកចិត្តឱ្យដាក់ចេញនូវយុទ្ធនាការផ្សព្វផ្សាយអំពីផលិតផលរបស់ខ្លួន និងរួមចំណែកដល់កម្មវិធីអប់រំផ្នែកហិរញ្ញវត្ថុឌីជីថលសម្រាប់វិស័យទាំងមូល។ យុទ្ធនាការនេះត្រូវផ្សព្វផ្សាយចំណេះដឹងអំពីការគ្រប់គ្រងហានិភ័យ និងការដោះស្រាយបណ្តឹងរបស់អ្នកប្រើប្រាស់ទៅតាមដំណាក់កាលនីមួយៗ។ ដើម្បីតាមដានលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងទាំងនេះ ធនាគារជាតិនៃកម្ពុជាអាចធ្វើការស្ទង់មតិជាសាធារណៈប្រចាំឆ្នាំ ក្នុងគោលបំណងវាយតម្លៃពីសមត្ថភាពយល់ដឹងផ្នែកហិរញ្ញវត្ថុរបស់អ្នកប្រើប្រាស់ និងបន្តសហការជាមួយ

បច្ចេកវិទ្យាហិរញ្ញវត្ថុ ក៏ដូចជាវិស័យហិរញ្ញវត្ថុទាំងមូល ក្នុងការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីការអប់រំផ្នែកហិរញ្ញវត្ថុ រួមទាំងចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងឌីជីថល។ ជាពិសេស សហគ្រិនស្ត្រីអាចទទួលបានអត្ថប្រយោជន៍ពីបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលជួយបង្កើនសមត្ថភាពផ្នែកហិរញ្ញវត្ថុ និងជំនាញគ្រប់គ្រង។ លើសពីនេះទៀត យុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថល ក៏អាចរួមបញ្ចូលកម្មវិធីសិក្សាអំពីយេនឌ័រផងដែរ។

## ៦. គំនិតផ្តួចផ្តើមជំរុញនវានុវត្តន៍

### ៦.១. បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ

#### ក. ស្ថានភាពបច្ចុប្បន្ន

បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ ជាបរិយាកាសធ្វើតេស្តសាកល្បងដែលត្រូវបានគ្រប់គ្រង ហើយផ្នែកក្របខណ្ឌគតិយុត្តមានលក្ខណៈលើកលែង និងបន្ធូរបន្ថយ តាមរយៈការប្រើប្រាស់ឆន្ទានុសិទ្ធិដោយអាជ្ញាធរមានសមត្ថកិច្ច។ បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ ជាវិធីសាស្ត្រសម្របសម្រួលនវានុវត្តន៍ ដែលបានអនុវត្តនៅតាមបណ្តាប្រទេសមួយចំនួន ក្នុងគោលបំណង (១)កាត់បន្ថយពេលវេលា និងការចំណាយក្នុងការដាក់ដំណើរការផលិតផលឬសេវាកម្មប្រកបដោយនវានុវត្តន៍ដល់អ្នកប្រើប្រាស់ (២)វិភាគហានិភ័យនៃការអនុវត្តគំរូធុរកិច្ចនិងបច្ចេកវិទ្យាថ្មីៗ (៣)ពិនិត្យលើបទប្បញ្ញត្តិពាក់ព័ន្ធក្នុងការគ្រប់គ្រងហានិភ័យ ក៏ដូចជាគាំទ្រដល់ការជំរុញនវានុវត្តន៍នៅក្នុងទីផ្សារ។ ធុរកិច្ចដែលធ្វើឡើងនៅក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ ត្រូវបានត្រួតពិនិត្យដោយផ្ទាល់ពីនិយ័តករ ហើយដើម្បីគ្រប់គ្រងហានិភ័យសាធារណៈ ធុរកិច្ចអាចផ្តល់ផលិតផលឬសេវាទៅឱ្យអ្នកប្រើប្រាស់មានចំនួនកំណត់នៅក្នុងរយៈពេលកំណត់ណាមួយ ហើយស្ថិតក្រោមលក្ខខណ្ឌណាមួយ។ បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដូចជា កាត់បន្ថយការដាក់ចេញបទប្បញ្ញត្តិដែលមានមិនមានភាពច្បាស់លាស់ និងលើកកម្ពស់ការប្រាស្រ័យទាក់ទងរវាងនិយ័តករ និងបច្ចេកវិទ្យាហិរញ្ញវត្ថុឱ្យកាន់តែមានប្រសិទ្ធភាព។ លើសពីនេះ ការដាក់ដំណើរការសាកល្បងនូវផលិតផលឬសេវានវានុវត្តន៍ក្រោមបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ នឹងផ្តល់ទិន្នន័យសំខាន់ៗដល់និយ័តករសម្រាប់គាំទ្រដល់ការដាក់ចេញគោលនយោបាយថ្មីៗ។

គម្រោងប្រតិបត្តិការក្រោមបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ មានលក្ខណៈខុសប្លែកគ្នាទៅតាមធុរកិច្ចគោលដៅ លក្ខណៈវិនិច្ឆ័យក្នុងការទទួលយកការសាកល្បង ទំហំប្រតិបត្តិការសាកល្បង នីតិវិធីស្នើសុំចូលរួមសាកល្បង និងការបញ្ចប់ការសាកល្បង។ នៅក្នុងប្រទេសមួយចំនួន ការអនុវត្តបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ ធ្វើឡើងសម្រាប់តែធុរកិច្ចថ្មីៗដែលមិនទាន់មានអាជ្ញាបណ្ណស្របច្បាប់ក្នុងការផ្តល់សេវាហិរញ្ញវត្ថុ ចំណែកការអនុវត្តនៅប្រទេសដទៃទៀតបើកទូលាយដល់គ្រឹះស្ថានដែលមានអាជ្ញាបណ្ណរួចរាល់ ព្រមទាំងប្រតិបត្តិករផ្តល់បច្ចេកវិទ្យា។ ធុរកិច្ចអាចទទួលឱ្យចូលរួមក្នុងគម្រោងសាកល្បងមានលក្ខណៈជាក្រុម និងទៅតាមនិរន្តរភាពស្នើសុំជាបន្តបន្ទាប់ ហើយជាទូទៅ បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុបើកទូលាយដល់គម្រោងធុរកិច្ចនវានុវត្តន៍ ដែលផ្តល់អត្ថប្រយោជន៍ដល់អ្នកប្រើប្រាស់។ អាស្រ័យលើរបបនិយ័តកម្មនៅក្នុងប្រទេសនីមួយៗ បរិស្ថាន

សាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុអាចនឹងរៀបចំឡើងដោយនិយ័តករហិរញ្ញវត្ថុផ្សេងៗ។ បរិស្ថានសាក-ល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ អាចរៀបចំឡើងមានលក្ខណៈជាក្របខណ្ឌអន្តរជាតិ ដោយមានការចូលរួមពីនិយ័តករហិរញ្ញវត្ថុមកពីបណ្តាប្រទេសផ្សេងៗ ដូចជាករណី Global Financial Innovation Network ដែលជាសហព័ន្ធអន្តរជាតិនៃនិយ័តករមកពីប្រទេសផ្សេងៗ ដឹកនាំដោយអាជ្ញាធរការពារអ្នកប្រើប្រាស់អង់គ្លេស ដើម្បីផ្តល់លទ្ធភាពឱ្យដំណើរការសាកល្បងឆ្លងដែននូវបច្ចេកវិទ្យាថ្មីៗ។ មកទល់ពេលនេះ គម្រោងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុជាលក្ខណៈសកលនេះ មានសមាជិកប្រមាណ ៥០ ដែលជានិយ័តករនិងអាជ្ញាធរត្រួតពិនិត្យ ធនាគារកណ្តាល និងស្ថាប័នអន្តរជាតិ។

បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុកម្ពុជា មិនទាន់បានរៀបចំនៅឡើយ ប៉ុន្តែការយកចិត្តទុកដាក់គាំទ្រដល់វិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុនិងនវានុវត្តន៍ ត្រូវបានអនុវត្តតាំងពីឆ្នាំ២០០៨ មកម្លេះ នៅពេលដែលធនាគារជាតិនៃកម្ពុជាបានអនុញ្ញាតឱ្យប្រតិបត្តិករផ្តល់សេវាហិរញ្ញវត្ថុឌីជីថលមានវត្តមាននៅប្រទេសកម្ពុជា។ ខណៈដែលក្របខណ្ឌបទប្បញ្ញត្តិមិនទាន់បានដាក់ចេញ ធនាគារជាតិនៃកម្ពុជាបានបង្កើតរបបគ្រប់គ្រង តាមរយៈការផ្តល់លិខិតមិនជំទាស់ដែលជាក្របខណ្ឌដំបូងនៃបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុនាពេលបច្ចុប្បន្ននេះដល់ប្រតិបត្តិករផ្តល់សេវាឌីជីថលដំណើរការនៅក្នុងទីផ្សារប្រទេសកម្ពុជា។ ការដាក់ចេញរបបគ្រប់គ្រងនៅពេលនោះ មានគោលបំណងលើកកម្ពស់នវានុវត្តន៍ថ្មីនៅក្នុងសេវាកម្មហិរញ្ញវត្ថុ ក៏ដូចជាកាត់បន្ថយហានិភ័យដែលអាចកើតមាន។ ទោះបីជាបទប្បញ្ញត្តិគ្រប់គ្រងត្រូវបានដាក់ចេញនៅឆ្នាំ២០១០ តម្រូវឱ្យប្រតិបត្តិករផ្តល់សេវាហិរញ្ញវត្ថុឌីជីថលធ្វើការស្នើសុំអាជ្ញាបណ្ណ យន្តការអនុញ្ញាតឱ្យមានការធ្វើតេស្តសាកល្បង និងការសិក្សាទីផ្សារត្រូវបានអនុវត្តរហូតមកដល់សព្វថ្ងៃ។ ធនាគារជាតិនៃកម្ពុជាធ្វើការប្រឹក្សាជាប្រចាំជាមួយគ្រប់ភាគីពាក់ព័ន្ធនៅក្នុងឧស្សាហកម្មហិរញ្ញវត្ថុ រួមទាំងបច្ចេកវិទ្យាហិរញ្ញវត្ថុលើប្រធានបទពាក់ព័ន្ធប្រតិបត្តិការប្រើប្រាស់ប្រកបដោយនវានុវត្តន៍ ក៏ដូចជាបច្ចេកវិទ្យាដែលផ្តល់នូវអត្ថប្រយោជន៍ដល់វិស័យទាំងមូល។ ដើម្បីជំរុញឱ្យយន្តការដែលមានឱ្យកាន់តែមានសុក្រឹតភាព និងតម្លាភាពថែមទៀតពាក់ព័ន្ធនឹងការលើកកម្ពស់នវានុវត្តន៍និងគ្រប់គ្រងហានិភ័យ ធនាគារជាតិនៃកម្ពុជាពិនិត្យមើលលើការអនុវត្ត និងបទពិសោធន៍នៅតាមប្រទេសនានានៅលើសកលលោក និងកែច្នៃសម្រាប់អនុវត្តឱ្យត្រូវស្ថានភាពប្រទេសកម្ពុជា។

## ខ. បញ្ហាប្រឈម

បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុលែងជាទស្សនទានថ្មីហើយក្នុងការលើកកម្ពស់នវា-នុវត្តន៍។ ខណៈពេលដែលចំណាប់អារម្មណ៍លើបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុនៅតែមានការព្រួយបារម្ភលើបញ្ហានានា ជាពិសេសជាជាងសម្របសម្រួលនវានុវត្តន៍ បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ អាចដើរតួជាអ្នករារាំង បន្ទុចបង្អាក់ ឬបញ្ឈប់នវានុវត្តន៍។ ក្នុងករណីខ្លះ ប្រសិនបើបានរៀបចំការអនុវត្ត និងការត្រួតពិនិត្យមិនបានត្រឹមត្រូវទេ នោះបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុអាចបង្កផលលំបាកដល់អ្នកប្រើប្រាស់។ ការធ្វើតេស្តសាកល្បងអាចនាំមកនូវអត្ថប្រយោជន៍ជាច្រើនទាក់ទងនឹងការបង្កើតនវានុវត្តន៍នៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ប៉ុន្តែចាំបាច់ត្រូវតែអនុវត្តទៅតាមស្ថានភាពជាក់-ស្តែងនៅក្នុងប្រទេសនីមួយៗ។ ទោះបីជាបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុមិនបានដាក់

ចេញជាផ្លូវការ នវានុវត្តន៍នៅក្នុងវិស័យធនាគារនៅប្រទេសកម្ពុជាសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់។ ជាជាងដាក់ចេញបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុដោយមិនមានភាពច្បាស់លាស់ អាជ្ញាធរមានសមត្ថកិច្ចអាចផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើការដាក់ចេញគោលនយោបាយលើកកម្ពស់នវានុវត្តន៍ ដែលអាចសម្រេចបានគោលដៅចុងក្រោយ។

### ៦.២. មជ្ឈមណ្ឌលនវានុវត្តន៍

#### ក. ស្ថានភាពបច្ចុប្បន្ន

មជ្ឈមណ្ឌលនវានុវត្តន៍ សំដៅដល់មជ្ឈមណ្ឌលផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុដែលបង្កើតឡើងដោយអាជ្ញាធរត្រួតពិនិត្យ ដើម្បីផ្តល់ការណែនាំ ការគាំទ្រ និងការចង្អុលបង្ហាញដល់ប្រតិបត្តិករស្ថិតក្រោម ឬមិនស្ថិតក្រោមបទប្បញ្ញត្តិ ក្នុងគោលបំណងតម្រង់ទិសក្របខណ្ឌគតិយុត្ត ឬកំណត់គោលនយោបាយត្រួតពិនិត្យ ឬប្រឹក្សាផ្នែកច្បាប់ និងបញ្ហាផ្សេងទៀត។ មុខងារនិងភារកិច្ចនៃមជ្ឈមណ្ឌលនវានុវត្តន៍មានភាពខុសប្លែកគ្នាដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ឧស្សាហកម្ម ផ្តល់ការណែនាំក្រៅផ្លូវការ ឬផ្តល់ជំនួយក្នុងការរៀបចំការស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត ឬផលិតផលថ្មី។ ការបង្កើតមជ្ឈមណ្ឌលនវានុវត្តន៍ជាមធ្យោបាយចម្បង ដែលរៀបចំដោយនិយ័តករដើម្បីបង្កើតទំនាក់-ទំនងជាផ្លូវការជាមួយបច្ចេកវិទ្យាហិរញ្ញវត្ថុ។ មជ្ឈមណ្ឌលនវានុវត្តន៍ផ្តល់អត្ថប្រយោជន៍សម្រាប់និយ័តករ និងបច្ចេកវិទ្យាហិរញ្ញវត្ថុដូចជា កាត់បន្ថយការចំណាយ និងផ្តល់នូវព័ត៌មានសម្រាប់ដាក់ចេញគោល-នយោបាយ។ មជ្ឈមណ្ឌលនវានុវត្តន៍កាត់បន្ថយចំណាយសម្រាប់អ្នកប្រើប្រាស់ និងបច្ចេកវិទ្យាហិរញ្ញវត្ថុដោយផ្តល់លទ្ធភាពឱ្យនវានុវត្តន៍ជនធ្វើការប្រាស្រ័យទាក់ទងជាមួយនិយ័តករ ដើម្បីឱ្យយល់កាន់តែច្បាស់អំពីក្របខណ្ឌគតិយុត្ត និងតម្រូវការផ្សេងៗដែលជួយកាត់បន្ថយភាពមិនច្បាស់លាស់នៃបទប្បញ្ញត្តិ។ ជាមួយគ្នានេះ មជ្ឈមណ្ឌលនវានុវត្តន៍ត្រូវបានប្រើប្រាស់ដើម្បីកំណត់ហានិភ័យដែលសេវាហិរញ្ញវត្ថុប្រកបដោយនវានុវត្តន៍អាចប្រឈមមុខនឹងផលប៉ះពាល់លើក្របខណ្ឌគោលនយោបាយបទប្បញ្ញត្តិ។ កត្តាទាំងនេះមានដូចជា ចន្លោះខ្វះខាតក្នុងការកំណត់បទប្បញ្ញត្តិ ការគេចវេសបទប្បញ្ញត្តិ និងបទប្បញ្ញត្តិមិនច្បាស់លាស់ដែលត្រូវពិនិត្យ និងរៀបចំឡើងវិញ។

បច្ចុប្បន្ននេះ នៅមិនទាន់មានការរៀបចំរួមជាផ្លូវការនូវមជ្ឈមណ្ឌលនវានុវត្តន៍រួមសម្រាប់រាល់បច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជានោះទេ។ អាជ្ញាធរបទប្បញ្ញត្តិនីមួយៗដើរតួនាទីក្នុងការផ្លាស់ប្តូរព័ត៌មាន និងផ្តល់គោលការណ៍ណែនាំផ្សេងៗទៅតាមវិសាលភាពបទប្បញ្ញត្តិផ្ទាល់ខ្លួន។ នៅក្នុងវិស័យធនាគារ ធនាគារជាតិនៃកម្ពុជាផ្តល់ការណែនាំអំពីបទប្បញ្ញត្តិទាក់ទងនឹងការអភិវឌ្ឍផលិតផល និងសេវាកម្មដល់បច្ចេកវិទ្យាហិរញ្ញវត្ថុនានានៅក្នុងប្រទេស។ ធនាគារជាតិនៃកម្ពុជា ក៏ដើរតួនាទីជាចំណុចស្នូលក្នុងការទំនាក់ទំនង ចែករំលែកព័ត៌មានរវាងបច្ចេកវិទ្យាហិរញ្ញវត្ថុផ្សេងគ្នានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចំពោះវិស័យហិរញ្ញវត្ថុមិនមែនធនាគារ មជ្ឈមណ្ឌលធុរកិច្ចតេជោ (TECHO Startup Center) អាចចាត់ទុកថាជាមជ្ឈមណ្ឌលនវានុវត្តន៍ ប៉ុន្តែតួនាទីនិងភារកិច្ចនៃមជ្ឈមណ្ឌលនេះមានច្រើន និងលើសពីការណែនាំ និងការចែករំលែកព័ត៌មាន។ មជ្ឈមណ្ឌលនេះចូលរួមអភិវឌ្ឍដោយផ្ទាល់លើគម្រោងនវានុវត្តន៍ណាមួយ ដែលអាចនាំមកនូវផលប្រយោជន៍ដល់វិស័យឯកជន និងសាធារណៈ។ លើសពីនេះទៀត គំនិតផ្តួចផ្តើមរបស់វិស័យឯកជនដូចជា សមាគម

សហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា (CAFT) ក៏គាំទ្រដល់ការពិភាក្សាអំពីបរិស្ថានរបស់បច្ចេកវិទ្យាហិរញ្ញវត្ថុ និងចាត់វិធានការលើការអភិវឌ្ឍលើគម្រោងសំខាន់ៗ។

### ខ. បញ្ហាប្រឈម

កង្វះការរៀបចំជាផ្លូវការក្នុងការបង្កើតមជ្ឈមណ្ឌលនវានុវត្តន៍ ជាបញ្ហាប្រឈមក្នុងការគាំទ្រដល់ការរីកចម្រើននៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងប្រទេស។ ទោះបីជាយន្តការការរៀបចំនាពេលបច្ចុប្បន្នដំណើរការក្នុងកម្រិតខ្លះ ការងារនេះមិនបានផ្តល់នូវមុខងារពេញលេញជាមជ្ឈមណ្ឌលនវានុវត្តន៍រួម ដែលដើរតួជាចំណុចស្នូលក្នុងការទំនាក់ទំនងជាមួយអ្នកជំនាញលើនវានុវត្តភាពក្នុងវិស័យហិរញ្ញវត្ថុ។ ការធ្វើឱ្យប្រសើរឡើងនូវការសន្ទនា និងការចរចាជាសាធារណៈជាមួយអាជ្ញាធរពាក់ព័ន្ធ ការផ្តល់ព័ត៌មានសម្រាប់ដាក់ចេញគោលនយោបាយ ឬការអភិវឌ្ឍបទប្បញ្ញត្តិ និងគំនិតផ្តួចផ្តើមច្នៃប្រឌិតថ្មីសម្រាប់ពេលអនាគត មិនទាន់បង្ហាញឱ្យមានអត្ថប្រយោជន៍ជាក់លាក់នៅឡើយទេ។

យុទ្ធសាស្ត្រ និងអនុសាសន៍ឆ្លើយតបក្នុងការអនុវត្តផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនេះបានដកស្រង់ពីជំពូក ៤។ យុទ្ធសាស្ត្រ និងអនុសាសន៍ឆ្លើយតបទាំងនេះត្រូវបានរៀបចំឡើងស្ថិតនៅក្រោមសសរស្តម្ភចំនួន៣ និងផ្នែកពាក់ព័ន្ធដើម្បីបង្កើតបានយុទ្ធសាស្ត្រមួយយ៉ាងទូលំទូលាយសម្រាប់កំណត់ទិសដៅក្នុងការអនុវត្តផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ។

| សសរស្តម្ភ | ផ្នែក | ការអនុវត្ត | យុទ្ធសាស្ត្រ |
|---|---|---|---|
| សសរស្តម្ភទី១៖ សេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ | សេវាធនាគារឌីជីថល | នៅប្រទេសកម្ពុជា ពុំមានភាពខុសគ្នាទៅលើការគ្រប់គ្រងសេវាដែលអនុញ្ញាតឱ្យប្រើប្រាស់ ឬបទប្បញ្ញត្តិដោយឡែកសម្រាប់ប្រតិបត្តិការធនាគារឌីជីថលនោះទេ។ បច្ចុប្បន្ន ប្រតិបត្តិការដែលចាត់ទុកជាសកម្មភាពធនាគាររួមមាន៖ (១)ការផ្តល់ឥណទាន (២)ការទទួលប្រាក់បញ្ញើ និង (៣)ការផ្តល់មធ្យោបាយទូទាត់។ គ្រឹះស្ថានទាំងឡាយណាដែលផ្តល់សេវាណាមួយក្នុងចំណោមសេវាទាំងបីខាងលើ ត្រូវគោរពតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជាដោយមិនគិតពីមធ្យោបាយនៃការផ្តល់សេវា។ | លើកកម្ពស់ផលិតផល និងសេវាធនាគារឌីជីថលប្រកបដោយនវានុវត្តន៍ |
| | ថ្នាលហិរញ្ញប្បទានបច្ចេកវិទ្យាហិរញ្ញវត្ថុ | នៅក្នុងប្រទេសកម្ពុជា ពុំទាន់មានក្របខណ្ឌបទប្បញ្ញត្តិស្តីពី ថ្នាលហិរញ្ញប្បទានបច្ចេកវិទ្យាហិរញ្ញវត្ថុ សម្រាប់ជួយលើកកម្ពស់ការផ្តល់ឥណទានតាមទម្រង់ឌីជីថលនៅឡើយ។ | រៀបចំក្របខណ្ឌបទប្បញ្ញត្តិដែលទាក់ទងទៅនឹងថ្នាលហិរញ្ញប្បទានបច្ចេកវិទ្យាហិរញ្ញវត្ថុឱ្យស្របទៅតាមបរិបទ និងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជា |
| | មូលធនក្រោដហ្វាន់ឌីង | បច្ចុប្បន្ន ការគ្រប់គ្រងសកម្មភាពមូលធនក្រោដហ្វាន់ឌីងនៅកម្ពុជាស្ថិតនៅក្រោមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។ | មិនមាន |
| | ការប្រើប្រាស់សេវាបម្រើអតិថិជនស្វ័យប្រវត្តិ | ការប្រើប្រាស់សេវាបម្រើអតិថិជនស្វ័យប្រវត្តិនៅមានកម្រិត។ ហេតុនេះ ចំណេះដឹងផ្នែកឌីជីថល និងជំនឿទុកចិត្តលើសេវាបម្រើអតិថិជនស្វ័យប្រវត្តិជាកត្តាសំខាន់។ | មិនមាន |

| | | | |
|---|---|---|---|
| | រូបិយវត្ថុអេឡិចត្រូនិក និងសេវាទូទាត់សងប្រាក់ឌីជីថល | ក្របខណ្ឌបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុផ្នែកសេវាទូទាត់សងប្រាក់ឌីជីថល ត្រូវបានរៀបចំឡើងជាបន្តបន្ទាប់។ បទប្បញ្ញត្តិស្ដីពី ការគ្រប់គ្រងគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ ត្រូវបានប្រកាសឱ្យប្រើកាលពីឆ្នាំ ២០១៧ ដែលគ្របដណ្ដប់លើសេវាដូចជា ការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក ការផ្ទេរប្រាក់ក្នុងស្រុកនិងឆ្លងដែន ការទូទាត់តម្លៃរាយ និងការទូទាត់អនឡាញ។ ទោះជាយ៉ាងនេះក្ដី ការរីកចម្រើនផ្នែកបច្ចេកវិទ្យាក្នុងវិស័យទូទាត់នេះ បាននាំមកនូវហានិភ័យ និងបញ្ហាប្រឈមថ្មីៗដល់អាជ្ញាធរត្រួតពិនិត្យ។ ដូច្នេះ ដើម្បីរក្សាតុល្យភាពរវាងហានិភ័យ និងនវានុវត្តន៍ ចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពក្របខណ្ឌបទប្បញ្ញត្តិឱ្យស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។ | ពិនិត្យក្របខណ្ឌបទប្បញ្ញត្តិ ដើម្បីគាំទ្រដល់នវានុវត្តន៍ និងគ្រប់គ្រងហានិភ័យដែលអាចកើតមាននៅក្នុងសេវាទូទាត់សងប្រាក់ឌីជីថល |
| | បច្ចេកវិទ្យាធានារ៉ាប់រង | រាល់សកម្មភាពធានារ៉ាប់រងទាំងអស់នៅកម្ពុជារាប់បញ្ចូលទាំងបច្ចេកវិទ្យាធានារ៉ាប់រង ត្រូវបានគ្រប់គ្រងដោយច្បាប់ធានារ៉ាប់រងនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឱ្យប្រើកាលពីថ្ងៃទី០៤ ខែសីហា ឆ្នាំ ២០១៤។ ដោយសារបច្ចេកវិទ្យាធានារ៉ាប់រងមានលក្ខណៈជាសេវាធានារ៉ាប់រង ដូច្នេះ ក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុផ្ដល់បច្ចេកវិទ្យាធានារ៉ាប់រងត្រូវស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នៅប្រទេសកម្ពុជាពុំមានច្បាប់គ្រប់គ្រងផ្សេងគ្នារវាងក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុផ្ដល់បច្ចេកវិទ្យាធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងធ្វើប្រតិបត្តិការបែបប្រពៃណីនោះឡើយ ហើយក្រុមហ៊ុនទាំងពីរប្រភេទនេះ ត្រូវគោរពតាមលក្ខខណ្ឌតម្រូវដូចគ្នាក្នុងការធ្វើប្រតិបត្តិការស្របច្បាប់។ | មិនមាន |
| | ទ្រព្យសកម្មគ្រីបតូ | នៅប្រទេសកម្ពុជា ពុំទាន់មានបទប្បញ្ញត្តិជាក់លាក់ណាមួយសម្រាប់គ្រប់គ្រងប្រតិបត្តិការទ្រព្យសកម្មគ្រីបតូនៅឡើយ។ កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជា និយ័តករមូលបត្រកម្ពុជា និងអគ្គស្នងការដ្ឋាននគរបាលជាតិ បានចេញផ្សាយសេចក្ដីថ្លែងការណ៍រួមមួយ ក្នុងគោលបំណងដាក់កំហិតហាមឃាត់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជួញដូរដោយផ្ទាល់ ឬដោយប្រយោលពាក់ព័ន្ធនឹងប្រតិបត្តិការទ្រព្យសកម្មគ្រីបតូ ហើយក៏បានផ្សព្វផ្សាយដល់សាធារណជនឱ្យប្រុងប្រយ័ត្នអំពីហានិភ័យរបស់ទ្រព្យសកម្មគ្រីបតូនេះផងដែរ។ | មិនមាន |

| | | | |
|---|---|---|---|
| សសរស្តម្ភទី២៖ បច្ចេកវិទ្យាគាំទ្រ | សន្ទានកម្មនៃកម្មវិធីកំព្យូទ័រ | ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ការប្រើប្រាស់បច្ចេកវិទ្យាសន្ទានកម្មនៃកម្មវិធីកំព្យូទ័រក្នុងប្រទេស កម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ប៉ុន្តែស្តង់ដារបច្ចេកទេសនិងសេចក្តីណែនាំរួមអំពី សន្ទានកម្មនៃកម្មវិធីកំព្យូទ័រនៅមិនទាន់បានកំណត់នៅឡើយ។ ដូច្នេះ ដើម្បីធានាបាននូវការតភ្ជាប់ជាមួយបណ្តាញទូទាត់ស្មើរភាពគ្នាក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ សេចក្តីណែនាំរួម/កម្រិតខ្ពស់ស្តីពី សន្ទានកម្មនៃកម្មវិធីកំព្យូទ័រគួរតែត្រូវបានដាក់ចេញ ដើម្បីលើកកម្ពស់ការប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកំព្យូទ័រនៅក្នុងវិស័យធនាគារ។ | ដាក់ចេញគោលការណ៍ណែនាំ ដើម្បីជំរុញការដាក់ឱ្យប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រនៅក្នុងគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ |
| | បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សា | ការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិតនិងម៉ាស៊ីនស្វ័យសិក្សាសម្រាប់វិស័យធនាគារនៅកម្ពុជាស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ។ | ពិចារណាដាក់ចេញគោលការណ៍ណែនាំស្តីពី ការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សាក្នុងវិស័យធនាគារ |
| | បច្ចេកវិទ្យាជីវមាត្រ | ការប្រើប្រាស់ទិន្នន័យជីវមាត្រសម្រាប់កំណត់ និងផ្ទៀងផ្ទាត់អត្តសញ្ញាណអ្នកប្រើប្រាស់នៅក្នុងវិស័យធនាគារស្ថិតនៅដំណាក់កាលដំបូង ហើយពុំមានហេដ្ឋារចនាសម្ព័ន្ធឌីជីថលរួមសម្រាប់ការចែករំលែកប្រើប្រាស់ថ្នាក់ជាតិ និងសម្រាប់វិស័យហិរញ្ញវត្ថុនៅឡើយ។ ទន្ទឹមនឹងនេះ បទប្បញ្ញត្តិចំពោះការប្រើប្រាស់ទិន្នន័យជីវមាត្រស្ថិតក្នុងភាពស្រពិចស្រពិល។ ដោយឡែកចំពោះការអនុវត្តបច្ចុប្បន្ន បច្ចេកវិទ្យានេះត្រូវបានពិនិត្យនិងអនុញ្ញាតឱ្យប្រើ-ប្រាស់តាមករណីម្តងមួយៗ។ | ជំរុញការប្រើប្រាស់បច្ចេកវិទ្យាជីវមាត្រនៅក្នុងគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ |
| | បច្ចេកវិទ្យាក្លោដ | នៅក្នុងប្រទេសកម្ពុជា ការប្រើប្រាស់សេវាបច្ចេកវិទ្យាក្លោដមិនទាន់ឈានដល់សក្តានុពលពេញលេញនៅឡើយទេ។ បច្ចុប្បន្ន គ្រឹះស្ថានធនាគារតម្រូវឱ្យស្នើសុំការអនុញ្ញាតពីអាជ្ញាធរត្រួតពិនិត្យជាមុនសិនទើបអាចប្រើប្រាស់សេវាបច្ចេកវិទ្យាក្លោដ។ ទោះយ៉ាងណាក៏ដោយតម្រូវការដាក់លាក់ស្តីពី ការគ្រប់គ្រងហានិភ័យ និងក្របខណ្ឌសន្តិសុខសាយប័រនៃសេវាបច្ចេកវិទ្យាក្លោដនៅក្នុងវិស័យហិរញ្ញវត្ថុពុំទាន់បានកំណត់ពេញលេញនៅឡើយ។ | លើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពលើការប្រើប្រាស់បច្ចេកវិទ្យាក្លោដក្នុងគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ |

| | | | |
|---|---|---|---|
| | បច្ចេកវិទ្យាឌីជីថល | ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ជាពិសេសប្រព័ន្ធបាគងដែលប្រើប្រាស់ថ្នាលបច្ចេកវិទ្យាឌីជីថលបានទទួលការគាំទ្រយ៉ាងខ្លាំងពីសាធារណជន។ ទោះបីជាមានការរីកចម្រើនបែបនេះក្តី ក៏នៅតែត្រូវការចាំបាច់ក្នុងការស្រាវជ្រាវអំពីករណីប្រើប្រាស់ថ្មីៗបន្ថែមទៀតតាមរយៈការពិភាក្សា និងកិច្ចសហការជាមួយគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីជំរុញនវានុវត្តន៍នៅក្នុងបច្ចេកវិទ្យាឌីជីថល។ | ពិនិត្យលទ្ធភាពក្នុងការដាក់ចេញផលិតផល និងសេវាកម្មថ្មីៗទៀតដែលប្រើប្រាស់បច្ចេកវិទ្យាឌីជីថល នៅក្នុងវិស័យធនាគារ |
| សសរស្តម្ភទី៣៖ គោលនយោបាយជំរុញ | អត្តសញ្ញាណឌីជីថល | បច្ចុប្បន្ន ថ្នាលអត្តសញ្ញាណឌីជីថលពុំទាន់បានបើកទូលាយឱ្យប្រើប្រាស់ក្នុងវិស័យហិរញ្ញវត្ថុនៅឡើយ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុភាគច្រើនកំពុងពង្រីកក្របខណ្ឌ និងកម្មវិធីឌីជីថលដើម្បីសម្រួលការផ្ទៀងផ្ទាត់អត្តសញ្ញាណអ្នកប្រើប្រាស់ ប៉ុន្តែយន្តការនេះនៅមិនទាន់មានប្រសិទ្ធភាព និងភាពងាយស្រួលនៅឡើយ។ ការឆ្ពោះទៅរកការប្រើប្រាស់អត្តសញ្ញាណឌីជីថលដែលជាប្រភពទិន្នន័យធានាទុកចិត្ត ត្រូវបានជឿជាក់ថានឹងក្លាយជាមធ្យោបាយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីបង្កើននីតិវិធីផ្ទៀងផ្ទាត់ និងបញ្ជាក់ភាពត្រឹមត្រូវនៃប្រតិបត្តិការហិរញ្ញវត្ថុ។ | ចូលរួមនៅក្នុងគំនិតផ្តួចផ្តើមថ្នាក់ជាតិក្នុងការអភិវឌ្ឍ និងប្រើប្រាស់ថ្នាលអត្តសញ្ញាណកម្មឌីជីថលរួម |
| | ក្របខណ្ឌធនាគារបើកចំហ | ការអភិវឌ្ឍក្របខណ្ឌធនាគារបើកចំហ កំពុងស្ថិតនៅក្នុងដំណាក់កាលដំបូង។ បច្ចុប្បន្ន មានគំនិតផ្តួចផ្តើមស្តីពី ការចែករំលែកទិន្នន័យរបស់ស្ថាប័នរដ្ឋាភិបាល ប៉ុន្តែពុំបានគ្របដណ្តប់លើវិស័យហិរញ្ញវត្ថុនោះទេ។ គ្រឹះស្ថានធនាគារមួយចំនួនបានផ្តួចផ្តើមរៀបចំយន្តការរៀងៗខ្លួនក្នុងការចែករំលែកទិន្នន័យ និងព័ត៌មានអ្នកប្រើប្រាស់ទៅភាគីទីបី ដើម្បីសម្រួលប្រតិបត្តិការ និងសេវាប្រកបដោយនវានុវត្តន៍។ វិធីសាស្ត្ររួមក្នុងការដាក់ចេញក្របខណ្ឌធនាគារបើកចំហក្នុងវិស័យហិរញ្ញវត្ថុនឹងជួយបង្កើនការប្រកួតប្រជែង និងជំរុញនវានុវត្តន៍ក្នុងការផ្តល់សេវាហិរញ្ញវត្ថុ។ | ពិនិត្យលទ្ធភាពក្នុងការអភិវឌ្ឍក្របខណ្ឌធនាគារបើកចំហនៅក្នុងវិស័យធនាគារ |
| | ក្របខណ្ឌការពារទិន្នន័យ | បច្ចុប្បន្ន ប្រទេសកម្ពុជាពុំទាន់មានច្បាប់ស្តីពី ក្របខណ្ឌការពារទិន្នន័យនៅឡើយ។ នៅក្នុងវិស័យធនាគារ មាត្រាទី៤៧ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានចែងថា រាល់ព័ត៌មាននិងទិន្នន័យរបស់អ្នកប្រើប្រាស់ក្នុងគ្រឹះស្ថានធនាគារត្រូវរក្សាការសម្ងាត់។ ទោះជា | ពិនិត្យលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តក្របខណ្ឌបទប្បញ្ញត្តិសម្រាប់ការការពារទិន្នន័យនៅក្នុងវិស័យធនាគារ |

| | | | |
|---|---|---|---|
| | | យ៉ាងណាក៏ដោយ នៅពុំទាន់មានបទប្បញ្ញត្តិជាក់លាក់ដែលពាក់ព័ន្ធនឹងក្របខណ្ឌការពារទិន្នន័យ ដូចជាការប្រមូលនិងការប្រើប្រាស់ទិន្នន័យ សិទ្ធនិងការព្រមព្រៀងប្រើទិន្នន័យ និងការគ្រប់គ្រងទិន្នន័យជាដើម។ | |
| | **ក្របខណ្ឌសន្តិសុខសាយប័រ** | រាជរដ្ឋាភិបាលកម្ពុជាបានព្យាយាមដោះស្រាយបញ្ហាក្របខណ្ឌសន្តិសុខសាយប័រ តាមរយៈគំនិតផ្តួចផ្តើមមួយចំនួន រួមមានការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី ក្របខណ្ឌសន្តិសុខសាយប័រ ក៏ដូចជាការបង្កើតស្ថាប័នទទួលខុសត្រូវចំពោះក្របខណ្ឌសន្តិសុខសាយប័រផងដែរ។ សេចក្តីព្រាងក្របខណ្ឌសន្តិសុខសាយប័រថ្នាក់ជាតិកំពុងត្រូវបានរៀបចំ ដែលទាមទារឱ្យមានការចូលរួមពីគ្រប់វិស័យ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ។ សម្រាប់វិស័យធនាគារ គោលការណ៍ណែនាំស្តីពី ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យាត្រូវបានដាក់ចេញដើម្បីបង្កើតប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាប្រកបដោយសុវត្ថិភាព។ ទោះជាយ៉ាងណាក្តី គោលការណ៍ណែនាំនេះ ចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពឱ្យស្របតាមក្របខណ្ឌសន្តិសុខសាយប័រថ្នាក់ជាតិ។ | **ពិនិត្យឡើងវិញលើក្របខណ្ឌហានិភ័យសន្តិសុខសាយប័រនៅក្នុងវិស័យធនាគារ រួមទាំងបច្ចេកវិទ្យាហិរញ្ញវត្ថុឱ្យស្របតាមក្របខណ្ឌថ្នាក់ជាតិសម្រាប់ក្របខណ្ឌសន្តិសុខសាយប័រ** |
| | **ចំណេះដឹងផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ និងឌីជីថល** | ចំណេះដឹងផ្នែកឌីជីថលជាធាតុសំខាន់មួយក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុ និងបរិវត្តកម្មឌីជីថល។ ចំណេះដឹងផ្នែកឌីជីថលនៅកម្ពុជានៅតែជាបញ្ហាប្រឈមដ៏ធំមួយ ជាពិសេសចំណេះដឹងក្នុងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ធនាគារជាតិនៃកម្ពុជាទទួលស្គាល់នូវភាពចាំបាច់ក្នុងការសហការជាមួយគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីដាក់ចេញយុទ្ធសាស្ត្រ និងកម្មវិធីនានាសម្រាប់លើកកម្ពស់ការយល់ដឹងអំពីសេវាកម្មដែលផ្តល់ដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ ក៏ដូចជាការអប់រំផ្នែកឌីជីថលហិរញ្ញវត្ថុ។ | **ដាក់ចេញកម្មវិធីស្តីពី ចំណេះដឹងហិរញ្ញវត្ថុដោយសហការជាមួយគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ** |
| | **គំនិតផ្តួចផ្តើមជំរុញនវានុវត្តន៍** | **១. បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ៖** ដោយផ្អែកលើសាវតាកន្លងមក នវានុវត្តន៍ក្នុងវិស័យធនាគារនៅកម្ពុជាមានការរីកចម្រើន និងបានទទួលជោគជ័យគួរឱ្យកត់សម្គាល់តាមរយៈការអនុវត្តវិធីសាស្ត្រសិក្សា និងសាកល្បង។ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យបាននឹងបន្តពិភាក្សាថែមទៀត ដើម្បីលើកកម្ពស់នវានុវត្តន៍ក៏ដូចជាការគាំទ្រដល់វិស័យហិរញ្ញវត្ថុ រួមទាំងផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុផងដែរ។ | **ពិនិត្យលទ្ធភាពក្នុងការរៀបចំ និងដាក់ឱ្យប្រើប្រាស់បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ** |

| | | | |
|---|---|---|---|
| | | **២. មជ្ឈមណ្ឌលនវានុវត្តន៍៖** បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាដើរតួនាទីជាអាជ្ញាធរគ្រប់គ្រង ដាក់ចេញបទប្បញ្ញត្តិពាក់ព័ន្ធ និងផ្តល់មតិណែនាំក្នុងការជំរុញនវានុវត្តន៍ផលិតផល និងសេវាហិរញ្ញវត្ថុឌីជីថលដែលនឹងត្រូវដាក់ចេញក្នុងទីផ្សារក៏ដូចជាដើរតួនាទីជាអ្នកទំនាក់ទំនងជាមួយវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ទោះជាយ៉ាងនេះក្តី កាតព្វកិច្ចទាំងនេះពុំទាន់ឆ្លើយតបពេញលេញទៅនឹងតម្រូវការទីផ្សារនិងការអភិវឌ្ឍន៍នោះទេ។ ការរៀបចំមជ្ឈមណ្ឌលជំរុញនវានុវត្តន៍ភាពដោយឡែកក្រោមរូបភាពជាគ្រឹះស្ថានឯកជន អាចត្រូវបានចាត់ទុកថាជាកន្លែងទំនាក់ទំនង សម្របសម្រួល ផ្តល់ការណែនាំជំរុញនវានុវត្តន៍ និងផ្តល់ការគាំទ្រចាំបាច់សម្រាប់ធុរកិច្ចថ្មីៗ ដោយរាប់បញ្ចូលទាំងបច្ចេកវិទ្យាហិរញ្ញវត្ថុផងដែរ។ | ពិនិត្យលទ្ធភាពក្នុងការរៀបចំ និងដាក់ឱ្យប្រើប្រាស់មុខងារមជ្ឈមណ្ឌលនវានុវត្តន៍សម្រាប់វិស័យធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ |

# ជំពូក ៦ ផែនការសកម្មភាពអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ

ការអនុវត្តផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុត្រូវបានរៀបចំសម្រាប់រយៈពេល ៥ ឆ្នាំ (២០២០-២០២៥) ហើយត្រូវបានបែងចែកជា ៣ ដំណាក់កាលរួមមាន ដំណាក់កាលរយៈពេលខ្លី (២០២០-២០២១) ដំណាក់កាលរយៈពេលមធ្យម (២០២២-២០២៣) និងដំណាក់កាលរយៈពេលវែង (២០២៤-២០២៥)។ ក្នុងដំណាក់កាលនីមួយៗបានកំណត់នូវសកម្មភាពជាក់លាក់ដែលត្រូវអនុវត្តស្របតាមផែនការលម្អិត និងការអនុវត្តជាក់ស្តែង ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

| ការងារអាទិភាពក្នុងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| សសរស្តម្ភ | ផ្នែក | យុទ្ធសាស្ត្រ | សកម្មភាព | គោលដៅរយៈពេលខ្លី (២០២០-២០២១) | គោលដៅរយៈពេលមធ្យម (២០២២-២០២៣) | គោលដៅរយៈពេលវែង (២០២៤-២០២៥) | ស្ថាប័នដឹកនាំ | ស្ថាប័នគាំទ្រ |
| សសរស្តម្ភទី១៖ | I. ការដាក់ប្រាក់បញ្ញើ និងការផ្តល់ឥណទាន | | | | | | | |
| សេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ | ក. សេវាធនាគារឌីជីថល | លើកកម្ពស់ផលិតផលនិងសេវាធនាគារឌីជីថលប្រកបដោយនវានុវត្តន៍ | ធ្វើការសិក្សា និងវាយតម្លៃស្ថានភាពបច្ចុប្បន្នចំពោះសេវាធនាគារឌីជីថលនៅកម្ពុជា | • រៀបចំការសិក្សា និងវាយតម្លៃស្ថានភាពបច្ចុប្បន្នចំពោះសេវាធនាគារឌីជីថលនៅកម្ពុជា | • អនុវត្តការសិក្សា និងវាយតម្លៃស្ថានភាពបច្ចុប្បន្នចំពោះសេវាធនាគារឌីជីថលនៅកម្ពុជា | • ពិនិត្យឡើងវិញលើលទ្ធផលនៃការសិក្សា និងវាយតម្លៃស្ថានភាពបច្ចុប្បន្នចំពោះសេវាធនាគារឌីជីថលនៅកម្ពុជា | ធនាគារជាតិនៃកម្ពុជា | សមាគមធនាគារនៅកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ខ. ថ្នាលហិរញ្ញប្បទានបច្ចេកវិទ្យាហិរញ្ញវត្ថុ | រៀបចំក្របខណ្ឌបទប្បញ្ញត្តិដែលទាក់ទងទៅនឹងថ្នាលហិរញ្ញប្បទានបច្ចេកវិទ្យាហិរញ្ញវត្ថុឱ្យស្របទៅតាមបរិបទ និងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជា | រៀបចំបទប្បញ្ញត្តិស្តីពីថ្នាលទីផ្សារឥណទានសម្រាប់ធានាការអនុវត្តប្រកបដោយសុវត្ថិភាពដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ | • រៀបចំសេចក្តីព្រាងបទប្បញ្ញត្តិស្តីពី ថ្នាលទីផ្សារឥណទានដោយផ្តោតលើចំណុចដូចខាងក្រោម៖<br>○ ការបង្ហាញព័ត៌មានហានិភ័យ<br>○ លក្ខខណ្ឌតម្រូវ និងការអនុលោមតាមថ្នាលផ្តល់ឥណទានលើទីផ្សារ<br>○ ការការពារអ្នកប្រើប្រាស់<br>○ កិច្ចសន្យាកម្ចីស្មើភាព<br>○ ការក្សាទ្រព្យកម្ចី | • ដាក់ចេញបទប្បញ្ញត្តិស្តីពី ថ្នាលទីផ្សារឥណទានដោយផ្តោតលើចំណុចដូចខាងក្រោម៖<br>○ ការបង្ហាញព័ត៌មានហានិភ័យ<br>○ លក្ខខណ្ឌតម្រូវ និងការអនុលោមតាមថ្នាល ផ្តល់ឥណទានលើទីផ្សារ<br>○ ការការពារអ្នកប្រើប្រាស់<br>○ កិច្ចសន្យាកម្ចីស្មើភាព<br>○ ការក្សាទ្រព្យកម្ចី | • តាមដានការអភិវឌ្ឍនិងការអនុវត្តរបស់ថ្នាលទីផ្សារឥណទាននិងពិនិត្យមើលលើភាពសមស្របនៃការដាក់ចេញបទប្បញ្ញត្តិ | ធនាគារជាតិនៃកម្ពុជា | សមាគមធនាគារនៅកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា |
| | II. សេវាផាត់ទាត់ និងទូទាត់សងប្រាក់ | | | | | | | |
| | រូបិយវត្ថុអេឡិចត្រូនិកនិងសេវាទូទាត់សងប្រាក់ឌីជីថល | ពិនិត្យក្របខណ្ឌបទប្បញ្ញត្តិ ដើម្បីគាំទ្រដល់នវានុវត្តន៍ និងគ្រប់គ្រងហានិភ័យដែលអាចកើតមាននៅក្នុងសេវាទូទាត់សងប្រាក់ឌីជីថល | ពិចារណាធ្វើបច្ចុប្បន្នភាពលើបទប្បញ្ញត្តិប្រុងប្រយ័ត្នពាក់ព័ន្ធនឹងការផាត់ទាត់ និងទូទាត់សងប្រាក់ឱ្យកាន់តែប្រសើរ | • ពិនិត្យឡើងវិញនូវបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក និងសេវាទូទាត់សងប្រាក់ឌីជីថល | • ធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក និងសេវាទូទាត់សងប្រាក់ឌីជីថល | • អនុម័តបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក និងសេវាទូទាត់សងប្រាក់ឌីជីថល | ធនាគារជាតិនៃកម្ពុជា | សមាគមធនាគារនៅកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| សសរស្តម្ភទី២៖ បច្ចេកវិទ្យាគាំទ្រ | ក. សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ | ដាក់ចេញគោលការណ៍ណែនាំដើម្បីជំរុញការដាក់ឱ្យប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រនៅក្នុងគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ | ដាក់ចេញសេចក្តីណែនាំស្តីពី ស្តង់ដារសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ សម្រាប់សេវាហិរញ្ញវត្ថុ ដែលធានាភាពងាយស្រួលក្នុងការប្រើប្រាស់ និងប្រតិបត្តិការឆ្លងអន្តរគ្រឹះស្ថាន | • រៀបចំសេចក្តីព្រាងណែនាំស្តីពី ស្តង់ដារសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ ដោយមានការចូលរួមពិគ្រោះយោបល់ពីភាគីពាក់ព័ន្ធ | • ការអនុវត្តស្តង់ដារសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ នៅក្នុងវិស័យហិរញ្ញវត្ថុ | • ពិនិត្យឡើងវិញលើស្តង់ដារសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ នៅក្នុងវិស័យហិរញ្ញវត្ថុ | ធនាគារជាតិនៃកម្ពុជា | សមាគមធនាគារនៅកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា |
| | ខ. បច្ចេកវិទ្យាបញ្ញាសិប្ប-និម្មិត និងម៉ាស៊ីនស្វ័យសិក្សា | ពិចារណាដាក់ចេញគោលការណ៍ណែនាំស្តីពី ការប្រើប្រាស់បច្ចេកវិទ្យាបញ្ញា-សិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សាក្នុងវិស័យធនាគារ | ដាក់ចេញសេចក្តីណែនាំស្តីពី ក្រមសីលធម៌ និងការទទួលខុសត្រូវនៃការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សា | • ការរៀបចំការពិគ្រោះយោបល់ជាមួយគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុស្តីពី បច្ចេកវិទ្យាបញ្ញា-សិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សា | • កំណត់បញ្ហាចម្បងៗទាក់ទងនឹងការប្រើ-ប្រាស់ បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សាក្នុងគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ | • ការដាក់ចេញសេចក្តីណែនាំស្តីពី ក្រមសីលធម៌ និងការទទួលខុសត្រូវនៃការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សាក្នុងគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ | ធនាគារជាតិនៃកម្ពុជា | សមាគមធនាគារនៅកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | គ. បច្ចេកវិទ្យាជីវមាត្រ | **ជំរុញការប្រើប្រាស់បច្ចេកវិទ្យាជីវមាត្រនៅក្នុងគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ** | ពិនិត្យលើបទប្បញ្ញត្តិដែលមានស្រាប់ ដើម្បីអនុញ្ញាតឱ្យមានការប្រើប្រាស់ទិន្នន័យជីវមាត្រ សម្រាប់នីតិវិធីចុះឈ្មោះ ប្រើប្រាស់ និងបើកគណនី | • ការពិនិត្យលើបទប្បញ្ញត្តិដែលមានស្រាប់ដើម្បីអនុញ្ញាតឱ្យមានការប្រើប្រាស់ទិន្នន័យជីវមាត្រសម្រាប់នីតិវិធីចុះឈ្មោះ ប្រើប្រាស់ និងបើកគណនី | • កំណត់អំពីបញ្ញត្តិសំខាន់ៗដើម្បីគាំទ្រការប្រើប្រាស់បច្ចេកវិទ្យាជីវមាត្រ | • ធ្វើវិសោធនកម្ម ឬដាក់ចេញបទប្បញ្ញត្តិបន្ថែម ដើម្បីគាំទ្រការប្រើប្រាស់បច្ចេកវិទ្យាជីវមាត្រ | ធនាគារជាតិនៃកម្ពុជា | សមាគមធនាគារនៅកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា |
| | ឃ. បច្ចេកវិទ្យាក្លោដ | **លើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពលើការប្រើប្រាស់បច្ចេកវិទ្យាក្លោដក្នុងគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ** | កំណត់បទប្បញ្ញត្តិជាក់លាក់ក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្លោដ សម្រាប់គ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ | • រៀបចំវេទិកាសាធារណៈជាមួយគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្លោដ | • កំណត់តម្រូវការរួម និងបទប្បញ្ញត្តិជាក់លាក់ក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្លោដសម្រាប់គ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ | • ដាក់ចេញបទប្បញ្ញត្តិជាក់លាក់ក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្លោដ សម្រាប់គ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ | ធនាគារជាតិនៃកម្ពុជា | សមាគមធនាគារនៅកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ង. បច្ចេកវិទ្យាឌីអិលធី | ពិនិត្យលទ្ធភាពក្នុងការដាក់ចេញផលិតផលនិងសេវាកម្មថ្មីៗទៀតដែលប្រើប្រាស់បច្ចេកវិទ្យាឌីអិលធីនៅក្នុងវិស័យធនាគារ | លើកទឹកចិត្តឱ្យមានការបង្កើតសហគមអ្នកប្រើប្រាស់បច្ចេកវិទ្យាឌីអិលធី | • ស្វែងយល់ពីការប្រើប្រាស់បច្ចេកវិទ្យាឌីអិលធី ចុងក្រោយនៅក្នុងវិស័យធនាគារ | • កំណត់ និងធ្វើការសាកល្បងលើករណីប្រើប្រាស់បច្ចេកវិទ្យាឌីអិលធី នៅក្នុងវិស័យធនាគារ | • ពិនិត្យលទ្ធភាពករណីប្រើប្រាស់បច្ចេកវិទ្យាឌីអិលធី នៅក្នុងវិស័យធនាគារ | ធនាគារជាតិនៃកម្ពុជា | សមាគមធនាគារនៅកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា |
| សសរស្តម្ភទី៣៖ គោលនយោបាយជំរុញ | ក.អត្តសញ្ញាណឌីជីថល | ចូលរួមនៅក្នុងគំនិតផ្តួចផ្តើមថ្នាក់ជាតិ ក្នុងការអភិវឌ្ឍ និងប្រើប្រាស់ថ្នាលអត្តសញ្ញាណកម្មឌីជីថលរួម | សិក្សាពីលទ្ធភាពលើការប្រើប្រាស់អត្តសញ្ញាណឌីជីថលនៅក្នុងវិស័យធនាគារជាមួយដៃគូពាក់ព័ន្ធ | • សិក្សាពីអត្ថប្រយោជន៍និងផលប៉ះពាល់នៃការប្រើប្រាស់អត្តសញ្ញាណឌីជីថលនៅក្នុងវិស័យធនាគារ | • ពិនិត្យតាមដានអំពីវឌ្ឍនភាព និងលទ្ធផលនៃការសិក្សា | • ប្រើប្រាស់ថ្នាលអត្តសញ្ញាណឌីជីថលរួម សម្រាប់វិស័យធនាគារ | ធនាគារជាតិនៃកម្ពុជា | សមាគមធនាគារនៅកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ខ. ក្របខណ្ឌធនាគារបើកចំហ | **ពិនិត្យលទ្ធភាពក្នុងការអភិវឌ្ឍក្របខណ្ឌធនាគារបើកចំហនៅក្នុងវិស័យធនាគារ** | សិក្សាលទ្ធភាពនៃការដាក់ចេញក្របខណ្ឌធនាគារបើកចំហសម្រាប់វិស័យធនាគារ | • រៀបចំវេទិកាសាធារណៈស្តីពីក្របខណ្ឌធនាគារបើកចំហជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ | • កំណត់បញ្ហាចម្បងៗពាក់ព័ន្ធនឹងក្របខណ្ឌធនាគារបើកចំហ ដូចជា វិធីសាស្ត្រអនុវត្ត វិសាលភាពប្រភេទទិន្នន័យដែលអាចចែករំលែក និងកិច្ចសម្របសម្រួល | • ពិនិត្យលទ្ធភាពដាក់ឱ្យប្រើប្រាស់ក្របខណ្ឌធនាគារបើកចំហ សម្រាប់វិស័យធនាគារ | ធនាគារជាតិនៃកម្ពុជា | សមាគមធនាគារនៅកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា |
| | គ. ក្របខណ្ឌការពារទិន្នន័យ | **ពិនិត្យលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តក្របខណ្ឌបទប្បញ្ញត្តិសម្រាប់ការការពារទិន្នន័យនៅក្នុងវិស័យធនាគារ** | រៀបចំបទប្បញ្ញត្តិស្តីពីក្របខណ្ឌការពារទិន្នន័យនៅក្នុងវិស័យធនាគារ | • រៀបចំសេចក្តីព្រាងបទប្បញ្ញត្តិស្តីពីក្របខណ្ឌការពារទិន្នន័យ ដោយផ្តោតជាពិសេសលើចំណុចដូចខាងក្រោម៖<br>○ សិទ្ធិប្រើប្រាស់ និងរក្សាការសម្ងាត់ទិន្នន័យ<br>○ ការផ្តល់សិទ្ធិ និងការយល់ព្រម<br>○ ការចែករំលែកទិន្នន័យ<br>○ ការគ្រប់គ្រងទិន្នន័យ | • ដាក់ចេញបទប្បញ្ញត្តិស្តីពី ក្របខណ្ឌការពារទិន្នន័យនៅក្នុងវិស័យធនាគារ | • ពិនិត្យលើប្រសិទ្ធភាពនៃបទប្បញ្ញត្តិស្តីពីក្របខណ្ឌការពារទិន្នន័យនៅក្នុងវិស័យធនាគារ | ធនាគារជាតិនៃកម្ពុជា | សមាគមធនាគារនៅកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ឃ. ក្របខណ្ឌសន្តិសុខសាយប័រ | ពិនិត្យឡើងវិញលើក្របខណ្ឌហានិភ័យសន្តិសុខសាយប័រនៅក្នុងវិស័យធនាគារ រួមទាំងបច្ចេកវិទ្យាហិរញ្ញវត្ថុឱ្យស្របតាមក្របខណ្ឌថ្នាក់ជាតិសម្រាប់ក្របខណ្ឌសន្តិសុខសាយប័រ | ពិនិត្យ និងបង្កើតក្របខណ្ឌហានិភ័យសន្តិសុខសាយប័រនៅក្នុងវិស័យធនាគារ | • បង្កើតក្រុមការងារសម្រាប់វាយតម្លៃក្របខណ្ឌហានិភ័យសន្តិសុខសាយប័រ នៅក្នុងវិស័យធនាគារ | • ធ្វើការវាយតម្លៃលើក្របខណ្ឌហានិភ័យសន្តិសុខសាយប័រ នៅក្នុងវិស័យធនាគារ | • ពិនិត្យឡើងវិញលើការវាយតម្លៃក្របខណ្ឌហានិភ័យសន្តិសុខសាយប័រនៅក្នុងវិស័យធនាគារ | ធនាគារជាតិនៃកម្ពុជា | សមាគមធនាគារនៅកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា |
| | ង. ចំណេះដឹងផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ និងឌីជីថល | ដាក់ចេញកម្មវិធីស្តីពីចំណេះដឹងហិរញ្ញវត្ថុដោយសហការជាមួយគ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ | ១. រៀបចំយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ | • កំណត់ក្រុមគោលដៅ និងមធ្យោបាយសម្រាប់យុទ្ធនាការ | • អនុវត្តយុទ្ធនាការជាមួយស្ថាប័នពាក់ព័ន្ធ | • ពិនិត្យឡើងវិញលើយុទ្ធនាការដែលបានដាក់ចេញ | ធនាគារជាតិនៃកម្ពុជា | សមាគមធនាគារនៅកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ២. រៀបចំកម្មវិធីបណ្តុះបណ្តាល និងសិក្ខាសាលា | • រៀបចំកម្មវិធីបណ្តុះបណ្តាល និងសិក្ខាសាលា | • អនុវត្តកម្មវិធីបណ្តុះបណ្តាល និងសិក្ខាសាលា | • ពិនិត្យឡើងវិញលើកម្មវិធីបណ្តុះបណ្តាលនិងសិក្ខាសាលា | ធនាគារជាតិនៃកម្ពុជា | សមាគមធនាគារនៅកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា |
| | | | ៣. លើកកម្ពស់ការប្រើប្រាស់សេវាធនាគារឌីជីថល | • រៀបចំយុទ្ធសាស្ត្រសម្រាប់លើកកម្ពស់ការប្រើប្រាស់ធនាគារឌីជីថល | • អនុវត្តកម្មវិធីលើកកម្ពស់ការប្រើប្រាស់សេវាធនាគារឌីជីថល | • ពិនិត្យឡើងវិញលើយុទ្ធសាស្ត្រសម្រាប់លើកកម្ពស់ការប្រើប្រាស់សេវាធនាគារឌីជីថល | ធនាគារជាតិនៃកម្ពុជា | សមាគមធនាគារនៅកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | **ច. គំនិតផ្តួច-ផ្តើមជំរុញនវានុវត្តន៍** | **១. ពិនិត្យលទ្ធភាពក្នុងការរៀបចំ និងដាក់ឱ្យប្រើប្រាស់បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ** | វាយតម្លៃអំពីអត្ថប្រយោជន៍ និងផលប៉ះពាល់នៃការអនុវត្តបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុសម្រាប់វិស័យធនាគារ | • ពិនិត្យលើបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុរបស់ប្រទេសនៅក្នុងតំបន់ | • កំណត់អំពីអត្ថប្រយោជន៍ និងផលប៉ះពាល់នៃការអនុវត្តបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ សម្រាប់វិស័យធនាគារ | • ពិនិត្យឡើងវិញលើលទ្ធភាពក្នុងការដាក់ឱ្យប្រើប្រាស់បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងវិស័យធនាគារ | ធនាគារជាតិនៃកម្ពុជា | សមាគមធនាគារនៅកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា |
| | | **២. ពិនិត្យលទ្ធភាពក្នុងការរៀបចំ និងដាក់ឱ្យប្រើប្រាស់មុខងារមជ្ឈមណ្ឌលនវានុវត្តន៍ សម្រាប់វិស័យធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ** | បង្កើតមជ្ឈមណ្ឌលនវានុវត្តន៍ សម្រាប់វិស័យធនាគារ | • រៀបចំការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ | • កំណត់អត្តសញ្ញាណភាគីពាក់ព័ន្ធដែលមានសមត្ថភាព ដើម្បីអនុវត្តតួនាទីនៃមជ្ឈមណ្ឌលនវានុវត្តន៍នៅក្នុងវិស័យធនាគារ | • ពិនិត្យឡើងវិញលើលទ្ធភាពក្នុងការដាក់ឱ្យប្រើប្រាស់មជ្ឈមណ្ឌលនវានុវត្តន៍នៅក្នុងវិស័យធនាគារ | ធនាគារជាតិនៃកម្ពុជា | សមាគមធនាគារនៅកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា |

# ឯកសារយោង


១. Cambodia: Implications of the draft cybercrime law. (2020, January 15). Retrieved from https://www.dataguidance.com/opinion/cambodia-implications-draft-cybercrime-law

២. Digital 2020: Cambodia — DataReportal – Global digital insights. (2020, February 17). Retrieved from

៣. Ehrentraud, J., Ocampo, D. G., Garzoni, L., & Piccolo, M. (2020). FSI Insights.

៤. Royal Government of Cambodia. (2019). National Financial Inclusion Strategy (NFIS) 2019-2025

៥. Royal Government of Cambodia. (2016). Financial Sector Development Strategy (FSDS) 2016-2025

៦. Sim C (2017). Report on Financial Technology (FinTech) in Cambodia. April 2017.